ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2013, 14:22
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០០នាទី**

**សវនាការលើកទី១៨៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោកស្រី ទី ស្រីនណា

លោក ឡោ ជុនធី

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោក ប៉ាស្កាល់ អូប៊ីង

*(Mr. Pascal AUBOIN)*

លោកស្រី កាទ្រីណា ម៉ារី ណាតាលី

*(Ms. Katrina Marie Natale)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក រ៊ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក នូវ ហ៊ាន់ (TCCP-100) | ខ្មែរ |
| លោកស្រី សូផាន់ សូវណ្ណី (TCCP-149) | ខ្មែរ |
| លោក យិន រំដួល (TCCP-170) | ខ្មែរ |
| លោកស្រី ប៉ូ ឌីណា (TCCP-117) | ខ្មែរ |

# ឧបសម្ព័ន្ធ

# ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី

**លោក នូវ ហ៊ាន់** (TCCP-100)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....... ទំព័រ ២

សួរដោយលោក សំ សុគង់ ផ្តើមពី ....... ទំព័រ ៤

សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី ....... ទំព័រ ១៩

សួរដោយលោក សុន អរុណ ផ្តើមពី ....... ទំព័រ ២៥

សួរដោយលោក គង់ សំអុន ផ្តើមពី ....... ទំព័រ ២៩

សួរដោយលោក អាកទ្ទូរ វែកគែន ផ្តើមពី ....... ទំព័រ ៣២

**លោកស្រី សុផាន់ សុវណ្ណី** (TCCP-149)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....... ទំព័រ ៣៦

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....... ទំព័រ ៥៣

**លោក យិន រំដួល** (TCCP-170)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....... ទំព័រ ៥៦

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី ....... ទំព័រ ៦៦

សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី ....... ទំព័រ ៧២

**លោកស្រី ម៉ូ ឌីណា** (TCCP-117)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....... ទំព័រ ៧៧

សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី ....... ទំព័រ ៧៩

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....... ទំព័រ ៩២

សួរដោយលោក សុន អរុណ ផ្តើមពី ....... ទំព័រ ៩៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូប ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីម្សិលមិញ។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានបុគ្គល និង -- ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមានលើកលែងតែសហមេធាវីនាំមុខជាតិ -- សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមិនមានមូលហេតុ។

សូមកត់សម្គាល់ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ ហើយតាមកាលវិភាគដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មថ្ងៃនេះមានបួនរូប៖ ទី១ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-100, ទី២ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-149, ទី៣ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-170 និងទី៤ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-117។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ ហើយរង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០២:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីTCCP-100 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្ម

នៅក្នុងបន្ទប់សវនាការ!

[០៩:០៤:១៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក នូវ ហ៊ាន់៖**

**ឆ៖** សូមទោស លោកប្រធាន ខ្ញុំឈ្មោះ នូវ ហ៊ាន់។

**ស៖** អរគុណលោក នូវ ហ៊ាន់ តើលោកកើតនៅថ្ងៃខែឆ្នាំណា? ហើយលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំកំណើតនៅភូមិផ្សារថ្នូរ ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ហើយថ្ងៃ -- អាយុកំណើត -- ការពិតទៅអាយុកំណើតខ្ញុំ ៧៩ហើយឆ្នាំនេះ ប៉ុន្តែខ្ញុំទៅចូលរៀនយឺតខ្ញុំធ្វើកំណើតមួយទៀត។ ឆ្នាំនេះខ្ញុំអាយុ៧៤ ខ្ញុំបន្ថយអាយុអស់៥ឆ្នាំ។

**ស៖** បាទ អរគុណ។ លោក ហ៊ាន់ ទីកន្លែងលំនៅដ្ឋានរបស់លោកសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** ខ្ញុំសព្វថ្ងៃនៅសហរដ្ឋអាមេរិក នៅរដ្ឋតិចសាស់ ទីក្រុងញូវស្តុន។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

[០៩:០៥:៤៧]

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ នូវ ចាន់ ហើយម្តាយឈ្មោះ អាន ភៀ្វ។

**ស៖** បាទ អរគុណ។ ហើយលោកមានប្រពន្ធទេ?

លោកកុំអាលទាន់និយាយ! រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមសិនដើម្បីលោកនិយាយនោះទើបប្រពន្ធសំឡេងរបស់លោកចូលនៅប្រព័ន្ធចែកចាយសំឡេងនៅក្នុងសម្រាប់គ្រប់ភាគីនៃរឿងក្តីនេះ ដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនេះ ហើយនិងសាធារណជន ក៏ដូចជាជាពិសេសទៅអង្គភាពបកប្រែភាសាលោកជាភាសាអង់គ្លេស និងភាសាបារាំងទៀត។ បង្អង់បន្តិចពេលដែលស្តាប់សំណួររួច។

បាទ សព្វថ្ងៃនេះលោកមានប្រពន្ធដែរឬទេ? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** សព្វថ្ងៃខ្ញុំរស់នៅម្នាក់ឯង ប្រពន្ធខ្ញុំស្លាប់នៅឆ្នាំ១៩៩៨។ ខ្ញុំមានកូនប្រាំបីនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នូវ ហ៊ាន់។ ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់ឲ្យឱកាសឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានឡើងចំពោះលោក ដែលមានជាអាទិ៍ការខូចខាតខាងផ្លូវកាយ ខាងផ្លូវចិត្ត ខាងសម្ភារៈ ហើយជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលបានកើតមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ននេះ ដែលនាំឲ្យលោកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទចំនួនពីររូបគឺ នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។

[០៩:០៨:១៥]

បាទនេះជាសេចក្តីរៀបរាប់។ សូមអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកដើម្បីធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានេះ។

បាទ លោកបង្អង់សិន! សូមអញ្ជើញលោកមេធាវី សហមេធាវីជាតិមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីជម្រាបជូនលោកប្រធាន សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ាន់ នេះគឺមេធាវី សំ សុគង់ ជាអ្នកទទួលសិទ្ធិនៅក្នុងការសួរសំណួរទៅលើរូបគាត់ពីខាងដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដូចជាដើមបណ្តឹងរដ្ឋប្បវេណី TCCP-149 គឺនឹងត្រូវសួរឡើងដោយលោកស្រីមេធាវី ជេត វណ្ណលី។ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-170 នឹងសួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ជេត វណ្ណលី ដូចគ្នា។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី TCCP-117 នឹងសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី -- មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទី ស្រ៊ីនណា។ បាទ សូមអរគុណលោកប្រធាន។

[០៩:០៩:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក នូវ ហ៊ាន់!

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមខ្ញុំបាទ សូមគោរពលោកប្រធានក្រុមប្រឹក្សា និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទមេធាវី សំ សុគង់ ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី លោក នូវ ហ៊ាន់ និងជាមួយនឹងមេធាវីអន្តរជាតិមួយរូបទៀតគឺកញ្ញា លី ម៉ាង្វៀន។ មុននឹងខ្ញុំតាំងសំណួរសួរទៅលោក នូវ ហ៊ាន់ ខ្ញុំបាទសូមជម្រាបជូននូវព័ត៌មានមួយចំនួននូវ -- ដែលខ្ញុំបាន -- ដែលមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ លោក នូវ ហ៊ាន់ ត្រូវបានទទួលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ដោយសារតែលោកជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំ។ ហើយនៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានឯកសារលេខ D22/1962។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** លោក នូវ ហ៊ាន់ មេធាវី -- ខ្ញុំបានប្រគល់ជូនឯកសារទាក់ទងនឹងទម្រង់ព័ត៌មាននៃការដាក់ពាក្យសុំតាំងជាដើមបណ្តឹងរដ្ឋប្បវេណីជូនលោករួចហើយ។ ហើយព័ត៌មានដែល ឬក៏ព័ត៌មាន ឬក៏រឿងរ៉ាវដែលមាននៅក្នុងឯកសារនេះ គឺជាព័ត៌មានមួយដែលជាព័ត៌មានពិតដែលលោកបានឆ្លើយពេលនោះមែនដែរទេលោក?

[០៩:១១:១៨]

**លោក នូវ ហ៊ាន់៖**

**ឆ៖** នេះជាព័ត៌មានពិតទាំងអស់ សូមជម្រាបលោកមេធាវី។

**ស៖** សូមអរគុណលោកនូវ ហ៊ាន់។ (លោកប្រធាន លោក នូវ ហ៊ាន់ គាត់រស់នៅសហរដ្ឋអាមេរិកជាមួយគ្រួសាររបស់លោក)។ ខ្ញុំសូមអរគុណលោកដែលធ្វើដំណើរពីចម្ងាយ ពីសហរដ្ឋអាមេរិកដើម្បីធ្វើសក្ខីកម្មនៅថ្ងៃនេះ។ សំណួរដែលខ្ញុំសួរលោកនៅថ្ងៃនេះ គឺដូចតទៅ៖ នៅពេលដែលជម្លៀសចេញពីទីក្រុងភ្នំពេញ តើលោកបានជួបប្រទះ--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចកំណត់បានទេថា តើដើម

បណ្ដឹងរដ្ឋប្បវេណីមួយណាដែលក្រុមមេធាវីរបស់លោកតាំងសំណួរ ហើយមុនសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ហើយដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវឱ្យថ្លែងទុក្ខសោកវេទនារបស់ខ្លួនរួចទើបសួរជាក្រោយ។ អង្គជំនុំជម្រះបានផ្ដល់វេទិកាជូនទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បែរជាមេធាវីតាំងសំណួរសួរទៅវិញ។ ទំនងជាស្ដាប់ការចាត់ចែងរបស់ប្រធានអង្គជំនុំជម្រះមិនបានទេ តាមមើល៍។

ទី២ លោក -- លោក ដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះអី? លោកឈ្មោះ ហ៊ាន់? ឬលោកឈ្មោះ ហ៊ុន?

**លោក នូវ ហ៊ាន់៖**

សូមទោស ហ៊ាន់ – ហ-៊ិ-ន-់-។

**ប្រធានអង្គជំនុំ៖**

ហ៊ាន់។

**លោក នូវ ហ៊ាន់៖**

ហ៊ាន់ – នូវ ហ៊ាន់។

**ប្រធានអង្គជំនុំ៖**

យើងស្ដាប់មេធាវីរបស់លោក ដូចអត់ស្គាល់លោកផង គាត់ថាលោកឈ្មោះ ហាន។ គាត់អានឈ្មោះលោកមិនត្រូវ។ អញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

បាទ សូមជម្រាបលោកប្រធាន សម្រាប់ករណីដើមបណ្ដឹងរដ្ឋប្បវេណី នូវ ហ៊ាន់ នេះគឺលោកមេធាវី សុគង់ នឹងសួរជាសំណួរ។ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទី២ និងទី៣ ពួកគាត់នឹងធ្វើសេចក្ដីថ្លែងការណ៍ជាមុន។ បន្ទាប់មកមេធាវីនឹងសួរសំណួរនៅក្នុងករណីដែលមានការខ្វះខាត។ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីចុងក្រោយគឺ TCCP-117 គឺមេធាវីនឹងសួរជាសំណួរដើម្បីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតាមនោះបាទ។ សូមអរគុណលោកប្រធាន។

[០៩:១៥:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា បើលោកមានបំណងធ្វើដូច្នេះ លោកផ្ដល់ព័ត៌មានមកឱ្យយើងជាប្រធានអង្គជំនុំជម្រះជាមុន

បើពុំដូច្នោះទេ គឺលោកជាអ្នកដឹកនាំសវនាការហើយ មិនមែនយើងទេ។

**សួរដោយលោក សំ សុគង់៖**

**ស៖** លោក នូវ ហ៊ាន់ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។ លោកអាចរៀបរាប់ជូនអង្គសវនាការបានទេថា តើនៅពេលដែលជម្លៀសពីទីក្រុងភ្នំពេញ តើលោកបានជួបប្រទះនូវបញ្ហាអ្វីខ្លះនៅពេលដែលលោកត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញនោះ?

**លោក នូវ ហ៊ាន់៖**

**ឆ៖** សូមទោសលោកមេធាវី ពេលជម្លៀសចេញពីភ្នំពេញជាទិដ្ឋភាពមួយថ្មីដែលយើងមិនដែលបានជួបប្រទះ។ មនុស្សច្រើនកុះករត្រូវធ្វើដំណើរនៅក្នុងរដូវក្ដៅ ខែមេសា ក្ដៅណាស់ លោកប្រធាន។ កាលណាថ្ងៃត្រង់ គឺកៅស៊ូហៀរចេញមក ហើយបងប្អូនដែលជម្លៀសចេញភ័យតក់ស្លុតអត់បានយកស្បែកជើងអត់បាន យកអីតាម។ ដូច្នេះមានសភាពមួយថ្មីមិនដែលជួបប្រទះ គឺត្រូវពងជើង ខ្លះយកស្រទបចេកទៅចងទៅនឹងបាតជើង ខ្លះយកកន្ទបខោអាវទៅចងដើម្បីចៀសវាងការរលាក ការធ្វើឱ្យពងបាតជើង។ ហើយមនុស្សច្រើនណាស់អ៊ូអែ ត្រឡប់ចុះត្រឡប់ឡើង។ ខ្លះបាត់កូន ខ្លះបាត់ប្ដី ខ្លះបាត់ប្រពន្ធទៅមុខផងទៅក្រោយផង ចង្អៀតគ្នា ហើយណាមួយមិនដឹងថា ទៅរកស្បៀងនៅទីណាអីទីណាគឺច្របូកច្របល់ណាស់តាមផ្លូវគឺថា វាជារឿងច្របូកច្របល់។ ហើយសត្វរុយដូចឃ្មុំ រុយសំបូរនោះសំបូររុយនៅតាមផ្លូវ។ ហើយអង្គតុលាការជ្រាបស្រាប់ហើយនៅពេលនោះគឺគ្មានបន្ទប់អនាម័យអីទេគឺមានសំអាងតែព្រៃរៀងខ្លួន។ ដូច្នេះចូលទៅព្រៃម្ដងៗនោះឃើញលាមក គ្រប់ទីកន្លែងទាំងអស់ ហើយមានអ្នកខ្លះឈឺមួលឈាមស្លាប់នៅតាមផ្លូវ ដោយសារថាម្នាក់ៗភិតភ័យស្លន់ស្លោមិនដឹងទៅរកថ្នាំឯណាមកឱ្យសមាជិកគ្រួសារ ហើយណាមួយអង្គការបង្ខំបណ្ដេញចេះតែទៅមុខៗហើយម៉្លោះហើយសុខចិត្តផ្ដាច់ចិត្តថា បោះបង់ចោលគ្រួសារ ទុកម្នាក់ឯងនៅហ្នឹង គឺស្លាប់ថ្មើរណាក៏ស្លាប់ទៅ ហើយនាំគ្នាចេះតែធ្វើដំណើរទៅមុខទៀតទៅ។

[០៩:១៦:៥០]

ពេលនោះពួកក្រុមគ្រួសារខ្ញុំបាទហ្នឹង គឺជម្លៀសចេញជាមួយបងប្អូនទាំងអស់តាមផ្លូវជាតិលេខ១ចេញយើងពីភ្នំពេញនេះទៅកាន់ទឹកដីខេត្តព្រៃវែង និងខេត្តស្វាយរៀង។ មានបងប្អូនខ្លះគេឆ្លងរហូតចូលទៅប្រទេសវៀតណាម សង្គមនិយមវៀតណាម។ ហើយសភាពការណ៍នៅពេលនោះគឺជួបប្រទះជាពិសេស គឺកង្វះស្បៀង។ ជាពិសេសទៅទៀតគឺកង្វះឱសថព្យាបាលថ្នាំផ្សេងៗ។ ពេលកូនចៅឈឺមិន

ដឹងទៅរកឯណា? ស្បៀងមិនដឹងទៅរកឯណា? មានលុយ លុយគេលែងចាយហើយ។ រូបិយប័ណ្ណរៀលគឺអត់មានតម្លៃទេ តម្លៃនៅលើអង្ករ។ អង្ករនោះមិនជាគីឡូ ឬជាបាវ អង្ករគឺគិតជាខាំ គិតជាកំប៉ុងទឹកដោះគោ។ ហើយពិបាករកទៀត។ អ៊ីចឹងទេគឺថាយើងជួបទាំងអស់គ្នាសុទ្ធតែជួបប្រទះនឹងការលំបាកគ្រប់បែបយ៉ាងទាំងអស់ក្នុងពេលជម្លៀសចេញដោយបង្ខំពីទីក្រុងភ្នំពេញ។ ខ្ញុំបាទសូមជម្រាបជូនអង្គសវនាការ ជម្រាបជូនលោកមេធាវីរបស់ខ្ញុំបាទតែប៉ុណ្ណេះសិន។

**ស៖** ទាក់ទងទៅនឹងការជម្លៀសចេញនោះដែរ តើក្រុមគ្រួសាររបស់លោកពូមានការបាត់បង់ឬក៏មានការព្រាត់ប្រាសគ្នានៅពេលនោះដែរឬទេ លោកពូ?

[០៩:១៨:២១]

**ឆ៖** ជារឿងអភ័ព្វសម្រាប់ខ្ញុំ ខ្ញុំត្រូវបាត់កូនស្រីមួយ។ ហេតុអ្វីបានជាខ្ញុំបាត់កូនស្រី? ពីព្រោះកូនស្រីខ្ញុំនេះប្អូនថ្លៃរបស់ខ្ញុំនៅភ្នំពេញហ្នឹងគេអត់កូនស្រី គេមានតែកូនប្រុសបួននាក់។ ហើយនៅតូចៗគេមកសុំខ្ញុំយកទៅនៅជាមួយនឹងគេ។ ដល់ពេលជម្លៀសយើងអត់បានជម្លៀសជាមួយគ្នាទេ ខ្ញុំចេញផ្លូវផ្សេង គេចេញផ្លូវផ្សេង។ អ៊ីចឹងទេខ្ញុំត្រូវបាត់កូនស្រីមួយ ទៅបានតែកូនប្រាំពីរនាក់ទេ។ កូនស្រីមួយត្រូវបាត់ទៅជាមួយក្រុមគ្រួសាររបស់ប្អូនស្រីរបស់ខ្ញុំ ប្អូនថ្លៃស្រីហ្នឹង។ ហើយគ្រួសារហ្នឹងគាត់មានកូនប្រុសបួននាក់ ប្ដីប្រពន្ធពីរនាក់ ត្រូវប្រាំមួយនាក់ និងកូនស្រីខ្ញុំមួយទៀត ត្រូវជាប្រាំពីរ និងម្ដាយរបស់ប្អូនថ្លៃប្រុសនឹងមួយទៀតគាត់ចាស់ជរា ត្រូវប្រាំបីនាក់។ ហើយមានបងប្អូនគាត់ ខាងប្អូនថ្លៃប្រុសខ្ញុំបាទហ្នឹងគេបានជួបខ្ញុំ៧៩ ហ្នឹងដែលយើងខំដើរស្រាវជ្រាវអ្នកណានៅរស់ ដើរស្រាវជ្រាវបងប្អូននឹងថាគាត់បានជម្លៀសទៅកាន់ខេត្តកំពង់ស្ពឺ។

[០៩:១៩:២០]

ហើយមួយទៀតជាសំណាងសម្រាប់ខ្ញុំ ដែលខ្ញុំបានព័ត៌មាននេះអំពីកូនស្រីខ្ញុំដោយសារ ៧៩ នេះក្រោយបានថារំដោះហើយនិងបងប្អូនណានៅរស់ច្រើនធ្វើបុណ្យ នាំគ្នាធ្វើបុណ្យឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធបងប្អូនដែលបាត់។ អ៊ីចឹងទេមានគ្រួសារមួយគេធ្វើបុណ្យនៅម្ដុំផ្សារអូរឫស្សី ហើយម្ដាយចិញ្ចឹមរបស់ភរិយាខ្ញុំបាទគាត់បានទៅចូលរួម។ ហើយកាលនោះអ្នកណាឲ្យតែជួបគ្នាគឺសួរគ្នា អ្នកជម្លៀសទៅណានៅទីណា នៅខេត្តណា? ដូច្នេះមានម្ដាយមីងម្នាក់គាត់ថា៖ ខ្ញុំ អ៊ូ! ខ្ញុំស្គាល់ហើយ ពេជ ចុងកាល់ នេះ ខ្ញុំស្គាល់ហើយគាត់មានកូនប៉ុណ្ណេះនាក់អីប៉ុណ្ណេះនាក់ គាត់នៅសហករណ៍ជាមួយខ្ញុំ ហើយដែលមូលហេតុថ្ងៃមួយកូនគាត់ឈឺ ប៉ុន្តែមិនដឹងជាកូនទីប៉ុន្មានទេ សុំច្បាប់នៅការដ្ឋានគាត់ហ្នឹង មកមើលកូន។ មកដល់

ឃើញពេទ្យខ្មែរក្រហមហ្នឹងឲ្យអាចម៍ទន្សាយ ហើយគាត់និយាយខ្សឹបៗ គាត់និយាយថា "កូនខ្ញុំអង្កាល់ជាទៅបើឲ្យថ្នាំអាចម៍ទន្សាយអ៊ីចឹង" ហើយគាត់មិនចាប់ភ្លឹកថាពាក្យហ្នឹងជាពាក្យធ្ងន់ស្រាលប្រមាថអង្គការអីទេ។ នៅក្បែរនោះក៏មានឈ្លបគេស្តាប់សំឡេងយើង គេក៏ យប់ពេលយប់គេប្រមូលគ្រួសារហ្នឹងទាំងមូល យកទៅកម្ទេចនៅក្នុងរាត្រីនោះឯង។ មិនដឹងទីណា កន្លែងណា ដោយវិធីណា គឺខ្ញុំបាទមិនបានដឹងទេ គ្រាន់តែបានព័ត៌មានពីគាត់ ដែលគាត់បានជម្រាបជូនម្តាយចិញ្ចឹមរបស់ភរិយាខ្ញុំបាទថាដូច្នេះ ថាគេប្រមូលទាំងអស់គ្នាយកទៅកម្ទេចនៅក្នុងយប់នោះឯង ដោយសារតែពាក្យសម្តី "អាចម៍ទន្សាយ, កូនខ្ញុំអង្កាល់ជា" តែប៉ុណ្ណឹង។ ខ្ញុំបាទសូមជម្រាបអង្គតុលាការ សូមជម្រាបប៉ុណ្ណេះ។

[០៩:២១:០០]

**លោក សំ សុគង់៖**

បាទ សូមអរគុណលោក នូវ ហ៊ាន់។ លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញរូបថត ដែលខ្ញុំបាទបានដាក់ជូនទៅលោកប្រធានរួចហើយ ហើយចង់លោក នូវ ហ៊ាន់ ដើម្បីចង្អុលទាក់ទងនឹងកូនស្រីរបស់គាត់នៅក្នុងរូបថតនេះ។ ដោយមាន ERN 00540951 ជាភាសាខ្មែរ។ សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក សំ សុគង់៖**

**ស៖** លោក នូវ ហ៊ាន់ លោកបានឃើញរូបថតនេះទេ។ តើលោកអាចប្រាប់អង្គសវនាការបានទេថាតើរូបមួយណាដែលជារូបកូនស្រីរបស់លោក?

**ឆ៖** នេះហើយ ជារូបកូនរបស់ខ្ញុំបាទដែលត្រូវទទួលរងគ្រោះស្លាប់ជីវិតនៅក្នុងឆ្នាំ១៩៧៥ គឺរូបនេះឯង ពាក់អាវផ្កានេះ ពណ៌ផ្កានេះ។

**ស៖** បាទសូមអរគុណ។ នៅពេលដែលកូនស្រីលោកដែលបានបែកពីលោកនៅក្នុងពេលជម្លៀសចេញទីក្រុងភ្នំពេញ តើកូនស្រីរបស់លោកស្រីមានអាយុប៉ុន្មាននៅពេលនោះ?

[០៩:២២:៣៧]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប បាទ។

**លោក នូវ ហ៊ាន់៖**

**ឆ៖** កាលនោះ គាត់អាយុពី៩ ទៅ១០ឆ្នាំ។

**ស៖** លោកអាចជម្រាបប្រាប់បានទេថា នៅពេលដែលកូនស្រីរបស់លោក បានបែកចេញពីលោក តើលោកអាចជម្រាបប្រាប់អង្គសវនាការនៅពេលនេះ ថាតើមានអ្វីដែលកើតឡើងចំពោះកូនស្រីលោក? ក៏ដូចជាប្អូនថ្លៃប្រុសរបស់លោក និងក្រុមគ្រួសារប្អូនថ្លៃរបស់លោកបានដែរឬទេ?

**ឆ៖** សូមជម្រាបអង្គតុលាការទាំងមូល សូមជម្រាបលោកមេធាវី ក្នុងឋានៈជាមនុស្សដែលតែងតែមានសតិសម្បជញ្ញៈ តើឪពុកណាមួយ តើម្ដាយណាមួយ ជីដូនណាមួយ ជីតាណាមួយ ដែលមិនស្រឡាញ់ចៅ មិនស្រឡាញ់របស់ខ្លួន ជាពិសេសនៅពេលកូនចៅឈឺម្ដងៗ គ្រាន់តែឈឺក្នុងលក្ខណៈឈឺដែលមានពេទ្យមានហ្មមើលក៏ភ័យព្រួយ ចុះទម្រាំបើបាត់បង់កូនដោយមិនដឹងហេតុផលអី គេប្រមូលយកទៅសម្លាប់ យកទៅកម្ទេចទាំងកណ្ដាលរាត្រីយ៉ាងនេះ។ តើៗកម្សួលនៃការសោកស្ដាយហ្នឹងយ៉ាងប៉ុនណា? នៅតែនឹកឃើញកូនថា តើវិធីដែលគេសម្លាប់កូនហ្នឹង ហើយនិងក្មួយតូចៗហ្នឹង តើដោយវិធីណានៅពេលនោះ? តើយ៉ាងម៉េចទៅ? អារម្មណ៍ហ្នឹងវានៅវិលវល់នៅតែក្នុងខ្លួន នៅតែវិលវល់នៅតែស្ដាយស្រណោះ ទោះបីខ្ញុំកូនច្រើនក៏ដោយ ខ្ញុំបាទកូនច្រើនក៏ដោយ នៅតែនឹកស្ដាយស្រណោះកូនដែលបាត់ទៅ នៅតែស្ដាយស្រណោះៗ ហើយធ្វើឲ្យអារម្មណ៍យើងអត់ល្ហសោះ វិលវល់ ណាប្រពន្ធខ្ញុំភរិយាខ្ញុំ កាលគាត់នៅរស់ គាត់ទៅរកហោរាអីមើល ថា“អូ៎! ខែ១២ កូនហ្នឹងមកហើយ”។ ខ្ញុំក៏សប្បាយបន់ទៅអើយ ធ្វើម៉េចបានជួបកូន ប៉ុន្តែការពិត អត់មានទេៗ។ ប្រសិនជានៅរស់កូនខ្ញុំអាចដឹងថា -- កាលណោះ គាត់១០ឆ្នាំ ៩ឆ្នាំ គាត់អាចដឹងថា ទីលំនៅនៅកន្លែងណា ជីដូនជីតា ឪពុកម្ដាយគាត់នៅទីណា គាត់នឹងវិលមករក។ ប៉ុន្តែនេះអស់មែន គឺប្រាកដជាអស់ទាំងគ្រួសារមែន អត់មានអ្នកណាមួយនៅរស់សោះនៅក្នុងគ្រួសារប្អូនថ្លៃរបស់ខ្ញុំបាទនេះ។ អ៊ីចឹងទេ ទុក្ខសោកទាំងអស់ហ្នឹងត្រូវជាន់ឈ្លីជានិច្ចកាលនៅលើអារម្មណ៍របស់ខ្ញុំបាទ ជាឪពុកហ្នឹងពិបាកចិត្តប៉ុនណា ខំថែចិញ្ចឹមឈឺនាំទៅពេទ្យ រកពេទ្យណាដែលពូកែ ដើម្បីព្យាបាលជំងឺកូន ហើយដល់ពេលហ្នឹង បាត់ទៅហ្នឹង ទៅទាំងភ័យព្រួយ ទៅទាំងអត់អាហារ ទៅទាំងអត់ថ្នាំពេទ្យ ហើយគេប្រមូលកណ្ដាលរាត្រីយកទៅសម្លាប់ហ្នឹង។ ដូច្នេះ អារម្មណ៍ខ្ញុំបាទហ្នឹងវិលវល់ណាស់។ នេះសូមជម្រាបលោកមេធាវីសម្រាប និងលោកប្រធានតុលាការសូមជម្រាបប៉ុណ្ណឹង។

[០៩:២៥:៤៩]

**ស៖** ទាក់ទងនៅពេលដែលពូមានអារម្មណ៍យ៉ាងដូចម្ដេចដែរ នៅពេលដែលពូបែកបាក់កូន ហើយក្រុមគ្រួសារដោយមិនដឹងថាអ្វីដែលកើតឡើងចំពោះពួកគេនោះ?

**ឆ៖** ខ្ញុំបាទមានតែការស្ដាយស្រណោះសោកសង្រេង ហើយមិនដឹងថាធ្វើវិធីណា រកវិធីណាដើម្បីនឹងមកផ្សះផ្សាផ្លូវចិត្តហ្នឹងវាបាត់ស្នាមរបួស គឺគ្មានវិធីទាល់តែសោះ។ ដូច្នេះ ទិដ្ឋភាពហ្នឹងវានៅពីលើ -- នៅតែពីមុខយើងជានិច្ចកាលថា កូនខ្ញុំស្លាប់ៗ ក្មួយខ្ញុំស្លាប់ ប្អូនថ្លៃខ្ញុំស្លាប់ ដោយគ្មានទោសកំហុសអ្វីទាំងអស់។ នៅអារម្មណ៍នៅតែអ៊ីចឹង។ បាននឹកឃើញថា អូ៎! ហើយចុះថាបដិវត្តន៍សង្គ្រោះជាតិ កសាងជាតិហ្នឹង ហើយចុះបើជួបប្រទះវិបត្តិយ៉ាងដូច្នេះ តើកសាងជាតិរបៀបម៉េច? ហើយនេះជាគំនិតរបស់ខ្ញុំបាទ។

[០៩:២៧:០០]

**ស៖** នៅពេលដែលពូបានដឹងដំណឹងពីការបាត់ខ្លួន ឬក៏ការស្លាប់របស់កូនស្រីរបស់ពូ ក៏ដូចជាក្រុមគ្រួសារប្អូនថ្លៃប្រុសរបស់ពូហ្នឹង នៅពេលនោះពូមានអារម្មណ៍យ៉ាងណាដែរនៅពេលដែលបានទទួលដំណឹងនេះ?

**ឆ៖** ដូចខ្ញុំបាទ បានជម្រាបមេធាវីរួចហើយអំមិញនេះ គឺអារម្មណ៍របស់ខ្ញុំហ្នឹងវិលវល់ ហើយខ្ញុំសូមបន្ថែមបន្តិច សូមតុលាការ លោកប្រធានតុលាការមេត្តាអភ័យទោស។ ខ្ញុំមានគ្រួសារមួយទៀត គឺប្អូនបង្កើតម្ដាយជាមួយគ្នា នោះក៏ត្រូវបាត់បង់អស់មួយគ្រួសារដែរ។ ស្វាមីរបស់គាត់ធ្វើការនៅរតនាគារស្វាយរៀង ខេត្តស្វាយរៀង ឃ្លាំងប្រាក់ស្វាយរៀង។ ហើយមន្ត្រីស្វាយរៀងទាំងអស់ គេបានអង្គការប្រមូលយកសម្លាប់អស់នៅក្នុងខេត្តស្វាយរៀង។ ហើយប្អូនស្រីខ្ញុំបាទហ្នឹងនាំកូនប្រាំនាក់ ស្រីប្អូននាក់ប្រុសម្នាក់មកកាន់ភូមិកំណើតរស់នៅក្នុងសហករណ៍ជាមួយ ហើយដល់៧៨ អង្គការត្រូវជម្លៀសទៅខាងបស្ចិមពាយ័ព្យហ្នឹង គាត់ក៏ស្ម័គ្រចិត្តទៅជាមួយជន្លងគាត់ទៅក្នុងខេត្តពោធិ៍សាត់។ ហើយក្នុងគ្រួសារហ្នឹងបាត់ដំណឹងទាំងអស់ អត់មានដំណឹងអីរលីង គឺត្រូវស្លាប់ទាំងអស់ ម្ដាយមួយ កូនប្រាំនាក់ ហើយឪពុក ជាស្វាមីហ្នឹងស្លាប់នៅក្នុងខេត្តស្វាយរៀងពេលរំដោះភ្លាមៗនោះ។ ដូច្នេះទុក្ខសោកហ្នឹងវាធ្ងន់ៗវាផ្ទួនលើផ្ទួន។ ហើយទន្ទឹមនឹងហ្នឹង សូមជម្រាបផង តុលាការជ្រាបផងថា ការបាត់បង់ផ្នែកសម្ភារៈផ្ទះកំណើតមួយដែលជាកេរមត៌ករបស់ជីតាជីដូន សម្រាប់ឪពុកម្ដាយខ្ញុំបាទ នៅឯភូមិស្រះថ្កូវ ឃុំកំពង់សឹង ស្រុកព្រះស្ដេច ខេត្តព្រៃវែងហ្នឹង ក៏ត្រូវអង្គការរុះយកទាំងអស់ មិនដឹងយកទៅឯងណាទេ ព្រោះតំបន់នោះជាតំបន់ដែលខ្មែរក្រហមចូលមករុករានទន្ទ្រានជិតទឹកដីបន្ទាយនៅអ្នកលឿងហើយ។

[០៩:២៩:០០]

ដូច្នេះអ្នកភូមិទាំងអស់ដែលមានគ្រួសារ បងប្អូននៅអ្នកលឿង នៅព្រៃវែង នៅភ្នំពេញគាត់នាំគ្នាភៀសខ្លួនចេញពីទីភូមិស្រុកនោះ មកនៅអ្នកលឿងព្រៃវែង ស្រុក -- ភ្នំពេញ។ នៅទីនោះខ្លះអ្នកដែលក្រីក្រ គឺនៅក្នុងនោះក៏អង្គការមិនបានរុះរើផ្ទះសម្បែងរបស់គាត់ទេ។ អ៊ីចឹងទេ គឺផ្ទះហ្នឹងមួយគឺត្រូវខ្មោចយកទៅបាត់ផ្ទះកំណើតនេះ។ ហើយមួយទៀត ផ្ទះមួយទៀត ត្រូវឆេះអស់នៅតំបន់ច្បារអំពៅនេះផ្ទះឈើប្រកស័ង្កសីតំបន់នេះ គឺថាខ្មែរក្រហមបានបាញ់ផ្គោងចុះឡើងក្លួងក្លាំងៗ ម្ដុំផ្ទះឈើ ផ្ទះស្លឹកអីទាំងប៉ុន្មានត្រូវឆេះខ្ទេចខ្ទីអស់។ ហើយសំខាន់សម្រាប់រូបខ្ញុំបាទ គឺឯកសារសំខាន់ៗនៃជីវិតរបស់ខ្ញុំបាទ និងគ្រួសារខ្ញុំបាទ ដូចជាសញ្ញាបត្រ ដូចជាសំបុត្រកំណើតរបស់កូនទាំងឡាយដែលបានកត់ត្រាទុក ឈឺពីថ្ងៃណា? ប្រើថ្នាំអី ជួបឧុកទ័រណាអី រាល់ឯកសារសំខាន់ៗ អស់។ ឥឡូវហ្នឹងៗ មិនដឹងថាកូនថ្ងៃណាកើតថ្ងៃណាខែណា ចាំតែឆ្នាំ ជួនកាលភ្លេចទាំងឆ្នាំទៅទៀត ព្រោះអត់មានឯកសារ។ នេះដែលជាសំខាន់សម្រាប់ជីវិតខ្ញុំ គឺស្រឡាញ់ដែលរូបថតពីតូចអីៗហ្នឹង គឺវាអស់រលីង។ ហើយដូច្នេះអារម្មណ៍របស់ខ្ញុំបាទ វាចេះតែនឹកថា ឱ! ជួបប្រទះ ខ្ញុំបាទយល់ថាការបាត់បង់ទាំងឡាយនេះ គឺមិនមែនតែរូបខ្ញុំបាទមួយទេ ប្រជាពលរដ្ឋជាច្រើននៅក្នុងប្រទេសកម្ពុជា គឺមានលំនាំស្រដៀងៗតែគ្នាហ្នឹង បាត់កូនបាត់ចៅ បាត់បងប្អូនស្លាប់ និរាសព្រាត់ប្រាសគឺច្រើនណាស់។ គឺថាធ្វើឲ្យមនុស្សរញ្ជួយ ប្រែប្រួលច្របូលច្របល់ទាំងអស់នៅក្នុងពេលរំដោះ៧៥នោះ។

[០៩:៣០:៥៤]

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងថ្ងៃនេះ តើលោកមានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលដែលលោកបានមកធ្វើសក្ខីកម្មនៅថ្ងៃនេះ?

**ឆ៖** សូមជម្រាបលោកប្រធានតុលាការ សូមជម្រាបលោកមេធាវី ថាខ្ញុំអារម្មណ៍ខ្ញុំបាទថ្ងៃនេះគឺខំប្រមូលស្មារតីយ៉ាងណា ដើម្បីនឹងឆ្លើយនូវសំណួរ និងដើម្បីនឹងផ្ដល់នូវសក្ខីកម្មចំពោះអង្គតុលាការអង្គសវនាការថ្ងៃនេះឲ្យបានជ្រាប ពីរឿងផ្ទាល់គ្រួសាររបស់ខ្ញុំបាទ។ ហើយខ្ញុំបាទនឹក -- ម្យ៉ាងនឹកឃើញសប្បាយចិត្តថា អូ៎! ខ្ញុំក៏មានវាសនា -- ក៏ឆ្លៀតឱកាសនេះសូមថ្លែងអំណរគុណដល់អង្គតុលាការទាំងមូលដែលបានជ្រើសរើសឈ្មោះខ្ញុំបាទ -- បានចូលមកបង្ហាញសក្ខីកម្មនៅថ្ងៃនេះ។ ហើយខ្ញុំសូមថ្លែងប្រាប់អំណរគុណដ៏ជ្រាលជ្រៅជាទីបំផុត។

**ស៖** ទាក់ទងទៅនឹងសំណង តើពូមានបំណងចង់សូមទៅតុលាការ ដើម្បីជួសជុលការខូចខាត

ក៏ដូចជាផ្លូវចិត្តរបស់ពូ ក្នុងនាមពូជាជនរងគ្រោះដែរឬទេ?

[០៩:៣២:១៧]

**ឆ៖** ខ្ញុំបាទគិតរួចមកហើយ ខ្ញុំបាទបានគិតរួចមកហើយថា បើសិនជាជាតិ បើសិនជាអង្គការសហប្រជាជាតិ ឬមួយប្រទេសផ្តល់អំណោយផ្សេងៗថានឹងផ្តល់អំណោយយ៉ាងណាដល់ជនរងគ្រោះ ខ្ញុំគិតថាទំហំបរិមាណមនុស្សដែលទទួល ដែលក្នុងនាមជាជនរងគ្រោះច្រើនណាស់ រាប់លាននាក់។ ដូច្នេះបរិមាណថវិកាហ្នឹងខ្ពស់ណាស់ ខ្ញុំបាទមិនសង្ឃឹមថា ចង់បានជាថវិកាសម្រាប់អ្វីសម្រាប់ផ្ទាល់ខ្លួន ដើម្បីជួសជុលផ្លូវចិត្តដែលបានរំជួលដោយការបាត់បង់កូន បាត់បង់ប្អូន ដោយសារការបាត់បង់ក្រុមគ្រួសារប្អូនថ្លៃនេះទេ។ ប៉ុន្តែសង្ឃឹមថា ថ្ងៃណាមួយដែលមានឱកាសមកថ្លែងទីនេះ នៅអង្គសវនាការទីនេះ ជម្រាបអង្គតុលាការ និងជម្រាបបងប្អូនទាំងអស់ឲ្យបានជ្រាបថា បាន និងបានទទួលយុត្តិធម៌មួយសមស្របតាមរយៈអង្គតុលាការ ហើយដែលទាំងអស់គ្នារង់ចាំតែយុត្តិធម៌នេះយូរមកហើយ។ សង្ឃឹមថា យុត្តិធម៌នេះបានផ្តល់ទៅដល់ជនរងគ្រោះ ទាំងវិញ្ញាណក្ខន្ធអ្នកស្លាប់បាត់បង់ទៅ ទាំងវិញ្ញាក្ខន្ធសាច់ញាតិដែលនៅរស់ ទាំងអស់គ្នាក៏ជាយុត្តិធម៌មួយសម្រាប់អង្គតុលាការដែរ ក៏ជាយុត្តិធម៌មួយសម្រាប់ខាងចុងចោទផងដែរ នៅថ្ងៃ ជាពិសេសថ្ងៃនេះ ទាំងថ្ងៃទៅខាងមុខទៀតដែលជាទីបញ្ចប់របស់អង្គតុលាការ។ បាទ សូមជម្រាបប៉ុណ្ណឹង។

**ស៖** បាទ ជាចុងក្រោយខ្ញុំបាទសូម ខ្ញុំមិនមានសំណួរអីទៀត ប៉ុន្តែខ្ញុំចង់សូមសួរលោកថា តើលោកមានអ្វីដែលត្រូវជម្រាបជូនតុលាការថ្ងៃនេះបន្ថែមទៀតទេ?

[០៩:៣៤:១៨]

**ឆ៖** ខ្ញុំបាទឆ្លៀតឱកាសនេះផងដែរ គិតថាខ្ញុំបាទភ័យបំផុត ខ្លាចរឿងបញ្ហាពេលវេលា ប៉ុន្តែខ្ញុំបាទសូមអនុញ្ញាតពីលោកប្រធានអង្គតុលាការថ្ងៃនេះ ខ្ញុំគឺចង់លើកសំណួរខ្លះជូនទៅអស់លោកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលនៅរស់ ដែលបានមានវត្តមាននៅទីនេះ ដើម្បីនឹងឆ្លើយនូវសំណួររបស់ខ្ញុំបាទតិចតួចទេសំណួរហ្នឹង។ ហើយបើសិនជាអង្គតុលាការអនុញ្ញាត ខ្ញុំនឹងលើកសំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! នេះជាសិទ្ធិរបស់លោក។ ក្នុងនាមលោកជាភាគីលោកអាចតាំងសំណួរគ្រាន់តែលោកត្រូវការតាំងសំណួរនោះតាមរយៈប្រធានអង្គជំនុំជម្រះសាលាដំបូង គឺដើម្បីអង្គជំនុំជម្រះបាននឹងបញ្ជូននូវសំណួររបស់លោកទៅជនជាប់ចោទ ឬក៏ទៅគោលដៅដែលត្រូវឆ្លើយតបទៅនឹងសំណួរ។

សូមអញ្ជើញ!

**លោក នួរ ហ៊ាន់៖**

សូមជម្រាបលោកប្រធានអង្គតុលាការ សូមជម្រាបអង្គសវនាការទាំងមូល គឺសំណួរទាំងនោះ គឺសំណួរទី១ ក្នុងពេលសវនាការកន្លងមកមកទល់ថ្ងៃនេះ តាមខ្ញុំបាទបានតាមដានស្តាប់ មេដឹកនាំខ្មែរក្រហមតែងតែបដិសេធគ្រប់សំណួរដេញដោលទាំងអស់ គ្រប់ទឡ្ហីករណ៍ដែលជនរងគ្រោះបានលើកទាំងអស់។ គាត់ច្រើនតែឆ្លើយថា មិនបានដឹងៗៗ។ ហើយចុះខ្ញុំបាទចេះតែឆ្ងល់ ដូចថាគាត់ឆ្លើយថា គាត់ការពារទឹកដី មិនឲ្យបាត់បង់ទឹកដី ប៉ុន្តែទន្ទឹមនឹងហ្នឹងការបាត់បង់ជីវិតមនុស្សពីមួយថ្ងៃទៅមួយថ្ងៃកាន់តែបាត់ទៅៗ ជាពិសេសមិនបាច់និយាយថាពីបរិមាណចំនួនប្រជាជនទេ ប្រជាពលរដ្ឋយើងទេ។ សួរថា បរិមាណថ្នាក់ដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យទៅណាបាត់អស់ទៅ? នៅសល់តែលោកមេដឹកនាំខ្មែរក្រហមតែពីររូបប៉ុណ្ណោះ អ្នកដទៃទៅណាបាត់អស់ទៅ? ពេលថា ឮថាកម្ទេចបាត់មួយហើយ មិនដែលឮសួរឈ្មោះថាមានមេដឹកនាំណាមួយទៀតមកជំនួសកន្លែងដែលអ្នកបាត់ទៅ? ហើយឥឡូវដល់ឃើញ ឥឡូវសព្វថ្ងៃឃើញសល់តែមេដឹកនាំតែពីរនាក់ ហើយចុះទាំងអស់គ្នាទៅបាត់បង់ទៅ? អាហ្នឹងជាសំណួរខ្ញុំបាទមួយចង់បញ្ជាក់ថា មិនបានសម្លាប់ទេ ចង់ដឹកនាំស្រុកទេសឲ្យរីកចម្រើន។

[០៩:៣៦:៥៧]

ហើយសំណួរមួយទៀត គាត់ថាដើម្បីជួយសង្គ្រោះជាតិ ដើម្បីកសាងប្រទេសជាតិ ហើយ -- ប៉ុន្តែដូចខ្ញុំបាទបានរៀបរាប់ហើយ រាល់សមាជិកដែលបានមកថ្លែងនៅទីនេះនៅក្នុងនាមជាជនរងគ្រោះ តែងតែលើកពីហេតុផល ការបាត់បង់ ការវិនាស ខូចខាត ជាពិសេសក្បួនខ្នាតទាំងឡាយត្រូវខ្ទេច ត្រូវខ្ទី សៀវភៅទាំងឡាយប្រមូលយកទៅដាក់រោងចក្រនៅចាក់អង្រែ ដើម្បីស្លធ្វើជាក្រដាសថ្មី។ ហើយអ្នកបញ្ញវន្តជាច្រើន ទាំងអ្នកនៅក្នុងស្រុក ទាំងអ្នកនៅក្រៅស្រុក ប្រមែប្រមូលមកកម្ទេចអស់ជាច្រើន។ នេះដែលយើងគិតថាកសាងស្រុករបៀបម៉េច? កសាងប្រទេសជាតិរបៀបម៉េច? មូលដ្ឋានគ្រឹះដែលសម្រាប់កសាងប្រទេសជាតិបាត់បង់អស់ ជាពិសេសធនធានមនុស្ស ជាពិសេសបញ្ញាជន បាត់បង់អស់ហើយ អ៊ីចឹងទេកសាងជាតិយ៉ាងម៉េច? ចម្រើនយ៉ាងម៉េច? យកស្អីមកដើម្បីធ្វើម៉េចដើម្បីឲ្យបានអាចម្រើនហ្នឹងមក? ខ្ញុំបាទនៅតែឆ្ងល់ ខ្ញុំបាទមិនយល់។ អ៊ីចឹងទេ បើសិនជាលោកអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យមានឱកាសហើយ អាចឆ្លើយនឹងសំណួរខ្ញុំបាទសូមមេត្តា។ ខ្ញុំបាទមានសំណួរប៉ុណ្ណឹង ហើយនឹងចុងក្រោយខ្ញុំនឹងមានការកត់សម្គាល់របស់ខ្ញុំមួយនៅចុងក្រោយមួយទៀត សូមជម្រាបអង្គតុលាការជ្រាបប៉ុណ្ណឹង

បាទ។ សូមអរគុណ។

[០៩:៣៨:៣៣]

**ប្រធានអង្គជំនុំ៖**

លោក នួរ ហ៊ាន់ លោកគប្បីរៀបចំនូវសំណួររបស់លោកម្តងទៀត សាជាថ្មីឡើងវិញ។ សួរឲ្យខ្លីទៅបានហើយសំណួររបស់លោកមានលក្ខណៈជាអត្ថាធិប្បាយវែងពិបាកស្តាប់ ពិបាកយល់ណាស់សំណួរនេះ។ សូមលោករៀបចំនូវសំណួរឲ្យបានខ្លី ងាយយល់ ដើម្បីគោលដៅដែលស្តាប់នឹងសំណួរហើយត្រូវឆ្លើយនឹងសំណួរនោះយល់នឹងខ្លឹមសារនឹងសំណួររបស់លោកផង ទើបអាចឆ្លើយសមស្រប ហើយនិងឆ្លើយតបចំទៅនឹងសំណួរដែលសួរ។ សំណួរអម្បាញ់មិញនេះទំនងជាមិនមែនសំណួរទេ បើរៀបចំដូច្នេះ។

**លោក នួរ ហ៊ាន់៖**

សំណួរទី១ សួរថានៅក្នុងអំឡុងពេលសវនាការជនជាប់ចោទទាំងអស់បានផ្តល់សក្ខីកម្មថា ពួកគាត់មិនបានដឹងអំពីបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលរបស់កម្ពុជាប្រជាធិតេយ្យទេ។ ប៉ុន្តែខ្មែរក្រហម ឈ្លប និងខ្មែរក្រហម និងប្រជាជនដទៃទៀតត្រូវបានបាត់បង់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃទាំងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមក៏បាត់ ចុះហេតុអ្វីការបាត់បង់ខ្លួននេះនៅពេលនោះ គាត់ទៅទីណា? អ្នកណាអ្នកកម្ទេចគាត់? អ្នកណាសម្លាប់គាត់? តើអ្នកដឹងអំពីបទឧក្រិដ្ឋដែលបានកើតឡើងទេនៅពេលដែលអស់លោកនៅកាន់អំណាចនៅពេលនោះ? ហ្នឹងសំណួរទី១។

[០៩:៤០:១៧]

ហើយសំណួរទី២ជនជាប់ចោទទាំងពីររូបពួកគាត់បាននិយាយថាពួកគាត់បានការពារជាតិសង្គ្រោះជាតិ ប៉ុន្តែប្រជាជនជាច្រើនត្រូវបានសម្លាប់ត្រូវបានកម្ទេចដោយច្បាប់អង្គការ។ នៅពេលដែលប្រជាជនត្រូវបានសម្លាប់ តើពួកគេសម្លាប់អស់ទៅ អស់លោក លោកដឹកនាំខ្មែរក្រហមថា ការពារទឹកដីចុះទឹកដីហ្នឹង ការពារទឹកដីដែលសល់ហ្នឹងឲ្យអ្នកណានៅ បើទន្ទឹមនឹងហ្នឹងសម្លាប់ប្រជាពលរដ្ឋកម្ពុជាអស់រាប់លាននាក់អ៊ីចេះទៅហើយ។ នេះជាសំណួរទី២។ សូមជម្រាបអង្គសវនាការជ្រាប។ សូមអភ័យទោស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ហ៊ាន់។ អង្គជំនុំជម្រះសូមបញ្ជូនសំណួរនេះទៅជូនទៅជនជាប់ចោទដោយជូនទៅលោក ខៀវ សំផន មុនលោកនួន ជា។ លោក ខៀវ សំផន តើលោកអាចឆ្លើយតបទៅនឹងសំណួរដែលសួរដោយដើមបណ្តឹងរដ្ឋប្បវេណី នួ ហ៊ាន់ ចំនួនពីរសំណួរនេះបានទេ? សូមអញ្ជើញ!

00917917



[០៩:៤១:៤៧]

**លោក ខៀវ សំផន៖**

បាន សូមគោរពលោកប្រធាន។ សូមគោរពអស់លោក លោកស្រី ចៅក្រមទាំងអស់។ សូមគោរពអង្គសវនាការទាំងមូល។ សូមជម្រាបសួរលោក នូ ហ៊ាន់។ លោកបានបាត់បង់កូនស្រីរបស់លោកដែលជាទីស្រលាញ់របស់លោក បាត់បង់បងថ្លៃរបស់លោក និងបាត់បង់បងប្អូនខ្លះទៀតមួយចំនួន។ នេះជាសោកនាដកម្មមួយទៀតដែលបន្ថែមលើសោកនាដកម្មដែលភាគីស៊ីវិល និងសាក្សីមុនៗបានមកថ្លែងរៀបរាប់ជម្រាបអង្គសវនាការជាបន្តបន្ទាប់។ ខ្ញុំសូមទោសលោកដោយសូមជម្រាបលោកថាកាលជំនាន់កម្ពុជាប្រជាធិបតេយ្យខ្ញុំមិនបានដឹងទាល់តែសោះនូវរឿងរ៉ាវជាទុក្ខសោកលំបាកវេទនារបស់ប្រជាជនយើងយ៉ាងនេះទេ។

ជាថ្មីម្តងទៀត ខ្ញុំសូមទោសលោក និងប្រជាជនយើងដែលរងគ្រោះ។ ឥឡូវខ្ញុំសូមបែរមកឆ្លើយនឹងសំណួររបស់លោក។ សំណួរទី១ លោកថាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ ចេះតែឆ្លើយថាអត់ដឹងៗរឿងអី។ ខ្ញុំសូមជម្រាបលោកថា ខ្ញុំមិនដឹងមែន។ មិនដឹង ម៉េចបានមិនដឹង? ព្រោះ ខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ។ ខ្ញុំជាបញ្ញាជនមួយរូបដែលជំនាន់នោះគេចាត់ទុកថា ជាមនុស្សទន់ជ្រាយ។ ដូច្នេះ គេ អ្វីគេឲ្យខ្ញុំដឹងតែរឿងដែលល្អៗ។ ឯរឿងណាដែលមិនល្អគេមិនឲ្យខ្ញុំដឹងទេ អានេះហើយដែលខ្ញុំវាអត់ដឹងមែន។ ខ្ញុំវាមិនដឹងមែនទាល់តែសោះតែម្តង ខ្ញុំសូមជម្រាបលោកដោយស្មោះយ៉ាងនេះ។

[០៩:៤៥:០៦]

ទី២ ខ្ញុំចូលរួមជាមួយកម្ពុជាប្រជាធិបតេយ្យសឹងដោយចៃដន្យទេ ហើយខ្ញុំគិតថា វាមករួមនេះ គឺមករួមចំណែកតស៊ូការពារជាតិ ដើម្បីជាតិរស់។ រួមចំណែកប្រមូលកម្លាំងជាតិទាំងអស់តស៊ូប្រឆាំងនឹងសង្គ្រាម។ កាលនោះប្រទេសយើងត្រូវរងគ្រោះរោលរាលឆាបឆេះដោយភ្លើងសង្គ្រាមយ៉ាងណាៗលោកជ្រាបហើយ។ ដូច្នេះដែលខ្ញុំមកចូលរួម គោលបំណងខ្ញុំមិនមែនមករួមកាប់សម្លាប់ ពិសេសកាប់សម្លាប់ខ្មែរគ្នាឯងស្លូតត្រង់នោះទេ។ ខ្ញុំធ្វើអ៊ីចឹងទៅមិនរួចទេ។ ឯមនុស្សដែលសម្លាប់កូនស្រីរបស់លោក បងថ្លៃរបស់លោក និងបងប្អូនផ្សេងទៀតរបស់លោក ខ្ញុំយល់ថា គួរតែរកឲ្យឃើញដើម្បីយកមកកាត់ទោស។ ធ្វើម៉េចរកឲ្យទាល់តែឃើញ។

ខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង។ សូមជម្រាបអង្គសវនាការប៉ុណ្ណឹង។ សូមអត់ទោស។ សូមអស់។

[០៩:៤៧:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។ ចុះលោក នួន ជា វិញ តើលោកឆ្លើយនឹងសំណួរហ្នឹងយ៉ាងដូចម្តេច? សូមអញ្ជើញលោក នួន ជា។

**លោក នួន ជា៖**

ខ្ញុំសូមគោរពលោកប្រធាន។ ខ្ញុំសូមគោរពដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមិនចាំឈ្មោះផង សូមអត់ទោស។ ខ្ញុំសូមគោរពបងប្អូនជនរួមជាតិទាំងអស់ ដែលបានមកចូលរួមក្នុងអង្គប្រជុំ ហើយនិងនៅក្នុងប្រទេស និងក្រៅប្រទេស។

ជាបឋម ខ្ញុំសូមបញ្ជាក់ម្តងទៀត នូវតួនាទីនិងភារកិច្ចរបស់ខ្ញុំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមបញ្ជាក់ដូចតទៅនេះ៖

[០៩:៤៨:១០]

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ខ្ញុំទទួលភារកិច្ចជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា មានតួនាទីភារកិច្ចខាងការអប់រំ ឃោសនាផ្ទៃក្នុងបក្ស នេះមួយ។ មួយទៀត ខ្ញុំទទួលនាទីខាងប្រធានគណៈកម្មាធិការសភាតំណាងប្រជាជនកម្ពុជា។ ខ្ញុំមានតួនាទីតែពីរប៉ុណ្ណឹងទេ។ ឯខាងនីតិប្រតិបត្តិខ្ញុំគ្មានតួនាទីអ្វីទេ។ នេះសូមជម្រាប។ ដូច្នេះ រឿងអ្វីទាំងអស់ មានរឿងខ្លះ ខ្ញុំផ្ទាល់ខ្លួនបានដឹងខ្លះ ក៏ប៉ុន្តែរឿងជាច្រើនដែលមិនបានដឹង។ នេះខ្ញុំសូមជម្រាបឲ្យស្មោះអស់ពីចិត្ត។ មិនមែនខ្ញុំគេចពីការទទួលខុសត្រូវទេ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ថាការខូចខាត ការគ្រោះថ្នាក់របស់ជាតិខ្ញុំ ក្នុងឋានៈខ្ញុំជាម្នាក់ទទួលនាទីដឹកនាំ ខ្ញុំត្រូវតែទទួលការខុសត្រូវ។ ខ្ញុំសូមទទួលដោយស្មោះអស់ពីដួងចិត្ត។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

ភារកិច្ចរបស់ខ្ញុំ ដូចដែលខ្ញុំបានជម្រាបហើយ គឺថាខ្ញុំគ្មាននាទីអីខាងនីតិប្រតិបត្តិទេ។ ខ្ញុំនាទីខាងបក្ស ធ្វើខាងការអប់រំ ឃោសនាផ្ទៃក្នុងបក្ស។ នាទីខាងរដ្ឋបាលគឺប្រធានគណៈកម្មការសភាតំណាងប្រជាជន។ ឯភារកិច្ចខាងសភាតំណាងប្រជាជនកម្ពុជាក៏មិនទាន់បានធ្វើអីផង ស្រាប់តែកងទ័ពវៀតណាមចូលមកឈ្លានពានប្រទេសកម្ពុជា។ នេះខ្ញុំសូមជម្រាបតែប៉ុណ្ណឹងដោយសង្ខេប។ ម្តងទៀត ខ្ញុំសូមចូលរួមមរណទុក្ខជាមួយលោកអ្នក លោកឈ្មោះ ខ្ញុំភ្លេចឈ្មោះទៅហើយ ដើមបណ្តឹងរដ្ឋប្បវេណីនេះ ខ្ញុំសូមចូលរួមគោរពនៅវិញ្ញាណក្ខន្ធរបស់ឪពុកម្តាយ មាមីងរបស់លោក កូនចៅរបស់លោក ក៏ដូចជាសាច់ឈាមរបស់ខ្ញុំ។ នេះខ្ញុំសូមបញ្ជាក់ម្តងទៀត ដូចតអ៊ីចឹង។

ខ្ញុំសូមអស់លោកប្រធាន សូមគោរពលោកប្រធាន។

[០៩:៥០:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នួន ជា។

តើមានបញ្ហាអីទៀត សូមអញ្ជើញលោក នូវ ហ៊ាន់!

**លោក នូវ ហ៊ាន់៖**

សូមអភ័យទោសលោកប្រធានតុលាការ។ សូមអភ័យទោសអង្គសវនាការទាំងមូល ខ្ញុំបាទចុងក្រោយមុននឹងបញ្ចប់ហ្នឹង ខ្ញុំបាទ សូមឆ្លៀតឱកាសនេះ សូមថ្លែងអំណរគុណដល់អង្គការសហប្រជាជាតិរួមជាមួយនិងរាជរដ្ឋាភិបាលកម្ពុជាបានបង្កឱកាសបង្កើតជាអង្គតុលាការ ដំណើរការជំនុំជម្រះក្ដីនៅអំឡុងកម្ពុជាប្រជាធិបតេយ្យរហូតដល់ថ្ងៃនេះ ទោះបីមានការជួបលំបាកខ្លះកន្លងមក។ ហើយក៏សូមឆ្លៀតអំណរគុណដល់ប្រទេសបណ្ដាលមិត្តជាច្រើន ដែលមានសប្បុរសធម៌បានផ្ដល់នូវថវិកាជូនឲ្យអង្គតុលាការទាំងមូលអាចធ្វើដំណើរមកដល់ថ្ងៃនេះ និងទៅដល់បន្តទៅបញ្ចប់នៅថ្ងៃខាងមុខ។

[០៩:៥១:៤៣]

ក្នុងនាមប្រជាពលរដ្ឋកម្ពុជា សូមថ្លែងអំណរគុណក្នុងនោះក៏មានរូបខ្ញុំបាទមួយផងដែរ ហើយទន្ទឹមនឹងនេះ ខ្ញុំបាទចង់និយាយខ្លះបន្តិចទៀតពីគំនិតយោបល់របស់ខ្ញុំបាទ។ ហើយចុងក្រោយខ្ញុំមានបទចម្រៀងខ្លីវាដូចជាកំណាព្យដែរ ដើម្បីរំឭកដល់អារម្មណ៍ទាំងអស់គ្នា ទាំងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ទាំងបងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលមានជីវិតមកដល់ថ្ងៃនេះ តើយើងអាចនឹកឃើញទេសម័យនោះយ៉ាងម៉េច?ៗ ហើយខ្លីទេ។ ហើយបើសិនជាលោកប្រធានតុលាការអនុញ្ញាត ខ្ញុំបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

**លោក នូវ ហ៊ាន់៖**

ខ្ញុំបាទផ្ទាល់ជាគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ខ្ញុំបាទគិតថា អង្គការកាលនោះ អង្គការខ្មៅ អង្គការចិត្តខ្មៅកាលណោះ។ លោកចង់ឲ្យប្រជាពលរដ្ឋកម្ពុជារស់រានមានជីវិតនៅក្នុងឥស្សរភាព នៅក្នុងបូរណភាពទឹកដី លោកគិតថា លោកចង់ឲ្យម្នាក់ៗមានមួកពាក់ ចង់ឲ្យម្នាក់ៗមានស្បែកជើងមួយគូពាក់ ប៉ុន្តែសម្ភារៈទាំងពីរនេះទំហំមានតែមួយទេ ហើយទំហំតូច យកទៅប្រគល់ឲ្យអ្នកដែលទទួលក្បាលធំជើងធំ ដើម្បីទទួលមួក និងរបស់អង្គការឲ្យយកទៅពាក់លើក្បាលរបស់ខ្លួនបានទាល់តែខ្លួនចាំងក្បាលរបស់ខ្លួន

សិនបានពាក់មួកនោះត្រូវ ព្រោះមួកវាតូច។

[០៩:៥៣:៣៤]

ស្បែកជើងក៏ដូចគ្នាដែរ ស្បែកជើងតូច ជើងវាធំ ស៊ីកម៉េចនឹងត្រូវទាល់តែបង្ខំចិត្តចាំងជើងរបស់ខ្លួនដើម្បីទទួលយកស្បែកជើងមួយគូនោះស៊ីក។ អ៊ីចឹងទេខ្ញុំគិតថា នោះជាគំនិតតែមួយគត់គឺ អំណាចផ្ដាច់ការ អ្នកណាទាំងអស់ត្រូវតែធ្វើតាមទាំងអស់ ពិបាកវេទនាប៉ុនណា ព្រាត់ប្រាសកូនប្រពន្ធប៉ុនណា ទុក្ខសោកប៉ុនណា សុខចិត្តទៅទ្រាំអត់ទប់ទឹកភ្នែកកុំឲ្យហូរ។ ឃ្លានណាស់ក៏មិនប៊ានថា អូ៎! ឃ្លានណាស់ ក្ដីណាស់ក៏មិនប៊ានថា។ អូ៎!ក្ដៅណាស់ ត្រជាក់ណាស់ក៏មិនប៊ានថា ត្រជាក់ណាស់។ ដូច្នេះទាំងអស់គ្នាស្លោកៗទាំងអស់ វាបដូចកន្ទេល។ នេះជាគំនិតខ្ញុំបាទសង្កេតឃើញ ហើយធ្វើការកត់សម្គាល់យ៉ាងដូច្នេះ។

[០៩:៥៤:៣៤]

ហើយមួយទៀត ខ្ញុំគិតថា ទិសស្លោកដែលអង្គការបានលើកឡើងកាលនោះ ខ្ពស់ហួសហេតុពេក អង្គការមហាអស្ចារ្យ។ មហាអស្ចារ្យអីបើទាំងអស់គ្នារក -- បងប្អូនទាំងអស់ដែលមកធ្វើសក្ខីកម្មនៅទីនេះឃើញតែការបំផ្លិចបំផ្លាញ ស្លាប់ជីវិតបាត់បងគ្រួសារ អស្ចារ្យៗក្នុងការពិឃាត ក្នុងការកម្ទេច។ នេះជាគំនិតរបស់ខ្ញុំយល់ ហើយលោតផ្លោះហ្នឹងមិនដឹងលោតផ្លោះយ៉ាងម៉េច ហើយអង្គការភ្នែកម្នាស់ភ្នែកម្នាស់យ៉ាម៉េច បើអស់លោកជាពិសេសមេដឹកនាំខ្មែរក្រហមទាំងពីររូប លោកបានមានប្រសាសន៍អម្បាញ់រួចហើយ លោកបានសារភាពថាលោកមិនបានទទួលដឹងឮអំពីភារកិច្ចខ្លះទៀតដែលមិនមែនជាភារកិច្ចរបស់អស់លោក ខ្ញុំបានជឿជាក់ថាអ៊ីចឹងមែនចុះ។ ប៉ុន្តែយើងគួរកត់សម្គាល់ថា ជារឿងមួយដែលយើងគិតថា យើងធ្វើឲ្យស្រុករីកចម្រើន ប៉ុន្តែផ្ទុយទៅវិញស្រុកយើងត្រូវបានលិចលង់ តើវាលិចលង់ដោយសារអ្វី? វាមានរឿងដែលធ្វើស្រុកលិចលង់នោះ? តើវាបណ្ដាលមកពីអ្វី?

[០៩:៥៥:៤០]

បើយើងមើលឃើញផ្ទាល់នឹងភ្នែក ឃើញតែការវិនាសហិនហោចគ្រប់បែបយ៉ាងទាំងអស់ វាអត់សម។ បញ្ញាជនជាមូលដ្ឋានគ្រឹះសម្រាប់បន្តធនធានមនុស្សទៅជំនាន់មួយៗ។ គ្រឿងក្បូនខ្នាតអ្វីៗផ្សេងៗ។ ចុះអស់ទាំងអស់បាត់អស់រលីង ដល់អ៊ីចឹងទេយើងមានការសោកស្ដាយ ទាំងអស់គ្នារួមសោកស្ដាយ។ ហើយខ្ញុំបាទចុងក្រោយ ខ្ញុំបាទគ្រាន់តែធ្វើការកត់សម្គាល់ប៉ុណ្ណេះ គឺចំពោះលោក ខៀវ សំផន។ នៅក្នុងទសវត្សរ៍៦០ ខ្ញុំបាទតែងតែឮ ឃើញសារព័ត៌មានផ្សេងៗ ឃើញគេនិយាយពីមួយទៅមួយថា

លោកមានភាពស្អាតស្អំ មិនបានពុករលួយ អីគ្រប់បែបយ៉ាងទាំងអស់លោកស្អាតស្អំ លោកគិតពីរឿងជាតិ។ ប៉ុន្តែវាអកុសលអី ពេលនោះលោកអញ្ជើញទៅចូលរួមក្នុងត្រកជាមួយនឹងត្រីស្អុយ នៅក្នុងត្រកជាមួយត្រីស្អុយ។ ត្រកហ្នឹងគឺទ្រុង។ ហើយធម្មតាខ្មែរយើងត្រីមួយត្រកស្អុយតែមួយស្អុយទាំងអស់។ នោះខ្ញុំបាទសូមរួមសោកស្តាយផង ប៉ុន្តែការពិតមានត្រីខ្លះមិនស្អុយទេ ប៉ុន្តែវានៅក្នុងត្រកជាមួយនឹងត្រីស្អុយ។ ខ្ញុំបាទចូលរួមសោកស្តាយកន្លែងហ្នឹងមួយផង។ អានេះជាគំនិតរបស់ខ្ញុំបាទ ហើយខ្ញុំបាទសង្ឃឹមថា ចុងក្រោយអង្គតុលាការនឹងខិតខំព្យាយាមធ្វើម៉េច យោងឯកសារផ្សេងៗ យោងសក្ខីកម្មរបស់សាមីខ្លួនម្នាក់ៗ និងបន្តបន្ទាប់ទៅទៀតនឹងរកយុត្តិធម៌ជូនទាំងអស់គ្នា សម្រាប់ជនរងគ្រោះ អ្នកបាត់បង់ជីវិត អ្នកដែលនៅសល់ជីវិត សម្រាប់ប្រជាពលរដ្ឋទូទៅ សម្រាប់អ្នកនៅក្រៅប្រទេស សម្រាប់ក៏សាមីខ្លួនមេដឹកនាំកម្ពុជាប្រជាធិបតេយ្យផងដែរ នោះជាយុត្តិធម៌សម្រាប់ទាំងអស់។ ហើយខ្ញុំបាទសង្ឃឹមថា អង្គតុលការនឹងសម្រេចជោគជ័យនៅក្នុងទីបញ្ចប់។

ខ្ញុំបាទសូមថ្លែងអំណរគុណ ខ្ញុំបាទមានគំនិតតែប៉ុណ្ណេះ សូមអរគុណ។

[០៩:៥៧:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នូវ ហ៊ាន់។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ ហើយក៏សូមជម្រាបសួរលោក នូវ ហ៊ាន់ ផងដែរបាទ លោក នូវ ហ៊ាន់ ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញាជាមួយសហការីរបស់ខ្ញុំ ហើយខ្ញុំមានសំណួរមួយចំនួនតូច ចង់ឲ្យលោកជួយបញ្ជាក់អំពីព្រឹត្តិការណ៍ដែលបាន -- ដែលលោកបានជួបប្រទះកន្លងមក។

[០៩:៥៨:៣៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សំណួរជាដំបូងរបស់ខ្ញុំនោះ ចង់ដឹងអំពីការធ្វើដំណើរដែលលោកបានជម្រាបជូនអង្គសវនាការមុននេះបន្តិចហ្នឹងថា លោកបានធ្វើដំណើរចេញពីភ្នំពេញទៅខេត្តព្រៃវែង ដែលជាស្រុកកំណើត

របស់លោក។ ខ្ញុំចង់ដឹងថាតើនៅពេលដែលលោកធ្វើដំណើរចេញពីភ្នំពេញទៅព្រៃវែងនោះ ពេលនោះមានគេមកប្រាប់លោកថាត្រូវទៅខាងណាដែរទេពេលនុ៎ង?

**លោក នូវ ហ៊ាន់៖**

**ឆ៖** អង្គតុលាការ សូមជម្រាបលោកមេធាវី។ តាមពិតខ្ញុំបាទសូមជម្រាបកន្លែងនេះថា ពេលនោះគឺក្រុមគ្រួសារខ្ញុំបាទ គឺតាមផ្លូវលេខ១ យើងបានសួរដែរ សួរទៅខាងអង្គការ សួរទៅខាងយោធាថាតើឲ្យពួកខ្ញុំទៅណា? ថាចេះតែទៅ! តាមផ្លូវណាអង្គការចង្អុលចេះតែទៅៗ! កន្លែងណាដែលអង្គការឲ្យឈប់នៅកន្លែងនុ៎ងទៅ។

[០៩:៥៩:៤១]

ពេលហ្នឹងគឺធ្វើដំណើរទៅ ទៅដល់រយៈពេល១ខែ ទម្រាំទៅដល់ ចេះតែផ្អាកចាំៗ អ្នកខ្លះថាលោក ខៀវ សំផន គាត់អញ្ជើញមក គាត់នឹងរៀបចំស្រុកទេស គាត់នឹងប្រមូលបងប្អូនយើងចូលភ្នំពេញវិញ អីអីចឹង។ ហើយអ្នកខ្លះមានបងប្អូនកូនចៅត្រូវឆ្លងទន្លេ ម្ល៉ោះហើយតែផ្អាកៗ តាមផ្លូវជាតិលេខ១អីចឹងទៅ ហើយគ្រួសារខ្ញុំបាទទៅដល់អ្នកលឿងហ្នឹង ត្រូវនៅអ្នកលឿងត្រើយខាងលិចហ្នឹងចំនួនរយៈពេលមួយអាទិត្យ អស់ស្បៀង គ្មានអង្ករមួយគ្រាប់។ កូន កាលណោះបាត់មួយនៅសល់តែប្រាំពីរទេ។ អីចឹងទេ ពិបាកណាស់។ ប៉ុន្តែទន្ទឹមនឹងមានបងប្អូនខ្មែរក្រហមពីរនាក់ គាត់ខាងយោធា គាត់ទទួលបន្ទុកមើលរថយន្តទាំងឡាយដែលអង្គការមិនឲ្យឆ្លងសាឡាងទៅត្រើយម្ខាងនោះ គឺទុកចតពេញនៅត្រើយខាងលិចហ្នឹង។ គាត់មើលខាងសម្ភារៈ ខាងរថយន្តហ្នឹងឯង។ ដល់គាត់ឃើញគ្រួសារខ្ញុំបាទពិបាកអីចឹងគាត់បានដាំបាយ គាត់មានត្រីងៀត មានត្រីឆ្អើរអី ដួសបាយដាក់ឲ្យកូនខ្ញុំអី--

**ស៖** អីចេះលោក នូវ ហ៊ាន់ ខ្ញុំសុំអភ័យទោសដែលកាត់លោក។ ការឆ្លើយរបស់លោកគឺបានចំនឹងសំណួរខ្ញុំរួចហើយ។ ហើយអីចឹងដើម្បីកុំឲ្យខាតពេលវេលាយូរ ខ្ញុំសូមកាត់លោកត្រឹមនេះ ហើយខ្ញុំសូមបន្តសំណួរមួយទៀត។ តាមអ្វីដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញ គឺតើមានទាហានខ្មែរក្រហមបានអមដំណើរជាមួយអ្នកជម្លៀស ជាពិសេសជាមួយក្រុមគ្រួសាររបស់លោកដែរនោះ តើមានទាហានខាងខ្មែរក្រហមហ្នឹង គាត់បានអមដំណើរទៅជាមួយអីចឹងមែនដែរឬទេ?

[១០:០១:២៣]

**ឆ៖** ការពិត គឺអត់មានទេ គឺថាគ្រួសារណាទៅតាមយកថាកម្មរៀងខ្លួនៗ គឺអត់មានរឿង។ គឺភារកិច្ចរបស់ខ្មែរក្រហម គឺមានផ្សេង ភារកិច្ចគេផ្សេងៗ យើងមិនបានយល់ទេបាទ។

**ស៖** បាទ អរគុណ។ ចុះលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា លោកបានឃើញទាហានខ្មែរក្រហមដែលនៅតាមផ្លូវដែលលោកធ្វើដំណើរហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺដូច្នេះមែន។

**ស៖** បាទអរគុណ។ ចុះមួយទៀត ទាក់ទងទៅនឹងការធ្វើដំណើរតាមផ្លូវហ្នឹង តើលោកបានឃើញស្ថានភាពអ្នកដែលធ្វើដំណើរហ្នឹងយ៉ាងម៉េចខ្លះ? ហើយលោកឃើញមានដូចជាអ្នកស្លាប់ អ្នករបួសអីដែរទេ?

**ឆ៖** យើងឃើញមានបងប្អូនខ្លះស្លាប់ហើម។ អាហ្នឹងគឺមិនដឹងជាស្លាប់ពីថ្ងៃណា ម៉ោងណាអីថ្ងៃណា យើងមិនដឹងថាស្លាប់ដោយសារអី គឺយើងមិនដឹងទេ។ ប៉ុន្តែភាពច្របូកច្របល់នៅតាមផ្លូវជាតិលេខ១ហ្នឹង គឺណែនណាន់តាន់តាប់ហើយ គឺច្របូកច្របល់មិនដឹងជាអ្នកណាៗទេ អ្នកខ្លះបកចុះ បកឡើងដែលកូនបាត់ គ្រួសារបាត់។ ជាពិសេសដូចខ្ញុំបានជម្រាបខាងដើមរួចហើយ។ ជាពិសេសទាក់ទងរកស្បៀងសម្រាប់គ្រួសារ។ ហើយទម្រាំតែទៅដល់អ្នកលឿងហ្នឹង គឺខ្មែរក្រហមគេមិនឲ្យឆ្លងអ្នកដែលមានរថយន្តដាក់សម្ភារៈទៅហ្នឹង គេអត់ឲ្យឆ្លងទេ គេឲ្យទុករថយន្តនៅអ្នកលឿងត្រើយខាងលិច។ វេចតែសម្ពាយ យកតែសម្ពាយនឹងខ្លួន ឆ្លងតាមសាឡាងទៅត្រើយម្ខាងខាងណោះ។ ប៉ុណ្ណោះគ្រួសារខ្ញុំបាទហ្នឹងគឺបាននៅហ្នឹង ហើយដែលខ្មែរក្រហមពីរនាក់ហ្នឹងគាត់បានជួយជូនអីវ៉ាន់អីហ្នឹង គាត់បានផ្តល់អង្ករកន្លះតៅ អង្ករសំរូបកាលណោះ។ ឲ្យឆ្លងទៅដើម្បីទៅស្រុកកំណើត។

[១០:០៣:១៨]

**ស៖** បាទអរគុណលោក។ នៅពេលដែលធ្វើដំណើរតាមផ្លូវនុ៎ង តើមាននរណា មានក្រុមគ្រួសារណា ឬក៏អ្នកណាម្នាក់មានបំណងវិលត្រឡប់មកភ្នំពេញដែរទេ ហើយកាលដែល បើសិនជាមានតើគេអនុញ្ញាតឲ្យមកដែរឬទេ?

**ឆ៖** កាលណោះតាំងពីតំបន់ច្បាអំពៅ ទៅដល់វត្តនិរោធ ទៅដល់វត្តចំប៉ាអីតាមផ្លូវរហូតគេដាក់ក្តារខៀន ហើយគេសរសេរផ្សព្វផ្សាយព័ត៌មានថា បងប្អូនមានបណ្ឌាស័ក្តិ ជាពិសេសនាយទាហានឬក៏អ្នករដ្ឋការអីហ្នឹង សូមឲ្យចុះឈ្មោះ អង្គការត្រូវការឲ្យចូលទៅភ្នំពេញដើម្បីបម្រើការងាររៀបចំស្រុកយើងឡើងវិញសាជាថ្មី។ ដឹងទេ បងប្អូនមួយចំនួននោះគាត់សប្បាយចិត្ត គាត់គិតថាគាត់នឹងបានវិលត្រឡប់ទៅភ្នំពេញវិញ។ គាត់នាំគ្នាទៅចុះឈ្មោះបន្តបន្ទាប់នេះទៅ។ ប៉ុន្តែរូបខ្ញុំបាទផ្ទាល់ ខ្ញុំគិតថាមិនមែនទេ នៅខាងមុខយើងគឺសេចក្តីស្លាប់ហើយ។ អ៊ីចឹងទេ ខ្ញុំឃើញតែប៉ុណ្ណឹង ទិដ្ឋភាពប៉ុណ្ណឹងបាទ។

**សៈ** បាទអរគុណ។ តើលោកពិនិត្យឃើញយ៉ាងណា បានលោកគិតថាការទៅចុះឈ្មោះ ដើម្បីវិលត្រឡប់មកជួយខាងខ្មែរក្រហមវិញជាសេចក្តីស្លាប់? លោកយល់ឃើញ ឬក៏ពិនិត្យឃើញយ៉ាងម៉េចខ្លះនៅពេលនុ៎ង?

[១០:០៤:៥៨]

**ឆៈ** ខ្ញុំបាទសូមជម្រាបបញ្ជាក់បន្ថែមបន្តិចកន្លែងហ្នឹង។ កាលនោះច្បាប់នៅក្នុងប្រទេសកម្ពុជាក៏តឹងតែងដែរ អំពីឯកសារផ្សេងៗ ជាពិសេសឯកសារកុម្មុយនីស្ត។ ប៉ុន្តែខ្ញុំបាទតែងឆ្លៀតរកឯកសារកុម្មុនីស្តនោះមកមើល។ មើលក៏ដឹងពីរបៀបរបបកុម្មុយនីស្តនេះៗយ៉ាងម៉េច តឹងតែងយ៉ាងម៉េច លត់ពត់លត់ដំយ៉ាងម៉េច? អ៊ីចឹងទេគិតថាដំណើរយើងទាំងអស់គ្នាមិនល្អទេ មិនមែនសម្រាប់មកជួយកសាងជាតិទេ។ ឃើញជាក់ស្តែងនៅហ្នឹងមុខ កងទ័ពខ្មែរក្រហមខ្លះស្លៀកជាឯកសណ្ឋាន អ្នកខ្លះស្លៀកជាស៊ីវិល ហើយគាត់ដើរពិនិត្យមើលកែងជើង កែងជើងអ្នកដើរនៅតាមផ្លូវមុខគាត់ កែងជើងណារៀងក្រិនហ្នឹងគាត់កេះហើយ គាត់ថានេះជាទាហាន លន់ នល់ ហើយ គាត់កេះយកទៅបាត់ហើយ។

អ៊ីចឹងទេ យើងកត់សម្គាល់ថា គ្រោះថ្នាក់ណាស់សម័យហ្នឹង គឺថាពេលហ្នឹង ពេលចេញហ្នឹងគ្រោះថ្នាក់ហើយ ពេលទៅមុខទៀតនឹងគ្រោះថ្នាក់ទៀត ដូច្នេះយើងត្រូវប្រុងប្រយ័ត្នខ្លួនយើងមួយ។ ខ្លួនខ្ញុំផ្ទាល់បានប្រាប់ដល់កូនខ្លួនឯងទៀតថា កូនពីថ្ងៃហ្នឹងទៅ ពីពេលហ្នឹងទៅកូនឯងឈប់ហៅប៉ា ហៅម៉ាក់ព្រោះស្រុកគេដូរហើយ គេដូររបៀបរបបហើយ ហៅពុក ហៅម៉ែ។ ហើយជាកុសលល្អសម្រាប់ខ្ញុំ កូនខ្ញុំទាំងអស់ចាប់ពីថ្ងៃដែលខ្ញុំបានប្រាប់មិនដែលកូនណាមួយហៅថា ប៉ា ហៅថាម៉ាក់ ទេ ហៅតែ ពុក ហៅតែម៉ែ។ ដូច្នេះកន្លែងហ្នឹងមួយខ្ញុំដែលអាចចូលចុះនៅក្នុងការបត់បែននៃជំនាន់នោះ។

[១០:០៦:២៦]

**សៈ** បាទ អរគុណ។ លោកបានជម្រាបថាមានការកេះ ដែលសង្ស័យថាទាហាន លន់ នល់ តើលោកដឹងទេថាកេះហ្នឹង គេកេះយកទៅណា? លោកបានដឹងទេនៅពេលនោះ?

**ឆៈ** យើងកាលណោះ យើងមានមនុស្សច្រើន ដូច្នេះមានទីជម្រកជិតៗគ្នា អ្នកខ្លះបងប្អូនរាយជាជម្រកជិតយើង គាត់ដើរទៅបត់ជើង ឬមួយគាត់ធ្វើដំណើរទៅរកស្បៀងអីគាត់ជួបព្រឹត្តិការណ៍អស់ហ្នឹងគេយកទៅ គេដឹកឡានទៅ គេយកទៅសម្លាប់កន្លែងណាមួយ។ ខ្សឹបប្រាប់គ្នាថា អត់ស្រួលទេ អត់ស្រួលទេ គេយកទៅសម្លាប់ ដឹងតាមរយៈគ្នាអ៊ីចឹង ដូចអ្នកនៅជិតជំរំក្បែរៗគ្នាហ្នឹងគេនិយាយ។

**សៈ** បាទ អរគុណ។ មុននេះបន្តិចដែរលោកបានជម្រាបជូនអង្គសវនាការថា លោកចេះតែខំ

ប្រឹងធ្វើដំណើរតាមផ្លូវទៅ ព្រោះអីមានឮថា លោក ខៀវ សំផន នឹងមក។ តើលោកឮហ្នឹងឮនៅកន្លែងណាដែរ?

**ឆ៖** គឺកាលណោះខ្ញុំបាទ ក្រុមគ្រួសាររបស់ខ្ញុំបាទហ្នឹងសំចតនៅម្តុំវត្តចំប៉ាជាមួយនឹងសាច់សាលោហិតខ្លះនៅខេត្តព្រៃវែង រាប់ទៅជាង១១គ្រួសារ ហើយគាត់ហ្នឹងបានស្គាល់ច្បាស់ខាងលោក ខៀវ សំផន អ៊ីចេះ។ គាត់បានមានប្រសាសន៍ថាអ៊ីចឹង យើងរង់ចាំទៅលោក ខៀវ សំផន នឹងមកនឹងរៀបចំស្រុកទេស គាត់អាចនឹងហៅពួកមន្ត្រីរដ្ឋការចាស់ហ្នឹងឲ្យទៅចូលជួយកសាងប្រទេសឡើងវិញអ៊ីចឹង។ ហើយកូនគាត់ផ្ទាល់នោះ ក៏ត្រូវសម្រាលកូនទៀត ហើយប្តីអត់នៅទេ ប្តីអង្កាល់ណោះធ្វើទាហាន គេឲ្យទៅរៀននៅកំពង់ឆ្នាំង។ ដូច្នេះ ខ្ញុំបាទបានឮនៅពេលរយៈពេលនុំងឯងជាពេលដែលយើងជម្លៀសចេញនុំងឯង។

[១០:០៨:១៧]

**ស៖** បាទ អរគុណ ខ្ញុំមានសំណួរប្រហែលជាមួយទៀត។ ចង់ដឹងអំពីនៅពេលដែលលោកទៅដល់ស្រុកកំណើតរបស់លោកនៅឯព្រៃវែង នៅពេលដែលលោកទៅដល់នុំង តើមានគេចាត់ចែងឲ្យលោកចូលទៅក្រុមណា ឬក៏ទៅសហករណ៍ណាដែរទេនៅពេលនុំង?

**ឆ៖** ពេលទៅដល់ភូមិកំណើតមានខាងខ្មែរក្រហម បងប្អូនខាងខ្មែរក្រហមហ្នឹង គេមកធ្វើការឆែកឆេរទ្រព្យសម្បត្តិយើង ដូចថាសម្ភារយើងមានប៉ុន្មានត្រូវបើកចំហទាំងអស់ ដើម្បីឲ្យតំណាងឲ្យអង្គការហ្នឹង គាត់មើលថាយើងមានស្អីខ្លះដែលថាមានគ្រឿងប្រដាប់ពេទ្យ មានជាសឺរ៉ាំង មានជាម្ជុលអីហ្នឹងគេដកហើយ ប្រដាប់វាស់ឈាម ប្រដាប់ស្អីហ្នឹង គេដកយកអស់ហើយ គេមិនទុកឲ្យយើងទេ។ បើអាចសល់ៗតែថ្នាំពេទ្យអាចសល់ខ្លះ ហើយគេពេលហ្នឹងគេឆែកឆេរអស់។ ហើយទៅ ខ្ញុំបាទនៅភូមិកំណើតបានតែមួយអាទិត្យទេ ពីព្រោះភូមិនោះជាភូមិថ្មី។ ពេលរំដោះភ្លាម អ្នកដែលនៅសល់នៅភូមិកំណើតហ្នឹងគេក៏បានវិលមកចូលវិញ អ្នកភ្នំពេញក៏វិលទៅវិញ ទៅជួបគ្នានៅភូមិថ្មី ម្ល៉ោះហើយអត់មានផលិតកម្មជាស្រូវអង្ករអីបានទេ។ គេក៏កត់គ្រួសារទាំងអស់ហ្នឹង ៣២គ្រួសារ បញ្ជូនទៅភូមិមួយទៀតនៅក្បែរនោះ ប្រហែលជា ៣គីឡូ។ ហើយអ៊ីចឹងគ្រួសារខ្ញុំបាទមានឈ្មោះថានៅភូមិមួយទៀត ប្រហែល ៣គីឡូពីភូមិកំណើត។

[១០:០៩:៥០]

ហើយទន្ទឹមនឹងនោះប្រហែលជាមួយអាទិត្យក្រោយមក នៅក្នុងប្រហែលជាខែឧសភា ខ្ញុំបាទ

មិនចាំថ្ងៃ ក៏មានឈ្មោះអង្គការហៅទៅរៀនសូត្រនៅមន្ទីរសន្តិសុខស្រុកព្រះស្តេច មានឈ្មោះទៅៗរៀនសូត្រ។ នៅពេលនោះមានឈ្មោះទៅគ្នាបួននាក់ រូបខ្ញុំបាទ នួវ ហ៊ាន់, ហើយពូខ្ញុំបាទម្នាក់ ជា ជាង គាត់ជាវិស្វករ កសិកម្ម ហើយប្អូនគាត់ម្នាក់ទៀត ពូរិន គាត់ជាអនុសេនីយ៍ត្រីខាងភស្តុភារខាងសាំងនៅព្រែកព្នៅ ហើយមានម្នាក់ទៀតគាត់ជាកងអាវុធហត្ថ។ ហើយពួកពូដែលអនុសេនីយ៍ត្រីហើយខាងអាវុធហត្ថហ្នឹង ទៅបានតែមួយយប់ទេ យប់ហ្នឹងគឺអង្គការយកទៅបាត់ហើយៗមិនដឹងជាយកទៅណាទេ នៅសល់តែរូបខ្ញុំបាទ ហើយនិងពូ ជា ជាង ដែលជាវិស្វករកសិកម្មហ្នឹងទេ។ ហើយខ្ញុំបាទទៅដល់--ពេលទៅរៀនសូត្រ ហ្នឹងខំដាក់មានថ្នាំពេទ្យអីខ្លះទៅ មានប៊ិកមានសៀវភៅ ពួកបងប្អូនអ្នកស្រុកគេថា អូយ! ធំអើយមិនបាច់ យកទៅទេ របស់អស់ហ្នឹងអង្គការមានគ្រប់គ្រាន់អស់ហើយកុំភ័យអីរឿងថ្នាំសង្កូវ យើងក៏ជឿគាត់ទៅ។ ដល់ទៅដល់ឃើញផ្ទះមួយបីខ្ទងមនុស្សប្រហែលជា បីរយប្លាយនាក់ ទាហានអ្នកលឿង ទាហានស្ទឹងស្លូត ដែលបែកមុននោះដាក់ខាងក្រោមពេញ ដាក់ខ្នោះជាប់ជើងគ្នាខាងលើអត់ដាក់ខ្នោះទេ គឺណែនទាំងអស់ ហើយសង្កើចនោះមហាសង្កើច។ ខ្ញុំបាទជាប់ឈ្មោះត្រូវទៅរៀនសូត្រហ្នឹង ហើយរៀនសូត្រហ្នឹងគឺទៅជាប់នៅមន្ទីរឃុំឃាំង បានបងប្អូនខ្លះគាត់ថា គុកតតជញ្ជាំង។ ការពិតគឺមែនអត់ជញ្ជាំងមែន។ វេទនាណាស់គេងផ្ទាល់ដីកាប់ជញ្ជ្រាំងមកទ្រាប់ខ្នង។ ភ្លៀងឡើងក្រោកអង្គុយអោបក្បាលជង្គង់ទាំងអស់គ្នា បន់ឲ្យភ្លៀងឆាប់រាំង។ ហើយគ្មានអីទទួលទានទេ មានតែពោតក្រហមស្ងោរអត់កំបោរ បាយមួយគោម ដល់បបរមួយគោម គ្មានអ្វីទាំងអស់។ សម្លគឺថាមានតែអំបិលអង្ករមួយកំប៉ុង មួយចាវ មានត្រកួន ខ្លះទៅ មានផ្កាកំប្លោកខ្លះទៅ។ ដូច្នេះវាគ្មានសារជាតិអីបំប៉នសុខភាពរបស់យើងម្នាក់ៗទេ។ ម្នាក់ៗស្គម រង់ចាំតែសេចក្តីស្លាប់ទេ។ វេទនាណាស់នៅពេលនោះ។

[១០:១១:៥៧]

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធានខ្ញុំអស់សំណួរហើយ។ ហើយក៏សូមអរគុណដល់លោក នួវ ហ៊ាន់ ផងដែរដែលបានចំណាយពេលវេលាដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើងនេះ ដើម្បីចូលរួមចំណែកក្នុងការស្វែងរកការពិត និងយុត្តិធម៌ជូនដល់ទាំងជនរងគ្រោះ ក៏ដូចជាជនជាប់ចោទដូចដែលលោកបានមានប្រសាសន៍ព្រឹកមិញអ៊ីចឹងដែរ។ អ៊ីចឹងខ្ញុំសូមអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[១០:១២:៣៨]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមគោរពអង្គសវនាការ សូមគោរពក្រុមប្រឹក្សា និងសូមគោរពលោកប្រធាន។ ខ្ញុំសូមជម្រាបសួរលោក នូវ ហ៊ាន់។ ខ្ញុំឈ្មោះ សុន អរុណ មេធាវីការពារលោក នួន ជា។ ខ្ញុំមានសំណួរពីរបីទេ សួរព្រឹក នេះ។ ទី១ ខ្ញុំសួរថាលោក នូវ ហ៊ាន់ កាលពីនៅសិក្សាបានរៀនដល់កម្រិតណាថ្នាក់ណា?

**លោក នូវ ហ៊ាន់៖**

**ឆ៖** កាលនោះនៅក្នុងឆ្នាំ១៩៥៣ ខ្ញុំបានប្រលងជាប់វិញ្ញាបនប័ត្របឋមសិក្សានៅខេត្តព្រៃវែង ហើយបន្តការសិក្សារៀនសូត្រនៅអនុវិទ្យាព្រះសុរិយោវង្សស្វាយរៀងរយៈពេល៤ឆ្នាំ ហើយក៏បានបញ្ចប់ការសិក្សាទៅ ទៅប្រលងចូលបម្រើការងារនៅក្នុងក្រសួងសុខាភិបាល។

**ស៖** ពេលដែលលោកបម្រើការងារនៅក្នុងក្រសួងសុខាភិបាលពីឆ្នាំណាដល់ឆ្នាំណា? ហើយលោកមានមុខងារជាអ្វីក្នុងក្រសួងសុខាភិបាល?

**ឆ៖** ពីចុងឆ្នាំ១៩៥៨ រហូតដល់ឆ្នាំ១៩៧៥ ហើយមានទីកន្លែងធ្វើការផ្សេងៗគ្នា។ ទី១ គឺក្រុមកម្ចាត់ជំងឺរបេងដូចដើរបានខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តកណ្តាល បួនខេត្ត។ បន្ទាប់មកទៀតបានផ្ទេរទៅក្រុមកម្ចាត់ជំងឺគ្រុនចាញ់បានចុះទៅធ្វើការនៅក្នុងខេត្តកំពង់ធំ កាលនោះមិនទាន់បំបែកទៅជាខេត្តព្រះវិហារទេ ធ្វើនៅក្នុងខេត្តកំពង់ធំ ហើយពេលចប់បេសកកម្មកំពង់ធំទៅជួយខាងខេត្តកំពង់ចាមនៅក្នុងស្រុកត្បូងឃ្មុំ។ បន្ទាប់មកទៀតផ្ទេរទៅធ្វើការនៅក្រសួងមួយទៀត ក្រុមមួយទៀតហៅថាក្រុមកម្ចាត់ដំបៅងារ មានភារកិច្ចចុះតាមភូមិស្រុកនៅតាមព្រំប្រទល់ដែនឡាវ ព្រំប្រទល់ដែនថៃចាក់ថ្នាំការពារដំបៅងារ បណ្តុះ -- ចែកថ្នាំផ្សេងៗ--

[១០:១៥:១២]

**ស៖** សូមគាត់លោក ខ្ញុំមិនចង់បានចម្លើយវែងទេ គ្រាន់ចង់ដឹងមុខងាររបស់លោកធ្វើសុខាភិបាល មុខងារធ្វើអ្វីប៉ុណ្ណឹងទេ ប៉ុន្តែលោកឆ្លើយរួចទៅហើយ។ ខ្ញុំសូមបន្តសំណួររបស់ខ្ញុំ ដើម្បីចំណេញពេល។

ពេលដែលមុនជម្លៀសខ្លួនចេញពីភ្នំពេញ ដំណាក់កាលទី១ លោកបានទៅស្នាក់-- អំមិញលោកបានជម្រាបទៅខាងព្រះរាជអាជ្ញារួចហើយ ទៅនៅខាងស្រុកព្រះស្ដេចខេត្តព្រៃវែង។ អ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** បាទ គឺពិតប្រាកដអ៊ីចឹងមែន។

[១០:១៦:០០]

**ស៖** មុននឹងលោកបានជម្លៀសពីភ្នំពេញ មុនឆ្នាំមួយពាន់ -- ថ្ងៃ១៧ មេសា ១៩៧៥ (*ស៊ិក*) ពេលនុំងដល់ថ្ងៃ១៧ មេសា ឆ្នាំ៧៥ (*ស៊ិក*) ពេលហ្នឹងខ្មែរក្រហមចូលភ្នំពេញ តើលោកឃើញសភាពការណ៍នៅភ្នំពេញហ្នឹងមានសភាពបែបម៉េចសូមលោកជម្រាបតុលាការយ៉ាងខ្លីកុំវែងពេក។

**ឆ៖** ដូចខ្ញុំបានជម្រាបអង្គតុលាការរួចមកហើយថា សភាពការណ៍កាលនោះវាមនុស្សច្រើនណាស់ មនុស្សរាប់ដល់លាននាក់ឯណោះ វាច្របូកច្របល់គ្នាណាស់។ ពីជើងទៅត្បូង ពីត្បូងទៅជើង ពីកើតទៅលិច ខ្វាត់ខ្វែងគ្នា ប៉ុន្តែទន្ទឹមនឹងនោះក៏មានកម្លាំងខ្មែរក្រហមនៅតាម គាត់ឲ្យសញ្ញាថា ទៅផ្លូវណាអីផ្លូវណាខ្វាត់ខ្វែង អ្នកណាខ្វល់ចិត្តហ្នឹងសម្ភារៈយកទៅមានស្អីៗខ្លះ មានម្ហូបអាហារ មានអង្ករស្លឹកគ្រៃអី ខ្លះកូននៅអីណា ប្ដីនៅឯណា ដូចច្របូកប្របល់ គឺថាជ្រួលច្របល់ទាំងអស់តែម្ដង ធ្វើឲ្យស្ថានភាពស្រុកទេអង្កាល់នុំង គឺជ្រួលច្របល់ជាទីបំផុត។

**ស៖** ខ្ញុំអរគុណ។ ខ្ញុំចង់សួរពីរឿងសភាពការណ៍ ម្យ៉ាងទៀតពេលដែលទ័ពខ្មែរក្រហមចូលក្រុងភ្នំពេញ លោកឃើញទ័ពខ្មែរក្រហមហ្នឹងមានសម្លៀកបំពាក់ ប្រដាប់ប្រដាជាយោធាហ្នឹងរបៀបណា? ហើយមានប៉ុន្មានយ៉ាង? ប៉ុន្មានធុន?

[១០:១៧:៣៥]

**ឆ៖** ចំពោះខ្ញុំបាទដែលបានឃើញ គឺមានតែមួយធុនទេ គឺសម្លៀកបំពាក់ខោខ្មៅ អាវខ្មៅ ស្បែកជើងកង់ឡាន និងមួកកន្ដិប ហើយនិងជាពិសេស គឺកាំភ្លើងអាកា។ មានតែប៉ុណ្ណឹងទេដែលខ្ញុំបាទបានជួបប្រទះ។

**ស៖** អរគុណ។ បន្ទាប់ពីដំណាក់កាលទី១ ដែលលោកបានជម្លៀសទៅនៅស្រុកព្រះស្ដេច ខេត្តព្រៃវែងហើយ បន្តពីហ្នឹងទៀតទៅ តើមាន -- ខ្មែរក្រហមមានជម្លៀសលោកទៅណាទៀតទេ?

**ឆ៖** ខ្ញុំបាទ អត់បានមានជម្លៀសទៅកន្លែងណាផ្សេង គឺនៅសហករណ៍ដដែលហ្នឹង ហើយអត់បានជម្លៀសទៅកន្លែងណាផ្សេងទៀតទេ។

**ស៖** សូមអរគុណ។ ពីព្រឹកមិញលោកបានជម្រាបតុលាការថា ក្នុងគ្រួសាររបស់លោក គ្រួសារ

ផ្ទាល់របស់លោកហ្នឹង លោកបានមានកូនស្រីម្នាក់អាយុប្រហែល១០ ទៅ -- ប្រាំបួន ទៅ១០ឆ្នាំបាន ស្លាប់។ តើកូនស្រីរបស់លោកហ្នឹងស្លាប់នៅពេលណា? ហើយនៅកន្លែងណា?

**ឆ៖** ដូចខ្ញុំបានជម្រាបអង្គតុលាការមុននេះហើយថា ស្លាប់នៅក្នុងទឹកដីខេត្តកំពង់ស្ពឺ ប៉ុន្តែនៅថ្ងៃណា ខែណា ឆ្នាំណា គឺខ្ញុំបាទមិនបានចាំទេ ពីព្រោះព័ត៌មាននេះផ្តល់ដោយស្ត្រីម្នាក់មកម្តាយចិញ្ចឹមភរិយាខ្ញុំបាទពេលធ្វើបុណ្យក្រោយ៧៩ នៅតំបន់ផ្សារអូរឫស្សី ប៉ុណ្ណឹងឯង។ មិនអាចចាំបានទីកន្លែងម៉ោងណា ថ្ងៃណា គឺមិនបានចាំទេ។

[១០:១៩:២៤]

**ស៖** បើដូច្នោះលោកបានបែកចេញពីកូនស្រីរបស់លោកមុននឹងនាងស្លាប់។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតប្រាកដអ៊ីចឹងមែន។

**ស៖** បើដូច្នេះលោកមិនដឹងថា នាងស្លាប់ដោយមូលហេតុអ្វីទេ? លោកបានដឹងទេ?

**ឆ៖** ខ្ញុំបាទបានបញ្ជាក់មុនរួចហើយថា ថាខ្ញុំបាទមិនបានដឹងវិធីសម្លាប់ដោយវិធីណាក៏មិនដឹងទេ គ្រាន់តែថាគេប្រមូលគ្រួសារហ្នឹងទាំងមូលទៅក្នុងពេលយប់ ថាយកទៅសម្លាប់នៅទីណា ដោយវិធីណា ខ្ញុំបាទមិនបានដឹងទេ។

**ស៖** សូមលោកជម្រាបតុលាការម្តងទៀត។ តើការដែលតាមព័ត៌មានដែលលោកដឹងថាកូនស្រីរបស់លោកស្លាប់ លោកដឹងដោយសារអ្នកណា? ហើយអ្នកនោះបានមកប្រាប់លោកថា កូនលោកស្លាប់ លោកអត់បានសួរបញ្ជាក់ថាស្លាប់របៀបវិធីណា? នៅកន្លែងណាទេ? មានបានសួរទេ?

**ឆ៖** ខ្ញុំបាទបានជម្រាបពីមុនរួចមកហើយថា ដំណឹងនេះដឹងដោយមនុស្សស្រីម្នាក់ គាត់នៅក្នុងសហករណ៍ជាមួយនឹងប្អូនថ្លៃ គ្រួសារប្អូនថ្លៃរបស់ខ្ញុំបាទហ្នឹង ហើយម្តាយចិញ្ចឹមរបស់ភរិយាខ្ញុំបាទ គាត់ទៅចូលរួមពេលបុណ្យហ្នឹង គាត់បានសួរ ហើយថាគាត់នៅក្នុងសហករណ៍ជាមួយគ្នានៅក្នុងទឹកដីខេត្តកំពង់ស្ពឺ ប៉ុន្តែដឹងនៅស្រុកណា ឃុំណា គឺមិនបានដឹងទេ ប៉ុន្តែនៅជាមួយនឹងគាត់ ជាមួយនឹងបងស្រីនោះដែលគាត់ថាស្គាល់ច្បាស់ ពេជ ចុងកាល់ ហ្នឹង។ ពេជ ចុងកាល់ គាត់ជាអតីតវិស្វករ ហើយជាអតីតប្រធានអគ្គនាយករោងចក្រជីផូស្វាតទូកមាស។

[១០:២១:២១]

អ៊ីចឹងទេ ខ្ញុំបាទមិនបានដឹងអីពិតប្រាកដផ្ទាល់មាត់ជាមួយនឹងបងស្រីហ្នឹងទេ គឺម្តាយចិញ្ចឹមរបស់ភរិយាខ្ញុំបាទទេដែលបានទទួលដំណឹងពីគាត់មក ហើយគាត់យកដំណឹងនេះមកប្រាប់ដល់ខ្ញុំបាទនិងភរិយា

ខ្ញុំបាទឲ្យបានដឹងថា មូលហេតុដែលស្លាប់ហ្នឹងគឺអ៊ីចឹង វាអត់មានវិលមកវិញទេ គឺគ្រួសារហ្នឹងគឺស្លាប់ទាំងអស់។ ហ្នឹងប៉ុណ្ណឹង។

**ស៖** អរគុណ។ ចុះចំពោះគ្រួសារប្អូនថ្លៃរបស់លោកបានស្លាប់ លោកបានជម្រាបតុលាការថាស្លាប់ទាំងអស់ក្នុងមួយគ្រួសារ។ តើអ្នកទាំងនោះស្លាប់នៅពេលណា? នៅកន្លែងណា? ហើយនិងស្លាប់ដោយមូលហេតុអ្វីដែរ?

**ឆ៖** មូលហេតុដែលស្លាប់ ដែលខ្ញុំបាទបានជម្រាបរួចហើយ ថាគ្រាន់តែថាពេលដែលប្អូនថ្លៃខ្ញុំបាទសុំច្បាប់នៅកន្លែងដែលគាត់បម្រើធ្វើការនុ៎ង ហើយមកមើលកូនឈឺ ហើយឃើញពេទ្យខ្មែរក្រហមឲ្យថ្នាំអាចម៍ទន្សាយ ហើយគាត់មានប្រសាសន៍ថា "អ៊ូ៎! កូនខ្ញុំអង្កាល់ជាទៅ បើឲ្យថ្នាំអាចម៍ទន្សាយអ៊ីចឹង"។

[១០:២២:៣៤]

ហើយអ៊ីចឹងទេ ដល់យប់ហ្នឹងទៅឈ្លបគាត់បានឮ អាហ្នឹងពេលយប់ហ្នឹងទៅ គាត់មិនបានចាប់អារម្មណ៍ពាក្យនេះជាការប្រមាថមើលងាយដល់អង្គការទេ គាត់និយាយដោយស្មោះត្រង់ ទឹកចិត្តស្មោះត្រង់ តាមគំនិតខ្ញុំបាទយល់។ ដល់យប់អង្គការមកប្រមូលទាំងអស់ទៅ យកទៅកម្ទេចចោលទាំងយប់នោះទៅ ហើយមិនដឹងទីណា កន្លែងណា ម៉ោងណា គឺខ្ញុំបាទមិនបានដឹងទេ។ នេះជាគ្រួសាររបស់ប្អូនថ្លៃរបស់ខ្ញុំ ដែលកូនខ្ញុំបាទផ្ទាល់បានស្លាប់ជាមួយ។ នៅគ្រួសារប្អូនបង្កើតមួយទៀត។

**ស៖** លោកបានដំណឹងពីរឿងកូនលោកស្លាប់ និងប្អូនថ្លៃ គ្រួសារប្អូនថ្លៃរបស់លោកស្លាប់នុ៎ងលោកបានពេលក្រោយដែលទ័ពវៀតណាមបានចូលស្រុក -- ក្រោយឆ្នាំ១៩៧៩ អ៊ីចឹងទេ? ឬក៏មុនហ្នឹង?

**ឆ៖** គឺក្រោយឆ្នាំ១៩៧៩ ថ្មីៗនេះ។

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណលោកប្រធាន ខ្ញុំសូមចប់ អស់សំណួរ។ ខ្ញុំសូមអរគុណលោក នួរ ហ៊ាន់ ដែលលោកបានមកឆ្លើយនៅពេលនេះ។ សូមអរគុណ។

[១០:២៣:៤៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមជម្រាបសួរលោក នួរ ហ៊ាន់។ ខ្ញុំ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបញ្ជាក់លោក។

**សួរដោយលោក គង់ សំអុន៖**

**ស៖** មុននេះលោកបានឆ្លើយបញ្ជាក់ថា លោកបានស្គាល់លោក ខៀវ សំផន ជាពិសេសក្នុងទសវត្សរ៍៦០ ដែលលោកបានដឹងឮអំពីកិត្តិយសរបស់គាត់ កិត្តិនាមរបស់គាត់នៅពេលនោះ។ ខ្ញុំចង់សួរលោកថា តើលោកដឹងថា លោក ខៀវ សំផន ធ្វើអីដែរនៅទសវត្សរ៍៦០?

[១០:២៤:៤៥]

**លោក នួរ ហ៊ាន់៖**

**ឆ៖** ទី១ គឺដំបូងបង្អស់ខ្ញុំបាទដឹងថាគាត់ធ្វើកាសែត ធ្វើសារព័ត៌មានមួយហៅថាឈ្មោះថាអុបស៊ែរវ៉ាទ័រ។ ហើយក្រោយមកគាត់ក៏បាន កាលនោះសង្គមរាស្ត្រនិយមកើតឡើងដោយសម្តេច នរោត្តម សីហនុ គាត់ក៏បានចូលទៅជាប់ជាសភាតំណាងរាស្ត្រនៅក្នុងគណៈបក្សសង្គមរាស្ត្រនិយម ហើយគាត់មានពេលខ្លះគាត់បានឡើងទៅជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ហើយខ្ញុំបាទបានឮកិត្តិនាមនិងប្រវត្តិរបស់គាត់ និយាយពីមាត់មួយទៅមាត់មួយថាគាត់ជាមនុស្សស្អាតស្អំ គាត់មិនចូលចិត្តរឿងបញ្ឆោពុករលួយអីផ្សេងៗហ្នឹង។ មានពាក្យគេនិយាយមួយទៀតថាខ្ញុំបាទមិនដឹងថាពិត ឬមិនពិត ប៉ុន្តែខ្ញុំបាទបានឮតាមពាក្យគេនិយាយដែលចូលមកត្រចៀកខ្ញុំបាទ ថាមានថ្ងៃមួយនោះ ពេលដែលគាត់ឡើងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មមាននាយទុនម្នាក់ទិញម៉ែកសីដេសថ្មីមួយយកទៅទុកក្រោមផ្ទះគាត់ ហើយប្រគល់សោរនោះទុកនៅនុំងថាទុកជូនគាត់។ ហើយដល់ពេលគាត់អញ្ជើញត្រឡប់ពីធ្វើការមកវិញ គាត់សួរថាឡានអ្នកណាគេទុកហ្នឹង? បានអ្នកបម្រើគាត់ដែលថាមានឈ្មោះនេះៗ ខ្ញុំមិនដឹង គាត់ឲ្យអ្នកបើកឡានរបស់គាត់បើកឡានហ្នឹងយកទៅត្រឡប់ឲ្យម្ចាស់វិញ។ ប៉ុន្តែរឿងនេះ ពិតមិនពិត គឺខ្ញុំបាទមិនបានដឹងទេ ប៉ុន្តែខ្ញុំបាទឮគេនិយាយមកយ៉ាងដូច្នេះឯង។

[១០:២៦:១៣]

**ស៖** បាទសូមអរគុណ។ តើលោកអាចបញ្ជាក់បានទេពីការងាររបស់លោក ខៀវ សំផន នៅទសវត្សរ៍៦០ ទាក់ទងទៅនឹងកិច្ចការនៅក្នុង គេហៅថាកិច្ចការងាររដ្ឋរបស់លោក ខៀវ សំផន។ ថា

លោក ខៀវ សំផន ក្នុងឋានៈលោកជា -- តាមលោកមានប្រសាសន៍អំមិញថាជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ តើគាត់មានបញ្ហាអ្វីខ្លះនៅក្នុងផ្នែកនយោបាយនៅពេលនោះ?

**ឆ៖** សូមទោសលោកមេធាវី ខ្ញុំបាទសូមជម្រាបថា ខ្ញុំបាទមិនបានស៊ីជម្រៅទេ ពីព្រោះកាលនោះខ្ញុំបាទក៏មិនបានតាមដានព្រឹត្តិការណ៍អីផ្សេងៗឲ្យបានស៊ីជម្រៅជ្រៅជ្រះអំពីទាក់ទងអំពីបញ្ហានយោ-បាយដែរ គឺខ្ញុំបាទមិនបានស៊ីជម្រៅទេ។ គ្រាន់តែបានឮតែបានប៉ុណ្ណឹង គឺបានជម្រាបខាងដើមអំមិញហ្នឹង។

**ស៖** បាទសូមអរគុណ។ តើលោកដឹងថាវត្តមានរបស់លោក ខៀវ សំផន នៅប្រទេសកម្ពុជាហ្នឹងរហូតដល់ពេលណាដែរនៅក្នុងទសវត្សរ៍៦០ហ្នឹង? ខ្ញុំអាចសួរបញ្ជាក់លោកជាថ្មី បើសិនជាលោកមិនយល់នូវសំណួររបស់ខ្ញុំ។ ខ្ញុំចង់ដឹងថា តើលោក ខៀវ សំផន បានបាត់មុខពីសាធារណជន ពីវេទិកាសាធារណៈផ្សេងៗដូចលោកមានប្រសាសន៍ពីការចូលរួមប្រជុំអីផ្សេងៗជាដើមហ្នឹង នៅក្នុងពេលណាដែរនៅក្នុងទសវត្សរ៍៦០ហ្នឹង តើលោកមានចាំទេ?

[១០:២៨:០៩]

**ឆ៖** សូមទោសលោកមេធាវី បញ្ហានេះខ្ញុំបាទមិនបានដឹងអីគ្រប់គ្រាន់ទេ។ ប៉ុន្តែកាលណោះ គឺគ្រាន់តែយើងបានដំណឹងតាមសារព័ត៌មាននានាដែលគេបានចុះផ្សាយប្រចាំថ្ងៃ ប្រចាំសប្ដាហ៍តែប៉ុណ្ណោះឯង ហើយមិនបានចាំថាក្នុងរង្វង់ខែណា ហើយឆ្នាំណា គឺយើងមិនបានដឹងច្បាស់ទេ។

**ស៖** បាទសូមអរគុណ។ តើលោកបានដឹងថាលោក ខៀវ សំផន បានបាត់មុខពីប្រទេសកម្ពុជាដែរឬទេនៅពេលនោះ?

**ឆ៖** តាមរយៈសារព័ត៌មាន គេបានឲ្យដំណឹងដល់អ្នកអានទាំងឡាយជ្រាបថាលោកខៀវ សំផន បានចេញពីភ្នំពេញទៅចូលព្រៃម៉ាគីបាត់ហើយ។ តែប៉ុណ្ណឹងឯង ហើយគ្មានរឿងអីផ្សេងទៀតដែលគួរឲ្យដឹងច្រើនជាងនេះ។

**ស៖** សូមលោកបញ្ជាក់ថាព្រៃម៉ាគី ដែលលោកនិយាយនោះជាអ្វីដែរទៅ?

**ឆ៖** តាមខ្ញុំបាទយល់ ព្រៃម៉ាគីហ្នឹងគឺជាតំបន់ត្រួតត្រាដោយខ្មែរក្រហមហ្នឹងឯង។ នេះជាការយល់របស់ខ្ញុំបាទ។

[១០:២៩:២៨]

**ស៖** បាទសូមអរគុណ។ ចុះលោកបានដឹងពីវត្តមានរបស់លោកខៀវ សំផន វិញនៅពេលណាដែរ?

**ឆ៖** កន្លែងហ្នឹងមួយ ខ្ញុំបាទក៏មិនបានដឹងអីច្បាស់ដែរ គឺមិនបានដឹងអីច្បាស់ទេ ពីព្រោះយើងក្រោយពីស្រុកបែកលិចលង់អីទៅ វិលត្រឡប់មកវិញអីហើយ យ៉ាងម៉េចៗ គឺយើងវិលវល់អស់ហើយ យើងមិនបានដឹងដំណឹងអីច្រើនទេ គឺខ្ញុំបានដឹងអីច្រើនទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការលើកឧទាហរណ៍របស់លោក ការលើកពន្យល់របស់លោកចំពោះពាក្យថា "ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់" សូមលោកជួយបញ្ជាក់អំពីខ្លឹមសារនៃពាក្យនេះថា តើត្រីមួយត្រកដែលលោកចង់សំដៅដល់នោះជាអ្វី?

**ឆ៖** មុននេះលោក ខៀវ សំផន លោកបានមានប្រសាសន៍លោកហើយ សារភាពរួចហើយថា ថ្លែងរួចហើយថាលោកជាបញ្ញវន្ត។ ដូច្នេះគឺគាត់គិតថា កាលណោះគេឲ្យតម្លៃលោកថាជាមនុស្សនៅទន់ជ្រាយ។ អ៊ីចឹងទេ ខ្ញុំបាទគិតថាខ្ញុំបាទមិនបានយល់អីជ្រៅជ្រះទេកន្លែង ព្រោះ -- ប៉ុន្តែគ្រាន់ថាមានពាក្យខ្មែរថា "ត្រីមួយត្រកតែស្អុយតែមួយស្អុយទាំងអស់"។ ការពិតដែលខ្ញុំចង់និយាយ ដូចពីដើមគាត់ធ្លាប់មានប្រវត្តិរបស់គាត់ល្អ មិនពុករលួយ មិនស៊ីសំណូក មិនអីៗ។ ចុះហេតុអីពេលហ្នឹងទៅនៅជាមួយក្នុងអង្គការខ្មែរក្រហមហ្នឹង ខ្មៅចិត្ត ខ្មៅឫស្យាហ្នឹង។ ហើយអ៊ីចឹងទេចង់មិនចង់ អ្នកទាំងអស់គ្នាថា "ត្រីមួយត្រកតែស្អុយតែមួយស្អុយទាំងអស់ហើយ"។ ប៉ុន្តែខ្ញុំបាទយល់ថាខ្លួនលោក ខៀវ សំផន មកទាល់ថ្ងៃនេះគាត់នៅតែតាំងចិត្តថា គាត់ជាត្រីមិនស្អុយ ប៉ុន្តែពាក្យគេថា "ត្រីមួយត្រកតែស្អុយតែមួយស្អុយទាំងអស់" ព្រោះនៅត្រកជាមួយគ្នាបាទ។

[១០:៣២:០១]

**ស៖** បាទ សូមអរគុណ។ តើលោកដឹងពីមូលហេតុអ្វីបានជាលោក ខៀវ សំផន ត្រូវបានរត់គេចខ្លួន បង្ខំរត់គេចខ្លួនចូលទៅក្នុងព្រៃដូចដែលលោកមានប្រសាសន៍ថា ព្រៃម៉ាគីអម្បាញ់មិញនេះ។ លោក ខៀវ សំផន គាត់បានបញ្ជាក់នៅពេលដែលលោកសួរថា មូលហេតុដែលគាត់ចូលទៅជាមួយក្រុមខ្មែរក្រហមនោះអាចថាជារឿងចៃដន្យផង។ បាទ ខ្ញុំចង់សួរបញ្ជាក់លោកថា តើលោកបានដឹងពីមូលហេតុណាមួយដែលត្រូវបានផ្សព្វផ្សាយតាមសារព័ត៌មាន ឬក៏តាមការនិយាយពីមិត្តភក្តិរបស់លោក អំពីមូលហេតុនៃការបាត់ខ្លួនរបស់លោក ខៀវ សំផន នៅទសវត្សរ៍៦០នោះដែរទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបបន្ថែមថា ខ្ញុំបាទមិនបានដឹងអីជ្រៅជ្រះទេ គ្រាន់តែដឹងថាតាមរយៈសារព័ត៌មានថា គាត់បានបាត់ចេញពីទីក្រុងភ្នំពេញហើយ គឺតែប៉ុណ្ណឹងឯង គឺថាដោយមូលហេតុអ្វី ធ្វើឲ្យគាត់បាត់ហ្នឹង គឺមិនបានដឹងជ្រៅជ្រះទេ។

[១០:៣៣:១៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក នួរ ហ៊ាន់។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយសហការីមានសំណួរមួយពីរទៀត។ បាទ សូមអរគុណ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយពាក់ព័ន្ធទៅនឹងអ្វីដែលលោកបាននិយាយថា ព័ត៌មានដែលលោកបានទទួលពីអ្នកដែលស្គាល់លោក ខៀវ សំផន ខ្ញុំមិនដឹងថាអាចកំណត់ពេលវេលាយ៉ាងម៉េចទេ ក៏ប៉ុន្តែពេលនោះបាននិយាយថា “លោក ខៀវ សំផន នឹងមកប្រទេសដើម្បីរៀបចំប្រទេស” ខ្ញុំដូចជាមិនសូវចាំអម្បាញ់មិញនេះ។ លោកនិយាយថា លោកទទួលបានព័ត៌មានពីមនុស្សមួយចំនួនដែលនិយាយថា “លោក ខៀវ សំផន នឹងត្រឡប់មមកវិញ” អម្បាញ់មិញនេះខ្ញុំឮដូចជាអ៊ីចឹង។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា តើអ្នកណាជាអ្នកផ្ដល់ព័ត៌មានឲ្យលោកថា លោក ខៀវ សំផន នឹងត្រឡប់ចូលមកវិញនេះនោះ?

[១០:៣៤:១៥]

**លោក នួរ ហ៊ាន់៖**

**ឆ៖** ថ្ងៃហ្នឹងមានសាច់ញាតិខាងខ្ញុំបាទមួយ គាត់ធ្វើការនៅប្រធានសុរិយោដីនៅខេត្តព្រៃវែង ហើយគ្រួសារគាត់ហ្នឹងគាត់ទៅនៅជាប់ជាមួយគ្នាប៉ុន្មានគ្រួសារហ្នឹង គាត់បានមានប្រសាសន៍អ៊ីចឹង។ ប៉ុន្តែឲ្យថាខ្ញុំបានយល់អីច្បាស់ជ្រៅជ្រះអីជាងនេះ គឺមិនបានជ្រៅជ្រះទេ គាត់គ្រាន់មានប្រសាសន៍ថាអ៊ីចឹង យើងបង្អង់សិនទៅ គឺតិចទៀតលោក ខៀវ សំផន មកប្រហែលជាគាត់នឹងឲ្យបងប្អូន។ ពីព្រោះមុនយើងចេញក៏កងទ័ពខ្មែរក្រហមបានប្រាប់ដែរ បងប្អូនញាតិញោមចេញទៅតែ៣ថ្ងៃទេ អង្គការនឹងឲ្យត្រឡប់មកវិញហើយ។ ហើយអ៊ីចឹងយោងពាក្យសម្ដីថា “៣ថ្ងៃ” ហ្នឹងដែលគាត់បានមានប្រសាសន៍ថាប្រហែលជា លោក ខៀវ សំផន ចូលមកវិញហ្នឹងរៀបចំអីហៅបងប្អូនអ្នកធ្លាប់មានបច្ចេកទេសអីផ្សេងៗហ្នឹងទៅជួយបម្រើការងាររដ្ឋវិញ តែប៉ុណ្ណឹង។

**ស៖** មានន័យថាគេនាំគ្នាចាំឲ្យលោក ខៀវ សំផន ត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ។ អ៊ីចឹងមែនទេ?

[១០:៣៥:២៨]

**ឆ៖** ខ្ញុំមិនដឹងថា គេរាល់គ្នា គឺទាំងអស់គ្នាទូទាំងប្រទេសគឺមិនបានដឹងទេ ដឹងតែក្នុងមួយចំណុចដែលនៅជាប់ក្បែរជំរំដែលខ្ញុំបានស្នាក់នៅហ្នឹងគេមានគំនិតគេយល់ថាអ៊ីចឹង តាមរយៈលោកពូម្នាក់ដែលគាត់មានប្រសាសន៍ហ្នឹងឯង។ ទូទៅផ្សេងទៀតខ្ញុំអត់បានយល់ដឹងដែរ។

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីរឿងហេតុមួយដែលថាលោកចង់យកថ្នាំទៅតាមខ្លួនក៏ប៉ុន្តែគេមិនឲ្យលោកយកថ្នាំនោះទៅ។ ដូច្នេះខ្ញុំចង់ដឹង ព្រោះថាលោកធ្វើការនៅក្នុងក្រសួងសុខាភិបាល ខ្ញុំមិនដឹងថាលោកធ្វើអីឲ្យប្រាកដទេនៅក្រសួងហ្នឹង។ ក៏ប៉ុន្តែខ្ញុំចង់ឲ្យលោកបកស្រាយបន្តិច តើលោកយល់យ៉ាងម៉េចដែរអំពីការហាមឃាត់មិនឲ្យយកថ្នាំបែបនេះនោះ? ហើយបន្ទាប់មកលោកឃើញមានការចែកចាយថ្នាំមិនសមស្របនោះ។ ដូច្នេះ តើនៅពេលដែលឃើញគេហាមឃាត់លោកអ៊ីចឹងកុំឲ្យយកថ្នាំអ៊ីចឹងបន្ទាប់មកគេឲ្យជារបៀបថ្នាំដែលថាថ្នាំមិនមានប្រសិទ្ធភាពអីទៅវិញ តើលោកយល់យ៉ាងម៉េចចំពោះស្ថានភាពបែបនេះ?

**ឆ៖** កាលនោះខ្ញុំបានយកចិត្តទុកដាក់ណាស់ពេលចេញ ជាពិសេសភរិយាខ្ញុំបាទតែម្ដង។ គាត់ខំផ្លៀតឱកាសតាមផ្លូវយកនេះទៅដូរនេះ យកនោះទៅនេះជាពិសេសយកថ្នាំទៅតាមគ្រួសារក្រែងលោកូនចៅអីឈឺថ្កាត់យ៉ាងម៉េចៗយើងមានថ្នាំការពារ។ ប៉ុន្តែយើងលាក់បានតែមួយចំនួនទេ។ មួយចំនួន ដូចជាសីវាំងម្ដុលអីហ្នឹង គេឆែកឃើញអង្គការគេយកអស់ហើយ។ ដល់ទៅដល់មូលដ្ឋានយើងឃើញជាក់ស្ដែងថាអ៊ីចឹងមែនគឺគេមិនត្រូវការប្រើប្រាស់ថ្នាំអស់ហ្នឹងទេ ពួកចក្រពត្តិរបស់ពួកចក្រពត្តិ។ ដូច្នេះគេប្រើថ្នាំថ្មីជាពិសេសគឺថ្នាំអាចម៍ទន្សាយសួនប៉ុនៗកូនដៃហ្នឹង មិនដឹងថាមានសំបកឈើ ឬឈើស្អីខ្លះហ្នឹងយើងមិនបានដឹងទេ។ ហើយថ្នាំទឹក ថ្នាំសូលុយស្យុងសម្រាប់ចាក់ គឺយើងឃើញតែពណ៌ក្រហមៗ គេដាក់នៅក្នុងដបមីរីនដា – ទឹកក្រូចមីរីនដា សម្រាប់ចាក់ឲ្យប្រជាពលរដ្ឋណាដែលឈឺ។ ឃើញតែប៉ុណ្ណឹងហើយ។

[១០:៣៧:៥៦]

ខ្ញុំបាទដែលឃើញផ្ទាល់ភ្នែកអ៊ីចឹងយល់ថា និយាយអំពីបច្ចេកទេសវិទ្យាសាស្ត្រពេទ្យ គេប្រយ័ត្នណាស់រឿងបញ្ហាអនាម័យអីផ្សេងៗទាំងអស់គេមានសុទ្ធតែរូបមន្តអីច្បាស់លាស់ណាស់។ ដល់យើងឃើញរបស់របរប្រើប្រាស់អ៊ីចឹងយើងអត់មានការទុកចិត្តសោះ។ មិនដឹងជាគ្រោះថ្នាក់អ្នកណាទទួលថ្នាំអស់ហ្នឹងទៅទទួលគ្រោះថ្នាក់យ៉ាងម៉េច យើងមិនអាចដឹងបានទាំងអស់។ ដូច្នេះទាំងអស់ហ្នឹង ដែលធ្វើឲ្យយើងគិតថាប្រទេសជាតិនឹងក្លាយទៅជាអ្វីនៅថ្ងៃខាងមុខបើសិនជាធ្វើការរបៀបហ្នឹង យើងប្រើប្រាស់សម្ភារៈរបៀបហ្នឹង។ នេះជាគំនិតរបស់ខ្ញុំបាទយល់មានប៉ុណ្ណឹង។

**ស៖** ខ្ញុំមានសំណួរពីរបន្តពីអ្វីដែលលោកឆ្លើយ។ លោកបាននិយាយថាលោកចាប់អារម្មណ៍ទៅលើការងាររបស់លោក។ អ៊ីចឹងតើលោកអាចនិយាយពីការងាររបស់លោកក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានទេ?

[១០:៣៩:០៥]

**ឆ៖** ការងារនៅក្នុងកម្ពុជាប្រជាធិបតេយ្យក្រោយដែលខ្ញុំបាទត្រូវបានដោះលែងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៥ ពីមន្ទីរឃុំឃាំងនៅក្នុងស្រុកព្រះស្តេចវិលមកសហករណ៍ស្វាយបាំង ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែងវិញនោះ គឺការងាររបស់ខ្ញុំបាទ ភ្ជួររាស់ធម្មតាដូចជាប្រជាពលរដ្ឋនៅក្នុងភូមិ ជាពិសេសប្រជាពលរដ្ឋចាស់អ្នកមូលដ្ឋាន។ ភ្ជួររាស់ច្រូតដកស្ទូង។ ហើយដល់ឆ្នាំ៧៨ គេប្រមូលយុវជនយុវនារីទៅកងចល័តអស់ ដល់អ៊ីចឹងខ្វះកម្លាំងត្រូវដងទឹកដាក់រោងបាយ។ ដូច្នេះសហករណ៍ចាត់តាំងឲ្យរូបខ្ញុំបាទហ្នឹងទៅដងទឹកដាក់រោងបាយ។ រោងបាយមានមាត់ទាំងកូនក្មេង ទាំងមនុស្សចាស់ប្រហែលជាជិត៥០០នាក់។ រោងបាយហ្នឹងធំ។ ហើយយើងទទួលបន្ទុករែកទឹកនឹងស្នាប៉ោតពីរម្នាក់ឯង។ កាលយុវជននៅគេមានរទេះគោមួយនឹម ធុងមួយ ហើយមានរទេះកង់ឡានមួយគ្នាគេបួននាក់។ ដល់ពេលគេទៅចល័តអស់ទៅ ទៅលើកទំនប់ជីកប្រឡាយអស់ទៅ ខ្ញុំបាទទទួលបន្ទុកម្នាក់ឯង សហករណ៍ហ្នឹងដដែល ប៉ោតអម្រែកពីរ យោងទឹកអណ្តូងទម្រាំតែពេញពាងរោងបាយហើយជួយសម្អាតសម្ភារៈចានឆ្នាំង ហាលអីៗអ៊ីចឹង។

**ស៖** បាទ សូមអរគុណលោក។ ចំពោះថ្នាំវិញនោះ តើខ្ញុំអាចសង្ខេបបានទេថា ការសម្រេចក្នុងការជ្រើសរើសយកថ្នាំណាៗយកមកប្រើនោះ គឺជាការសម្រេចតាមបែបមនោគមន៍វិជ្ជា មិនមែនតាមបែបវេជ្ជសាស្ត្រនោះទេ។ តើអ៊ីចឹងមែនទេ បើតាមការយល់ឃើញរបស់លោកនោះ?

[១០:៤១:០៨]

**ឆ៖** ខ្ញុំបាទគិតថា ខ្ញុំបាទមិនច្បាស់ថាតាមមនោគមន៍វិជ្ជា ឬមួយក៏វិទ្យាសាស្ត្រទេ។ ខ្ញុំបាទគិតថា ខ្លួនអង្គការតែងតែប្រកាសថា ខ្លួនទីពឹងខ្លួន ធ្វើការអ្វីដោយខ្លួនឯង មិនត្រូវការពឹងពាក់អ្វីដែលជារបស់កម្អែលចក្រពត្តិ ដូច្នេះជាគំនិតរបស់អង្គការ។ អាហ្នឹងជារឿងមួយផ្នែកអង្គការ ប៉ុន្តែការពិតវាបម្រើសំណូមពរឲ្យមានប្រសិទ្ធភាពសម្រាប់ -- ចំពោះអ្នកមានជំងឺគឺខ្ញុំបាទថា វាអត់មានប្រសិទ្ធភាពទេ។ អានេះជាការយល់ឃើញរបស់ខ្ញុំបានមានប៉ុណ្ណឹង។

**ស៖** សំណួរចុងក្រោយ ខ្ញុំសូមឲ្យលោកឆ្លើយទៅតាមអ្វីដែលលោកកត់សម្គាល់ឃើញ។ តើ

E1/199.1

លោកមានកត់សម្គាល់ឃើញថា អ្នកដែលមានឋានៈខ្ពស់នៅជុំវិញលោកទទួលបានការប្រព្រឹត្តដូចគ្នាដែរឬទេ? ខ្ញុំចង់មានន័យថា តើមានការប្រព្រឹត្តខុសគ្នាដែរឬទេ ចំពោះមនុស្សផ្សេងៗពាក់ព័ន្ធទៅនឹងការយកថ្នាំពួកចក្រពត្តិ ហើយនិងថ្នាំថ្មីយកមកប្រើនេះ? លោកមានឃើញថា មានភាពខុសគ្នាដែរឬទេក្នុងការអនុវត្តវិធានថាមានអ្នកខ្លះអាចយកថ្នាំចក្រពត្តិ ឬក៏អ្នកខ្លះយកថ្នាំថ្មីមកប្រើប្រាស់នេះ?

[១០:៤២:៥៥]

**ឆះ** អ្វីដែលខ្ញុំបាទបានឃើញការប្រើប្រាស់ថ្នាំជាឱសថ ជាពិសេសអង្គាល់នុំងស្រុកខ្មែរយើងច្រើនថ្នាំប្រភពមកពីប្រទេសបារាំង។ អ្នកដែលប្រើប្រាស់ថ្នាំហ្នឹង អ្នកដែលមានលទ្ធភាពថ្នាំហ្នឹងប្រើប្រាស់ គឺប្រុងប្រយ័ត្នណាស់ គឺថាប្រើប្រាស់ដោយលាក់កំបាំងមិនឱ្យអង្គការ ឬមួយឈ្លបណាដឹងទេ គឺលាក់កំបាំងជិតណាស់។ បើសិនជាថ្នាំរបស់អង្គការតែម្តង ជាគ្រូឱសថបូរាណសម្បកឈើ ឫសឈើអីស្ងោរមួយចានជំងឺមួយរយមុខអីហ្នឹង អាហ្នឹងដឹងតែប្រើប្រាស់ទាំងអស់គ្នាអ៊ីចឹងទៅ ហើយថ្នាំសូលុយស្យុង ថ្នាំទឹកដាក់ដបមីរីនដា ដាក់ដបអីហ្នឹង គឺគេប្រើប្រាស់តាមអ៊ីចឹងទៅ។ ថ្នាំអាចម៍ទន្សាយអីគេប្រើប្រាស់ជាសេរី ទូទៅអ៊ីចឹងទៅនៅតាមកន្លែងផ្សេងៗហ្នឹង។ ប៉ុន្តែបើថ្នាំពីដើម គេលាក់បាំងណាស់ គេមិនឱ្យអង្គការឃើញទេ។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

[១០:៤៤:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោក នូវ ហ៊ាន់ ការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាព្យសនកម្ម និងសក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានស្វែងរកការពិតក្នុងរឿងក្តីនេះ។ សូមលោក នូវ ហ៊ាន់ មានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន ហើយលោកអាចវិលត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្រាបសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុង

បញ្ជូនលោក នួរ ហ៊ាន់ វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬទីដែលគាត់ស្នាក់នៅវិញបានហើយ។ ហើយអង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៤៥ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-149 ចូលមកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអី?

**លោកស្រី សូផាន់ សូវណ្ណី៖**

**ឆ៖** នាងខ្ញុំឈ្មោះ សូផាន់ សូវណ្ណី។

**ស៖** អរគុណ។ លោកស្រី សូវណ្ណី តើលោកស្រីមានអាយុប៉ុន្មាន?

**ឆ៖** នាងខ្ញុំអាយុ៥៧ឆ្នាំ។

**ស៖** បាទ អរគុណ។ ហើយលោកស្រីអាចជម្រាបអង្គសវនាការបានដែរទេថា តើលោកស្រីមានទីកន្លែងកំណើតនៅកន្លែងណា? ហើយទីកន្លែងលោក -- លំនៅសព្វថ្ងៃបច្ចុប្បន្ននេះ របស់លោកស្រីនេះលោកស្រីរស់នៅទីកន្លែងណា?

[១១:០៤:៥០]

**ឆ៖** នាងខ្ញុំកើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ។ ទីបច្ចុប្បន្ននាងខ្ញុំរស់នៅភូមិបន្ទាយដីក្រោយ

ឃុំបន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

**ស៖** លោកស្រីប្រកបមុខរបរធ្វើអី?

**ឆ៖** នាងខ្ញុំធ្វើកសិករ។

**ស៖** លោកស្រីអាចជម្រាបដល់អង្គសវនាការបានទេថាតើឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី? ប្ដីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

[១១:០៥:៣៧]

**ឆ៖** ចាស ឪពុករបស់ឈ្មោះ សូផាន់ សូផៃ (ស្លាប់) ម្ដាយរបស់នាងខ្ញុំឈ្មោះ លឹម គឹមសាយ (ស្លាប់) គ្រួសាររបស់នាងខ្ញុំឈ្មោះ ង៉ែត វណ្ណដេត។ នាងខ្ញុំមានកូនបីនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងម៉េចទៅ នៅក្នុងនីតិវិធីនៃការស្ដាប់នូវសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ព្យសនកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ? អំមិញគឺបានស្នើសុំដល់អង្គជំនុំជម្រះម្ដងរួចមកហើយ ប៉ុន្តែដូចជាមានការប្រែប្រួលនូវការសម្រេចចិត្តរបស់ខ្លួន។ សូមលោកបញ្ជាក់ឡើងវិញឲ្យបានច្បាស់លាស់នាពេលនេះ ចំពោះនីតិវិធីនៃការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និងដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀតដែរ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ដូចបានជម្រាបជូនលោកប្រធានពីមុន គឺថាសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គឺទុកឱកាសជូនដល់អ្នកស្រីជាអ្នកថ្លែង។ ហើយបន្ទាប់មកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនឹងសួរសំណួរ បើសិនមានចំណុចដែលនៅសេសសល់ ដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីយល់ថានឹងសួរ។

[១១:០៧:០៥]

ដូចគ្នាដែរសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ មានន័យថាដើមបណ្ដឹងរដ្ឋប្បវេណីទី៣ ហើយចំពោះករណីដើមបណ្ដឹងរដ្ឋប្បវេណីចុងក្រោយសម្រាប់ថ្ងៃនេះ។ គឺ TCCP-117 គឺមេធាវីជាអ្នកសួរសំណួរដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកឆ្លើយ។ បាទ សូមជម្រាបលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

លោកស្រី សូផាន់ សូវណ្ណី នៅក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់ឱកាសឲ្យលោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលបានកើតមានចំពោះលោកស្រី មានជាអាទិ៍ការខូចខាតផ្លូវចិត្ត ផ្លូវកាយ ឬខាងសម្ភារៈ។ ព្យសនកម្មផ្ទាល់ខ្លួន ដែលបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ន ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

បាទ នេះជាសិទ្ធិរបស់លោកស្រីក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏ជាឱកាសដែរ ដែលអង្គជំនុំជម្រះផ្ដល់ឱកាសនេះជូនទៅលោកស្រី។ សូមអញ្ជើញលោកស្រី សូវណ្ណី!

[១១:០៨:៥៨]

**លោកស្រី សូផាន់ សូវណ្ណី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។

នៅឆ្នាំ១៩៧៥ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំនឹងគ្រួសារខ្ញុំរស់នៅក្នុងភូមិ -- នៅផ្ទះជួបជុំគ្នាតែនៅក្នុងភូមិផ្សារតូច គេហៅថាសង្កាត់លេខ១ ក្រុងភ្នំពេញ គឺឡូលេខ៦យើងហ្នឹង។ ពេលនុំងខ្ញុំឮស្គរថា ឮស្គរមីក្រូគេហ្នឹង គេស្រែកថា មេឃោធាគេស្រែកថា “សូមឲ្យបងប្អូនត្រូវចាកចេញពីក្នុងទីលំនៅហ្នឹង! បើមិនចាកចេញទេនឹងមានការទម្លាក់គ្រាប់បែកពីអាមេរិកាំង”។ ចាស ខ្ញុំពេលនោះខ្ញុំមិនជឿនូវ ឮស្គរអីចឹងមិនជឿទេចាស។ ខ្ញុំក៏ចេញពីផ្ទះ ព្រោះផ្ទះខ្ញុំនៅក្នុងៗផ្លូវលំ ខ្ញុំក៏ចេញពីផ្លូវហ្នឹង ចេញទៅជិតហ្នឹងផ្លូវថ្នល់ហ្នឹងដើម្បីស្ដាប់ទៀត តែនៅឮស្គរ គេប្រកាសហ្នឹងម្ដងអីចឹងទៀត ពាក្យដដែលហ្នឹង។ ខ្ញុំក៏រត់មកប្រាប់ឪពុក ជាមួយម្ដាយខ្ញុំថា ឪម៉ែអើយ គេឲ្យយើងហ្នឹងចេញពីផ្ទះហ្នឹងហើយ ឲ្យយើងចេញពីភ្នំពេញជាប្រញាប់ បើយើងមិនចេញទេ នឹងមានការទម្លាក់គ្រប់បែកពីអាមេរិកាំង។ ឪពុកម្ដាយខ្ញុំថា អី!កុំជឿអីស្រុកសន្តិភាពអីចឹងហើយ មានអ្នកគេមកទម្លាក់អីទៅទៀតទេកូនអើយ។

[១១:១០:៣៤]

តែបន្ទាប់ពី -- គ្រាន់តែនិយាយមិនទាន់ផុតមាត់ផងមានឈ្លបបីបួននាក់ហ្នឹងគេដើរមកដល់មុខផ្ទះ។ គេស្រែកចូលទៅក្នុងផ្ទះខ្ញុំថា "ចាំអង្កាល់ទៀតបានមិនរៀបចំអីវ៉ាន់ចេញ! នៅទ្រេតទ្រោតដល់ណាទៀត ល្មមចេញហើយ! គេចេញគ្រប់គ្នាហើយ ឯងនៅរញ៉េរញ៉ៃអីដល់ណាទៀត! នៅទ្រេតទ្រាតដល់ណាទៀត!"។ ខ្ញុំឮសួរសម្រែកហ្នឹង គ្រប់គ្រួសារខ្ញុំភិតភ័យណាស់ ព្រោះវាមិនធ្លាប់ឮសូរសម្រែកគេស្រែកសម្លុតឲ្យយើងចេញពីផ្ទះ។ ផ្ទះយើងកំពុងតែនៅសុខៗ ហើយគេឲ្យចេញ តើយើងមានប្រតិកម្មម៉េចខ្លះដែលគេឲ្យយើងចាកចេញពីផ្ទះហ្នឹង ដូចជាវាលំបាកណាស់ លំបាកនិយាយប្រាប់អស់លោកថាវាពិបាកម៉េច។ អស់លោកដឹងហើយថាគេយកយើងចេញពីផ្ទះហ្នឹង ថាឲ្យយើងទៅនៅណា? ការហូបចុកយើងវារបៀបយ៉ាងម៉េច? អីយ៉ាងម៉េច យើងអត់បានដឹង? តែយើងត្រូវតែធ្វើតាមការប្រកាសរបស់គេ។

[១១:១១:៣៣]

គ្រាន់តែមិនទាន់នឹងបានរៀបចំអីស្រួលបួលផង ខ្ញុំក៏ឮសូរទៀត។ ឮសូរកាំភ្លើងពីរបីគ្រាប់បាញ់ឡើងទៅលើជិតផ្ទះខ្ញុំហ្នឹង។ វាធ្វើឲ្យខ្ញុំនិងគ្រួសារខ្ញុំហ្នឹងភ័យរន្ធត់ណាស់ ព្រោះឮសូរកាំភ្លើងទៀតហើយ។ យើងក៏ប្រញាប់ប្រញាលចេញពីផ្ទះហ្នឹង ដើរចេញទៅផ្លូវថ្នល់ក្រៅ។ ពេលដែលយើងទៅដល់ផ្លូវថ្នល់ខាងក្រៅ ព្រោះផ្ទះខ្ញុំនៅលំក្នុង។ ខ្ញុំត្រូវចេញពីផ្លូវលំហ្នឹងទៅដល់ផ្លូវថ្នល់ឯក្រៅហ្នឹង។ ពេលខ្ញុំទៅដល់ហ្នឹង វាគួរឲ្យរន្ធត់ និងលំបាកមែនទែននូវទិដ្ឋភាពវារញ៉េរញ៉ៃ វាមនុស្សកកកុញណែនណាន់តាន់តាប់ពោរពេញទៅដោយមនុស្ស មិនដឹងមកពីទីណា។ ខ្ញុំអត់ដឹងថាគេមកពីណា គេមកទៅណាអី ប៉ុន្តែគ្រាន់តែដឹងថានៅលើផ្លូវហ្នឹងគឺមានប្រជាជនច្រើនមែនទែន មានអ្នករបួសក៏មាន រុញ កាលហ្នឹងយើងមានស៊ីក្លូ មានកង់ មានម៉ូតូ មានឡាន តែអត់បើកបាន។ ព្រោះវាអត់មានសាំងមានអីទេ។ គេចេះតែរុញណែនប្រជ្រៀតគ្នាទៅ។ ហើយឮសូរសម្រែកឪពុកហ្នឹង ស្រែកហៅកូន។ ម្ដាយរកបង រកប្អូន រកប្ដី រកក្រុមគ្រួសារ។ តែមានគ្រួសារមួយនោះគេសុំថា "ក្មួយអើយ -- លើកដៃសំពះយោធាគេហ្នឹងថា-- ឲ្យខ្ញុំសុំទៅរកកូនវិញនៅក្នុងផ្ទះ"។ គេបានស្រែកសម្លុតថាគេមិនឲ្យទៅក្រោយវិញដាច់ខាត មានតែទៅមុខ។ ទៅក្រោយគេមិនឲ្យទៅទេ បើទៅមុខបាន។ ដោយយោធាអស់ហ្នឹងគេស្ពាយកាំភ្លើង ភ្ជង់អវ៉ែងពេញហ្នឹង។ គេជំរុញឲ្យយើងទៅមុខជានិច្ច គឺមិនឲ្យថយក្រោយបានដាច់ខាត។ ក្នុងឱកាសហ្នឹង ផ្លូវហ្នឹងនៅសងខាងផ្លូវមាន មើលទៅទិដ្ឋភាពស្មោកគ្រោកណាស់ រុយហើរពេញហ្នឹង មានសាកសព។ សាកសពហ្នឹងមិនដឹងស្លាប់ពីអង្កាល់ ខ្ញុំក៏មិនបានដឹងដែរ ព្រោះចេញមកយើងឃើញគេងាប់ពេញតែផ្លូវហ្នឹង។

ហើយលាមកពេញតែផ្លូវហ្នឹង យើងចេះតែដើរទៅ ចេះតែដើរទៅមុខរហូត។

[១១:១៣:៣៣]

ចាស ខ្ញុំដើររយៈពេល២ថ្ងៃ ពីគីឡូលេខ៦ទៅដល់ព្រែកព្នៅដើរ ២ថ្ងៃ។ គ្មានទឹក គ្មានអីទេយើងហូបចេះតែទឹកផ្អេសផ្អាសហ្នឹង តាមផ្លូវហ្នឹងមានស្អី យើងចេះតែហូបទៅ យើងស្រេកឃ្លាន។ ពេលដែលទៅដល់ព្រែកព្នៅរៀបតែនឹងរៀបចំដាំបាយ ដាំម្ហូប។ ដាំបាយអីញ៉ាំ ស្រាប់តែឃោធាហ្នឹង គេដាក់មីក្រូគេប្រកាសថា ផ្សារគ្មានមានទេ លុយក៏គ្មានចាយដែរ។ ចាស អ៊ីចឹងទាំងរូបខ្ញុំ ទាំងក្រុមគ្រួសារខ្ញុំ ទាំងប្រជាជនដែលនៅតាមផ្លូវហ្នឹង ដូចថាតក់ស្លុត អស់សង្ឃឹម ព្រោះមនុស្សយើងត្រូវការរស់តែនឹងហូបចុកបើគ្មានផ្សារ គ្មានស្អី មិនដឹងទៅទិញស្អី បើពេលដែលយើងចេញមកហ្នឹង យើងគ្មានបានយកស្អីមកច្រើនយើងយកតែបន្តិចៗ ព្រោះគេប្រាប់យើងថាតែ៣ថ្ងៃ ឲ្យយើងចូលទៅវិញ។ អ៊ីចឹងយើងយកបានស្អីបានដែលយួរបាន កាន់បាន យើងយកមក។ យើងអត់បានយកស្អីដែលជាច្រើនធ្ងន់ធ្ងរសម្រាប់ទុកមុខថ្ងៃក្រោយច្រើនថ្ងៃអី អត់មានទេ។ យើងយកតែល្មមហ្នឹង យើងចេញមកហ្នឹង។

[១១:១៤:៥០]

ដល់គេប្រកាសអ៊ីចឹងទៀតទៅ ការអស់សង្ឃឹម ការតក់ស្លុត ការលំបាកក្នុងចិត្តហ្នឹង វាមាននៅក្នុងក្រុមគ្រួសារខ្ញុំផង មាននៅក្នុងប្រជាជន ខ្ញុំអាចមើលទឹកមុខគេបានហើយ។ អ្នកខ្លះហ្នឹងឈឺចិត្តពេកបាចលុយហ្នឹងចោលទៅ ខ្លះហ្នឹងក៏ដុតចោល បាចចោលពេញតែផ្លូវហ្នឹង ដើរទៅមុខទៀតទៅ។ ចាស ខ្ញុំដើររយៈ១៥ថ្ងៃ ខ្ញុំបានឆ្លងសាឡាងព្រែកក្ដាមហ្នឹង ឆ្លងទៅត្រើយខាងណោះ។ ក្នុងគោលបំណងឪពុកខ្ញុំហ្នឹងគឺគាត់ចង់និយាយថា គាត់ចង់យកកូនហ្នឹងឲ្យចេញ -- កូនចៅក្រុមគ្រួសារខ្ញុំហ្នឹងទៅដល់ទល់ដែនដើម្បីឆ្លងៗរត់គេចខ្លួន គាត់មិនចង់ឲ្យកូននៅក្នុងហ្នឹង។ គាត់ហាក់ដូចដឹងរឿងអ្វីមួយតែគាត់អត់ប្រាប់យើង គាត់អត់ប្រាប់ខ្ញុំទេ។ ចាស គាត់មិនប្រាប់ថាគាត់ចង់ឆ្លងឲ្យផុត យកកូនចេញឲ្យផុត។ តែពេលទៅដល់ ខ្ញុំមិនទាន់ទៅដល់កំពង់ធំផង នៅជាយ។ ខ្ញុំអត់បានស្គាល់ នឹកចាំថាភូមិអីស្អី គ្រាន់តែដឹងថាជិតដល់ខេត្តកំពង់ធំប៉ុណ្ណឹង។ ដោយការអស់កម្លាំងហេវហត់ពេកហ្នឹងក៏នាំក្រុមគ្រួសារហ្នឹងចូលទៅសម្រាកនៅក្នុងវត្តមួយហ្នឹង។ វត្តហ្នឹងអត់មានមនុស្សទេ គ្មានព្រះសង្ឃទេ តែរូបបដិមាករដែលជាព្រះជាអីហ្នឹងខ្លះបាក់ព្រះកេសទៅ បាក់ដៃ បាក់ជើង ក។ ខ្ញុំមិនដឹងថាអ្នកណាគេវៃចោលទុកហ្នឹងយូរតាំងពីអង្កាល់ណាទេ ខ្ញុំអត់ដឹងទេ។ ចាស ខ្ញុំទៅដល់ឃើញគេស្លាត់ក្នុងភូមិ ក្នុងវត្តហ្នឹងក៏នាំគ្នាទៅសម្រាកក្នុងកុដមួយហ្នឹង។ ខ្ញុំសម្រាកនៅក្នុងវត្តហ្នឹងបាន២ថ្ងៃ ល្ងាចនៅថ្ងៃទី២ហ្នឹង មានឈ្លបគេបីបួននាក់គេដើរមក គេសួរឪពុកខ្ញុំ

ថា "មិត្តឯងទៅណា?" ឪពុកខ្ញុំឆ្លើយថា "ហ៊ឺ! ក្មួយណ្ហើយពូហ្នឹងចង់ទៅខេត្តកំពង់ធំ ដើម្បីទៅជួបជុំគ្រួសារ ឪពុកម្ដាយបងប្អូន" តែដល់ពេលហ្នឹងទៅគេថា "ទៅធ្វើស្អី? នៅធ្វើការនៅទីនេះក៏ធ្វើការឲ្យអង្គការ ទៅធ្វើដល់កំពង់ធំមិត្តឯងក៏ធ្វើការឲ្យអង្គការដែរ។ មិត្តឯងចង់ធ្វើស្អី នៅធ្វើការហ្នឹងឲ្យអង្គការស្អែកមិត្តឯងចុះទៅជួយធ្វើការប្រជាជននៅក្នុងភូមិ! គេកំពុងតែធ្វើការសស្រាក់សស្រាំ មិត្តឯងចង់ដើរទៅណាទៀត?" ឪពុកខ្ញុំឮសម្ដីហ្នឹងក៏មិនប៊ាននិយាយអីតបតទៅគេវិញទៀតដែរ ក៏គាត់នៅស្ងៀមទៅ។

[១១:១៧:១២]

ស្អែកព្រឹកព្រលឹមឡើងមានប្រធានភូមិគេហ្នឹង គេដើរមក១ គេប្រាប់ឪពុកថា "ស្អែកហ្នឹងឲ្យពួកក្រុមគ្រួសារខ្ញុំហ្នឹងចុះទៅដកសំណាប" មែនស្អែកឡើងម៉ោងប្រហែលជាប្អូនប្រាំភ្លឺហ្នឹង ឃើញគេមកដាស់ក្រុមគ្រួសារខ្ញុំហ្នឹងឲ្យចុះទៅដកសំណាប។ អស់លោកជំនាន់ហ្នឹងក្រុមគ្រួសារខ្ញុំរកស៊ី ហើយឪពុកម្ដាយខ្ញុំហ្នឹងឲ្យកូនរៀន ពួកខ្ញុំអត់ស្គាល់ស្រែម៉េច អត់ស្គាល់ស្រូវយ៉ាងម៉េច អត់ស្គាល់សំណាបហ្នឹងយ៉ាងម៉េចទៀត ដល់គេឲ្យយើងចុះដកសំណាប លោកដឹងទេ គេអ្នកចេះគេដកទៅមុន។ ចាស យើងនៅក្រោយចេះតែដកតិច១ គេបំផ្លោងភក់ជះចូលមករកក្រុមគ្រួសារខ្ញុំទាំងអស់។ ប្អូនខ្ញុំ ខ្ញុំក្ដីហ្នឹង ត្រូវភក់ហ្នឹងពេញមុខទាំងអស់។ ប្អូនខ្ញុំស្រែកយំ ឪពុកជាមួយម្ដាយខ្ញុំខំយកដៃខ្ទប់មាត់កូនកុំឲ្យយំឮពេក។ ដល់ហ្នឹងទៅយកដៃហ្នឹងចូកទឹកភក់ ទឹកប៊ិក១យកមកលាងមុខកូន ដើម្បីកុំឲ្យ -- ឲ្យបើកភ្នែកមើលទៅឃើញទៀត។

[១១:១៨:២៦]

សកម្មភាពហ្នឹងលោកបីប្អូនប្រាំថ្ងៃនៅតែដកសំណាបអ៊ីចឹងរាល់ថ្ងៃ ប្អូនខ្ញុំហើមភ្នែក ខ្លួនខ្ញុំអីហ្នឹងឈឺភ្នែកហើមអស់ទាំងអស់ តែយើងអត់ប៊ានទេ យើងអត់ប៊ាន យើងអត់មានពាក្យអីនិយាយទេ។ តែនៅថ្ងៃទី៥ ឪពុកខ្ញុំហ្នឹងដាច់ចិត្តនិយាយថា -- គាត់ជួបប្រធានភូមិនៅលើភ្លឺហ្នឹងក៏គាត់សុំសួរថា "ក្មួយណ្ហើយ បើសិនជាពូសុំក្មួយទៅរកឪពុកម្ដាយនៅខេត្តកំពង់ធំ តើក្មួយសម្រេចចិត្តថាម៉េច?" ប្រធានភូមិហ្នឹងគេឆ្លើយថា "ខ្ញុំអត់សម្រេចឲ្យពូទេ តែខ្ញុំទៅសួរថ្នាក់លើសិន" មួយភ្លែតឃើញដើរមានឈ្លបបីប្អូននាក់មកទៀត ឈ្លបហ្នឹងគេមកស្ដីឲ្យឪពុកខ្ញុំថា "ម៉េចមិត្តឯងចង់ទៅណាទៀតហើយ? ពួកមិត្តឯងនេះសុទ្ធតែពួកនាយទុន ចង់តែគេចវេះទេ ធ្វើការពលកម្មអីជាមួយប្រជាជន អង្គការដាក់ទិសអត់ចង់ទេ។ ឥឡូវមិនបាច់ទៅណាទេនៅធ្វើការហ្នឹងហើយ។ ចាំដល់ពេលណា ធ្វើការបានល្អទៅចាំហៅឪពុកម្ដាយអ្នកឯងឲ្យមកលេងអង្គការឲ្យមកហើយ"។ ពុកខ្ញុំឮពាក្យសម្ដីហ្នឹងគាត់ឈប់មាត់ គាត់អត់ប៊ាននិយាយអីទាំងអស់ គាត់ក៏អង្វរកូនថា "កូនខំធ្វើការទៅ តស៊ូទៅ កុំមាត់កុំកអីសោះ ចង់គេធ្វើអីធ្វើទៅ"។

ស្អែកឡើងមានពូម្នាក់ហ្នឹងនៅក្នុងភូមិហ្នឹង គាត់អ្នកនៅក្នុងមូលដ្ឋានហ្នឹង គាត់ដូចមានធម៌មេត្តាគាត់អាណិតក្រុមគ្រួសារខ្ញុំហ្នឹង គាត់មកខ្សឹបប្រាប់ឪពុកខ្ញុំ គាត់ថាគាត់ប្រាប់រឿងឲ្យឪពុកខ្ញុំមួយ ឲ្យឪពុកខ្ញុំដឹងខ្លួន ឲ្យរៀបចំត្រៀមលក្ខណៈព្រោះគេយកគ្រួសារខ្ញុំទៅសម្លាប់ចោលហើយ។ ឪពុកខ្ញុំសួរថាគាត់ខុសរឿងអី? បានពូគាត់ឆ្លើយថា មកឪពុកខ្ញុំនឹងជានាយទុនចង់យកកូនរត់គេចវេះមិនចង់ឲ្យនៅធ្វើនៅបញ្ចេញកម្លាំងពលកម្ម។ ឪពុកខ្ញុំភ័យថា ថាមិនដឹងមានមធ្យោបាយម៉េចដើម្បីយកក្រុមគ្រួសារចេញផុត? តែពូនោះគាត់ថាគាត់អាចជួយបាន។ ដោយជួយជម្លៀសពួកខ្ញុំហ្នឹងពេលយប់ឲ្យជិះទូក។ គាត់មានទូកមួយព្រោះគាត់ជាអ្នកនេសាទ។ ឪពុកខ្ញុំហ្នឹងក៏សម្រេចចិត្តអរគុណគាត់។ ហើយអ៊ីចឹងគាត់ថា ឥឡូវឲ្យរក្សាការសម្ងាត់ទាំងអស់គ្នាកុំឲ្យមាត់ឲ្យសោះដល់ពេលទៅៗតែម្តង។

[១១:២០:៥១]

យប់ហ្នឹងម៉ោងប្រាំបួន ម៉ោង ដប់យប់ងងឹត គាត់ក៏មកដាស់ពួកខ្ញុំហ្នឹងឲ្យនាំគ្នាទៅដល់ទូកហ្នឹង។ ខ្ញុំអត់ដឹងថាស្ទឹងអីទេលោក យប់ណាស់ ងងឹតណាស់ មិនដឹងភូមិស្អីជាស្អីទេ ខ្ញុំក៏ឡើងទូកហ្នឹងទៅចាសឪពុកខ្ញុំនៅកន្ទុយទៅគាត់នៅក្បាល ហើយពួកខ្ញុំស្រីៗ ហ្នឹងគ្រប កាប់ស្លឹកឈើហ្នឹងគ្រប គាត់គ្របពួកខ្ញុំនៅកណ្តាលទូកហ្នឹង។ ឲ្យឱនទាំងអស់ឲ្យដេកក្រាប ទៅឲ្យគ្របឲ្យជិតចាស។ ពេលទៅដល់ឆ្ងាយផុតពីកំពង់ហ្នឹងស្រាប់តែជួបវគ្គហ្នឹងទូករបស់ពួកឈ្លប គេប្រទ្រុយតាមមាត់ទឹកហ្នឹង។ គេក៏ស្រែកសួរទៅអ្នកម្ចាស់ទូកហ្នឹងព្រោះគេស្គាល់គ្នា។ គេសួរថា “មិត្តឯង ទៅណាហ្នឹង?” ពូម្ចាស់ទូកហ្នឹងឆ្លើយឡើងថា “ខ្ញុំទៅលើកលប”។ អស់លោក ពេលនោះក្រុមគ្រួសារខ្ញុំមហាសែនរន្ធត់លោកព្រោះលោកដឹងហើយបើគេអុំទូកហ្នឹងមកជិតទូកយើង យើងត្រូវស្លាប់។ ស្លាប់ទាំងអស់ ស្លាប់ទាំងម្ចាស់ទូកហ្នឹងស្លាប់ទាំងអស់។ តែដូចព្រះលោកជួយលោក។ ទឹកដោះម្តាយថ្លៃយ៉ាងម៉េចទេ ជួយរុញទូកហ្នឹងមិនឲ្យចូលមកជិតទូកយើងសោះ។ គេក៏ជិះហួសទៅ។ យើងនឹងភ័យលាយអរ លាយសព្វបែបយ៉ាងទាំងអស់។ ក៏ជិះក៏ហួសទៅទៀត។ គាត់ហ្នឹងខំអុំជាមួយឪពុកខ្ញុំហ្នឹងលោក អុំមែនទែន អុំទៅដល់ទួលមួយព្រៃ ឆ្ងាយណាស់ ឆ្ងាយមែនទែនហើយគាត់ក៏ប្រាប់ – ម្ចាស់ទូកប្រាប់ថា “ពូឡើងទៅ ឡើងចូលទៅក្នុងព្រៃហ្នឹងឲ្យជ្រៅកាន់តែជ្រៅកាន់តែល្អកុំងាកក្រោយវិញឲ្យសោះ ទៅមុខទៅបានសុខហើយ”។ ខ្ញុំក៏ឡើង ឪពុកខ្ញុំក៏ឡើងទៅ។

[១១:២២:៣៦]

ពេលនោះយប់ជ្រៅមែនទែនហើយអស់លោក។ ឪពុកខ្ញុំយកគ្រួសារខ្ញុំទាំងអស់ហ្នឹងយកទៅដាក់នៅកណ្តាលព្រៃមួយហ្នឹង ហើយព្រៃសុទ្ធតែរពាក់សុទ្ធតែស្អីលោកអើយ ហើយមុសៗដូចបាចអង្កាម។

ទឹកសន្សើមមុស។ ឪពុកខ្ញុំអត់ហ៊ានឲ្យកូនរើទេ សុខចិត្ត យកដៃហ្នឹងបូតមុសដែលខាំកូនហ្នឹងពេញអស់ ហើយចាំល្មមភ្លឺសួរគេសួររកផ្លូវចេញ។

ពេលភ្លឺស្រាងៗ ឪពុកខ្ញុំសម្លឹងទៅលើដើមត្នោតឃើញគេអ្នកឡើងត្នោតម្នាក់ ឪពុកខ្ញុំសួរថា អូន អើយ ក្មួយអើយ ពូហ្នឹងវង្វេងផ្លូវ សូមឲ្យក្មួយហ្នឹងយកពូឲ្យចេញផុតពីព្រៃផង។ គេក៏បង្ហាញផ្លូវក្រុមគ្រួសារខ្ញុំហ្នឹងឲ្យតម្រង់ទៅក្នុងភូមិមួយ។ ពេលហ្នឹងក្រុមគ្រួសារខ្ញុំទៅដល់ភូមិហ្នឹងគេក៏ជូនចូលទៅដល់ផ្ទះប្រធានភូមិទៀត។ ប្រធានភូមិនោះឆ្លើយឡើងថា គាត់មិនអាចឲ្យយើងនៅបានទេ ព្រោះយើងជាអ្នកថ្មី ជាគ្រួសារ១៧ អត់អាចឲ្យនៅបានទេ ព្រោះភូមិនេះសុទ្ធតែអ្នកមូលដ្ឋានចាស់។ អ៊ីចឹងឲ្យយើងបកឡើងទៅភូមិរកាកោង។ ពួកខ្ញុំអរ ក៏សូមអរគុណគេ ហើយគេក៏ជូនយើងទៅទៀត។ គេក៏ចិត្តល្អដោយដាក់យើងនៅក្នុងរទេះគោគ្របចំបើងបរតាមផ្លូវព្រៃ អត់ឲ្យឃើញអត់ឲ្យដើរទេ តែគ្រាន់តែគ្របយើងនៅក្នុងរទេះហើយ គ្របចំបើង ប្រាំមួយប្រាំពីរនាក់ហ្នឹង ចេះតែសម្ងំទៅធ្វើម៉េចឲ្យតែបានរស់។

[១១:២៤:១៣]

ពេលទៅដល់ភូមិរកាកោងហ្នឹង ឪពុកខ្ញុំបានសួរទៅគាត់ហ្នឹងថា ស្គាល់ឈ្មោះក្មួយគាត់អត់ ព្រោះឪពុកខ្ញុំមានក្មួយម្នាក់នៅរកាកោងហ្នឹង។ គេថាស្គាល់។ ដល់ពេលយើងទៅហ្នឹងគេអរណាស់ គេអបអរយើងទៅដល់ ព្រោះឃើញពូទៅដល់តែពេលដែលយើងទៅដល់ហ្នឹងគាត់ក៏សុំសួរប្រាប់យើងថា គាត់មិនអាចទទួលយើងនៅបានទេ ទាល់តែទៅប្រាប់ប្រធានភូមិទៀត។ ឪពុកខ្ញុំក៏សុខចិត្តទៅប្រាប់ប្រធានភូមិ។ ប្រធានភូមិថា ឲ្យនៅបាន ឲ្យអ្នកឯងចុះធ្វើពលកម្មជាមួយគេទៅ។ អង្គការដាក់ទិសយ៉ាងម៉េច ធ្វើតាមទៅ។ ឪពុកខ្ញុំយល់ព្រម។ ពេលយើងទៅនៅរកាកោង ព្រោះយើងមានផ្ទះបងប្អូនយើងនៅជាមួយគេ ក្រោមផ្ទះគេហ្នឹងសម្រាកនៅទីហ្នឹងទៅ។ ចាស ការហូបចុកអីហ្នឹងយើងមានតិចតួចជាប់នឹងខ្លួនហ្នឹង អង្ករអីៗហ្នឹងយើងចេះតែបបរស្ករ ហូបស្ករទៅតាមលទ្ធភាពដែលយើងមានហ្នឹង។

ដល់តែពេលហ្នឹងទៅបានតែ២ថ្ងៃទេ គេមកហៅឲ្យយើងទៅកាត់កក់។ ខ្ញុំអត់ស្គាល់កក់ម៉េចផងលោក គ្រួសារខ្ញុំទាំងអស់ អត់ស្គាល់កក់ទាំងអស់។ ស្គាល់តែប៉ា -- អ៎! ពុកមួយ ម្ដាយខ្ញុំទេ តែគាត់អត់បានប្រាប់កូនថា ពេលដែលច្រូតកក់ហ្នឹង តើមុតដៃរបៀបម៉េច? កក់ហ្នឹងដូចឡាម តែកាលណាយើងកាន់ខុស យើងច្រូតខុសរបៀបហ្នឹង វានឹងធ្វើឲ្យយើងមុតដៃដូចឡាមអ៊ីចឹង។ ប្អូនៗខ្ញុំមុតដៃហូរឈាមយំពេញបឹង ខ្ញុំអីហ្នឹង តែយើងធំៗនិយាយស្ដាប់គ្នាបាន។ ចុះវាតូច វានិយាយស្ដាប់ម៉េចបានលោក វាឈឺវា វាយំទៅ គេស្ដីបន្ទោសឲ្យឪពុកម្ដាយខ្ញុំហ្នឹងគ្រប់បែបយ៉ាងទាំងអស់។

[១១:២៦:00]

យើងនៅរកាកោងហ្នឹងកាប់កក់បានបីបួនថ្ងៃហ្នឹង បានគេប្រកាសទៀតហើយ គេបើកអង្គប្រជុំប្រកាសថា ក្នុងគ្រួសារមួយគ្រួសារឲ្យយើងទៅដឹកអំបិលខ្លួនឯង តែគេមានកង់ឲ្យយើងដឹក។ ពេលយើងទៅដឹកអំបិលហ្នឹងមក គេនឹងចែកឲ្យយើងពាក់កណ្ដាល តែប្រើរយៈពេល១៥ថ្ងៃ។ យកតាមលទ្ធភាពដែលយើងយកបាន ពេលនោះក្នុងគ្រួសារខ្ញុំ គ្មានអ្នកណាមើលទៅមាំទាំទេ មានតែខ្ញុំទេ ខ្ញុំអាច -- ខ្ញុំអាណិតឪពុកខ្ញុំពេក ខ្ញុំមិនឲ្យឪពុកខ្ញុំទៅទេ ខ្ញុំសុខចិត្តទៅខ្លួនឯង។ ពេលខ្ញុំជិះកង់ទៅដល់ស្រែអំបិលហ្នឹង ខ្ញុំវេទនាណាស់តាមផ្លូវ គឺមិនមែនយើងជិះលើផ្លូវថ្នល់ណាអស់លោក យើងជិះកាត់ព្រៃៗ ហើយយើងត្រូវធ្វើម៉េចឲ្យបានទាំងទៅទាំងមក១៥ថ្ងៃ។ យើងអត់ស្គាល់ថាផ្លូវណាវាជិត ផ្លូវណាវាម៉េចទេ យើងធ្វើម៉េចឲ្យតែថាទៅដល់ ហើយទៅដល់ស្រែអំបិលហ្នឹង ខ្ញុំ -- គេគ្រាន់ដល់ឃើញយើង យើងមានក្រដាសស្នាមអីហ្នឹង គេយកក្រដាសទៅមើលហើយ គេថាចូលទៅកើបអំបិលក្នុងឃ្លាំងទៅ! ហើយឲ្យប្រញាប់ចេញមកវិញ! អត់មាននៅឈរមើលវេរ៉ងអីលិចកើត ជើងត្បូងអី។ អ្នកឯងគ្មានសិទ្ធិឈរមើលអីទាំងអស់។ កើបហើយឡើងកង់ចេញទៅវិញភ្លាម។

[១១:២៧:៣០]

ពេលនោះ ខ្ញុំកើបមែនពិត តែភ្នែកខ្ញុំបានលួចមើលទៅចំហៀងខ្លួន មើលទៅស្រែអំបិលខ្ញុំឆ្លល់ឃើញប្រជាជនហ្នឹងធ្វើស្រែ ដែលធ្វើស្រែអំបិល គេកំពុងកាយអំបិលកាយអីហ្នឹង។ មានប្រជាជនធ្វើប៉ុន្តែនៅលើភ្លឺរបស់ស្រែអំបិលហ្នឹង គឺសុទ្ធតែយោធាដែលប្រដាប់ដោយអាវុធ ឈរវេរាដើរទៅដើរមក។ ចំណែកប្រជាជនហ្នឹង គឺនៅក្នុងស្រែអំបិលហ្នឹងធ្វើទៅ។ ខ្ញុំមិនបានពិនិត្យសកម្មភាពគេ តើគេត្រូវធ្វើម៉េច អីម៉េច? ខ្ញុំមិនប៊ានទេលោក។ ខ្ញុំក៏ប្រញាប់ធាត់កង់ចេញមកតាមផ្លូវ តាមផ្លូវខ្ញុំដាក់បានអំបិល៥០គីឡូ មុខហើយនិងក្រោយ។ លោកអើយខ្ញុំបន្តិចដួលផង ឯណាដៃដែលកាត់កក់ហ្នឹងវាហើម វាឈឺហើយវារលាកក្រលៀន និយាយប្រាប់លោកតាមត្រង់ គឺថាឈឺចាប់គ្រប់បែបយ៉ាងទាំងអស់ ដែលខ្ញុំមិនដែលជួបប្រទះទាល់តែសោះ។ តែខ្ញុំហេតុតែខ្លាចគេធ្វើបាបឪពុកម្ដាយខ្ញុំ ខ្ញុំសុខចិត្តចេញជួសគាត់។

ពេលខ្ញុំទៅដល់ផ្ទះខ្ញុំមានសភាពទ្រុឌទ្រោមអស់កម្លាំង គ្មានកម្លាំងកំហែងអីក្នុងខ្លួនបន្តិចណាទេ។ ពេលខ្ញុំយកអំបិលទៅឲ្យគេហ្នឹង គេយកអំបិលហើយហ្នឹង ខ្ញុំឃើញយោធាគេឲ្យអ្នកដែលលីអំបិលចូលហ្នឹង គ្នាលីអំបិលទៅគ្នាដួល យោធាហ្នឹងស្រែកថា "ម៉េចអា្ន! ធ្វើការប៉ុណ្ណឹងធ្វើមិនកើតទេអី្ន ពួកអានាយទុននេះ! យីពួកអាស្អែងនេះអា្ន ធ្វើការមិនកើតបានតែខ្សែតីនេះតើ!" តែនៅដៃគេមានខ្សែតីលោក

តែគេវាត់ទៅដី គេមិនបានវាត់ជនហ្នឹងទេ គេវាត់ទៅដី។ ដូចជាការគំរាម វាធ្វើឲ្យយើងអ្នកដឹកអំបិលនេះតក់ស្លុត។ ខ្ញុំភ័យណាស់លោក ខ្ញុំភ័យញ័ររកទីបំផុតគ្មានទេ។ ខ្ញុំខ្លាចគេណាស់ គេឲ្យអំបិលខ្ញុំមួយគីឡូ ខ្ញុំស្មានមើលទៅប្រហែលមួយគីឡូលោក ព្រោះមួយកញ្ចប់អីចឹង។

[១១:២៩:៤៣]

គេបានភរខ្ញុំប៉ុន្មានទេ ព្រោះគេថា យកមកគេចែកពាក់កណ្ដាល ខ្ញុំខំប្រឹងបាន៥០គីឡូ គេឲ្យខ្ញុំមួយគីឡូលោក។ ខ្ញុំកាន់អំបិលហ្នឹងយកទៅប្រាប់ឪពុកខ្ញុំ។ ឪពុកខ្ញុំប្រាប់ថា “កុំមាត់កូន បានប៉ុនណាក៏យកទៅកុំមាត់ឲ្យសោះ ទ្រាំទៅកូនទ្រាំទៅ”។ ពុកខ្ញុំតែងតែប្រើពាក្យថា ឲ្យខ្ញុំទ្រាំ ឲ្យខ្ញុំតស៊ូៗ រហូតលោក។ មិនឲ្យខ្ញុំនិយាយពាក្យស្អីសោះ។

យើងនៅបានបីបួនថ្ងៃទៀត គេប្រកាសទៀតហើយ គេប្រកាសថាឲ្យយកអ្នកថ្មីនៅក្នុងភូមិរកាកោងចេញពីភូមិហ្នឹងទាំងអស់។ ដោយអង្គការដាក់ទិសឲ្យទៅធ្វើស្រែនៅខេត្តពោធិ៍សាត់ និងបាត់ដំបង។ ព្រោះមិនខ្វះទេនៅ ស្រូវអង្ករនៅខេត្តបាត់ដំបង ពោធិ៍សាត់ ទាំងឃ្លាំងៗ ទាំងជង្រុក។ ទៅដល់ធ្វើទៅអង្គការនឹងចែករបបឲ្យអ្នកឯងហូបបាយឆ្ងាញ់ពេញលាក់ -- គ្រប់បែបយ៉ាង មានសាច់ មាន អ្ហ៎!មានផ្លែឈើមានអីទៀតលោក។ ខ្ញុំមិនជឿទេ ឪពុកម្ដាយខ្ញុំមិនជឿ ប៉ុន្តែមិនជឿក៏មិនបាន ព្រោះនេះជាទិសដៅដែលអង្គការដាក់ទិសដៅមកឲ្យយើងត្រូវតែទៅ។ អ្នកថ្មីត្រូវចេញពីភូមិរកាកោងទាំងអស់។ ពេលនោះគេចុះឈ្មោះហើយ គេប្រមូលយើងឲ្យចុះកាណូត។

[១១:៣១:០៣]

យើងជិះកាណូតពីរកាកោងហ្នឹងមកព្រែកតាម៉ាក់ខាងកើតភ្នំពេញនេះ មិនដឹងឈប់ត្រង់ណាទេលោក ហើយពេលនៅលើទូកហ្នឹងបានគួរឲ្យស្លុតទៅទៀត។ យោធាគេឈរបាំងជំទែងហ្នឹង ហើយក្មេងនោះវា នៅលើហ្នឹងមានចាស់ជរា មានក្មេងមានអី។ វាទារឃ្លានបាយ វាស្រែយំ ទាំងប្អូនខ្ញុំប្អូនគេ។ ស្រែកយំរកបាយរកអី យោធាគេគំហកថា “កូន-- ម៉េចអត់ចេះមើលទេហ៎? អញធាក់ទម្លាក់ទឹកងាប់ទាំងម៉ែទាំងកូនអស់ឥឡូវហ្នឹង!”។ អស់លោកពិចារណាមើល៍ សម្ដីស្អីគេហ្នឹង ដែលប្រើពាក្យសម្ដីហ្នឹង។ សម្ដីៗក្នុងរបបស្អីគេទេ ខ្ញុំមិនចេះដែរ ខ្ញុំដឹង។ តែមើលទៅគួរឲ្យរន្ធត់ណាស់ ញាប់ញ័រណាស់លោក។ គួរឲ្យស្លុតតែម្ដង គ្រាន់ឮសម្ដីហ្នឹង។ ម្ដាយហ្នឹងខំយកចានហ្នឹងដួសអាទឹកទន្លេដែលកំពុងជិះនៅលើទូកហ្នឹងដួសទឹកហ្នឹងឲ្យកូនផឹកទៅ ហើយលួងកូនកុំឲ្យយំ ឱបកូននឹងខ្លួន ដោយខ្លាចគេសម្លាប់កូនខ្លួនឯងបោះទៅក្នុងទឹក។

[១១:៣២:១២]

ពេលយើងឡើងទៅដល់ច្រាំងហ្នឹង មានឡានហ្សេអឹមសេ បីបួនប្រាំគ្រឿងតម្រៀបហើយស្រាប់។ គេចាប់យើងញាប់ចូលទៅក្នុងឡានហ្នឹង ពេញហើយគេចេញដំណើរមកវ៉ារទេះភ្លើង។ មកដល់វ៉ារទេះភ្លើងហ្នឹង ក្នុងបារ៉ុងដែលហ្នឹងមិនមែនជាកៅអី ពូកអីទេលោក ជាបារ៉ុងដែលគេដឹកជ្រូក ដឹកសត្វធាតុ។ គេបញ្ជូនយើង ស្មានទោស កាលហ្នឹងបើសិនជាឡានបែន គេបែនយើងដាក់ទៅក្នុងបារ៉ុងហ្នឹងបាត់ហើយ តែអត់មាន គេចាប់ញាប់ៗណែនហើយ គេរ៉ៃយកឈើដាក់កន្លឹះផ្តាប់ ខ្ទាស់ភ្ជាម។ ការបត់ជើងបត់ដៃអី គឺគ្មានទេ។ រទេះភ្លើងចេញហើយ ចេញទាំងយប់។

ដល់ទៅពេលដល់វ៉ាមួយ គេឲ្យយើងបត់ជើង តែគេថា “ពួកប្រុសៗឈរពីលើហ្នឹងបត់ជើងទៅ! ហើយស្រីៗចុះមក បត់ជើងម៉េចក៏ដោយ ឈរហ្នឹង!” ហើយគេភ្ជង់កាំភ្លើងពីលើយើងហ្នឹង។ យើងហ្នឹងភ្នែកចេះតែលួចមើលកាំភ្លើងគេ តែការបត់ជើងហ្នឹងស្ទើតែថាវាមិនចេញទៅវិញទៅហើយ ព្រោះវារន្ធត់នឹងអាកាំភ្លើងនៅខ្នងហ្នឹង កញ្ចឹងកនេះ។ គឺគ្រាន់តែបត់ជើងហ្នឹង ក៏គេគំរាមកំហែងយើងដែរ ក៏គេធ្វើបាបទុក្ខទោមម្នេញគ្រប់បែបយ៉ាងទាំងអស់។ គ្មានទឹក គ្មានបាយ អត់មានរបបអីទាំងអស់ នៅតាមរទេះភ្លើង នៅតាមស្ទីក៏ដោយ ក៏អត់មាន។

[១១:៣៣:៣៧]

ពេលទៅដល់វ៉ានៅពោធិ៍សាត់ហ្នឹង គេក៏ដាក់យើងចុះ ហើយគេឲ្យយើងឡើងឡានម្តងទៀត។ ទាំងយប់លោក គឺមិនដឹងម៉ោងប៉ុន្មាន អីម៉ោងប៉ុន្មានទេ គ្មានបាយគ្មានទឹកអីទេ ចេះទៅទីណាត់ទីណែងហើយ។ អ្នកណាមានគំនិតហ្នឹង មានដបមានអីហ្នឹង ចេះតែដួសទឹកទន្លេកាលដែលយើងជិះមកហ្នឹងហូបទៅ។ មកដល់វ៉ារទេះភ្លើងហ្នឹង គេឲ្យយើងឡើងទៀតហើយ ឡើងជិះឡានទៅតាមភូមិឃុំ។ គេចែកយើងតាមភូមិឃុំទាំងយប់ហ្នឹង។ ខ្ញុំទៅដល់ពោធិ៍សាត់ហៀបភ្លឺ។

គេក៏ឲ្យឡើងឡានហ្នឹងចេញទៅសហករណ៍ គេហៅថាសហករណ៍ពោធិ៍ពីរ ស្រុកកណ្តៀង។ ពេលទៅដល់ហ្នឹង ស្រុកសហករណ៍ពោធិ៍ពីរហ្នឹងជាព្រៃសុទ្ធសាធលោក។ ជាគុម្ពព្រេច គ្មានដីភូមិអីម៉ាបន្តិច។ ស្អែកឡើង គេឲ្យយើងពូថៅ ចបកាប់ ឲ្យយើងគាស់រុករានព្រៃហ្នឹង ធ្វើទីលំនៅខ្លួនយើងដោយខ្លួនឯង។ គេអត់មានជួយយើង ឧបត្ថម្ភយើងៗ ចេះធ្វើម៉េចបាននៅបានទៅ។ គ្រាន់តែគេចែកប្លង់ដីថា នេះមួយគ្រួសារដីប៉ុណ្ណេះ កន្លែងនេះ ថាអានោះនៅនោះទៀតតែប៉ុណ្ណឹងឯង។ យើងធ្វើទៅចាស។ ឪពុកម្តាយខ្ញុំហ្នឹងចេះតែគាស់គល់ នាំកូនគាស់ នាំគាស់គល់ទៅ។ គេចែកអង្ករដែរលោក ប្រាំនាក់មួយ

កំប៉ុងៗ។ ហើយគ្រួសារខ្ញុំប្រាំបីនាក់ហ្នឹង គេគិតទៅតាមហ្នឹងទៅ។ យើងហ្នឹងមិនប៉ានហូបបាយទេ ហូបបបរ បបរខាប់ៗទៅ មានអំបិលមានអី ហើយមើលទៅគ្មានបន្លែអីផងជុំវិញ សុទ្ធតែគុម្ពព្រេច។ គ្មានស្អីទេ ចេះតែហូបៗទៅលោក ហើយគាស់គល់ធ្វើលំនៅទៅ។ បានពីរបីថ្ងៃហ្នឹង គេក៏តាំងចាត់តាំងបំបែកយើងហើយ ឲ្យឪពុកខ្ញុំនៅរុករានព្រៃ ម្ដាយខ្ញុំត្រូវទៅនៅការដ្ឋានគេ ដោយរែកទឹកចាក់ទឹកដំណាំឲ្យគេ ធ្វើសព្វបែបយ៉ាង។

[១១:៣៥:៤២]

ចំណែកខ្ញុំត្រូវទៅនៅកងចល័ត បងស្រីខ្ញុំនៅកងចល័ត។ បងស្រីពីរនាក់សំណាងណាស់បាននៅកងចល័តភូមិ។ ចំណែកតែខ្ញុំគេដកឲ្យទៅកងចល័តពិសេសស្រុក ដើរចល័តតាមស្រុក ប្អូនខ្ញុំទៅនៅមណ្ឌលកុមារ។ ការព្រាត់ប្រាសនេះវាឈឺចាប់ណាស់លោក គ្មានទីលំនៅ គ្មានម្ហូបហារ ហូបហើយបែកបងប្អូនហើយ បែកឪពុកម្ដាយជាទីស្រឡាញ់ទៀត។ ខ្ញុំអត់ធ្លាប់ ខ្ញុំអត់ប្រទះ ដល់តែគេធ្វើខ្ញុំអ៊ីចឹង ខ្ញុំថាដូចជា ដូចមានអារម្មណ៍ថាដូចជាចង់ស្លាប់ណាស់ តែហេតុតែស្រឡាញ់ឪពុកម្ដាយ មើលមុខពេលដើរចេញទៅមើលមុខឪពុកម្ដាយភ្លៀកៗ។ ឪពុកខ្ញុំមើលមុខកូនដោយគ្មានពាក្យអីនិយាយទាំងអស់ គ្រាន់តែងក់ក្បាលជាសញ្ញាថាទៅៗកូន ទៅចុះ! តែប៉ុណ្ណឹង។

ខ្ញុំត្រូវគេឲ្យទៅកាប់ប្រឡាយនៅ ប្រឡាយសាលាគំរូក្នុងខេត្តពោធិ៍សាត់ហ្នឹងដែរ តែឆ្ងាយ។ ពេលខ្ញុំនៅហ្នឹងបានប្រហែលជា៣, ៤, ៥ខែដែរ។ យូរដែរលោក ខ្ញុំមិនដែលបានស្គាល់ផ្ទះម៉េចទេ ព្រោះគេអត់ឲ្យយើងមកទេ គេឲ្យយើងនៅសម្រាកនៅហ្នឹង តាមការដ្ឋានយើងហ្នឹង។ ស្រាប់តែខ្ញុំស្គាល់ពួកងរទេះមួយ គាត់មកខ្សឹបប្រាប់ខ្ញុំថា “ឪពុកអ្អែងឈឺធ្ងន់ហើយ ដេកទៅពេទ្យកណ្ដៀង។ អ្អែងមានពេលទៅអត់ ទៅសួរគាត់បន្តិចទៅអ្ហើយ!”។

[១១:៣៧:៣០]

ខ្ញុំភ័យណាស់ ខ្ញុំយំដូចស្អីនោះអ៊ីចឹង ខ្ញុំរន្ធត់ក្នុងចិត្តខ្ញុំ ល្ហិតល្ហៃដៃជើង ខ្ញុំក៏ទៅសុំ លើកដៃសំពះមេកងថា “បង ខ្ញុំសូមទៅមើលឪពុកខ្ញុំឈឺដេកនៅពេទ្យកណ្ដៀងបានអត់? --

**ប្រធានអង្គជំនុំ៖**

បាទ កុំអាលសិនលោកស្រី សូវណ្ណី! ព្រោះមានមេធាវីរបស់លោកស្រីបានងើបឡើង។ សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យនិយាយជាមួយកូនក្ដីខ្ញុំ ដើម្បីឲ្យកូនក្ដីខ្ញុំបានដោយ ពេលវេលាមានកំណត់ ដើម្បីឲ្យកូនក្ដីខ្ញុំសង្ខេបអង្គហេតុបន្តិចចាស។ សូមអនុញ្ញាតពីលោកប្រធាន។

[១១:៣៨:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ! ហើយពេលវេលាវានៅសល់តែ១០មីនុតទៀតទេសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ទាំងសេចក្ដីថ្លែង ទាំងការតាំងសំណួរផ្សេងៗ។

**លោកស្រី ជេត វណ្ណលី៖**

លោកស្រី សូវណ្ណី សូមលោកស្រីសង្ខេបរឿងឲ្យបានខ្លី ព្រោះពេលវេលានៅសល់តែ១០នាទីទៀតទេ។ សូមអរគុណលោកស្រី។ ចាស សូមបន្តទៀត ប៉ុន្តែសូមសង្ខេបបន្តិចចាស។

**លោកស្រី សូផាន់ សូវណ្ណី៖**

ខ្ញុំសូមនិយាយយ៉ាងខ្លី។ ពេលនោះខ្ញុំខំសូមគេ គេមិនឲ្យខ្ញុំទៅទេ។ ប៉ុន្តែពេលយប់ចប់ធ្វើការងារខ្ញុំរត់ ខ្ញុំលួចរត់ ខ្ញុំដាច់ចិត្តលួចរត់ទៅរកមើលឪពុកខ្ញុំ។ ពេលដែលទៅដល់ខ្ញុំឆ្លងទឹកស្ទឹង ទឹកស្ទឹងខែប្រាំងមិនជ្រៅទេលោក កាត់ព្រៃ ឆ្លងស្ទឹងដើម្បីទៅដល់ស្រុកកណ្ដៀងហ្នឹង។

[១១:៣៩:០៩]

ខ្ញុំពេលទៅដល់មន្ទីរពេទ្យហ្នឹង ខ្ញុំចូលទៅដល់ ខ្ញុំអរណាស់ ខ្ញុំរត់ចូលទៅដល់ឃើញឪពុកខ្ញុំ -- អត់មានឃើញឪពុកទេ ឃើញតែគ្រែ។ ខ្ញុំក៏សួរគេអ្នកជិតខាងថា “ឃើញឪពុកខ្ញុំអត់?” គេឆ្លើយឡើងថា “ឪពុកខ្ញុំស្លាប់ហើយ ឪពុកអ្អែងងាប់ហើយអ្អើយ ប៉ុន្តែមុននឹងងាប់ ឪពុកអ្អែងបានស្រែកដង្ហើយរកប្រពន្ធកូន”។ ហើយពេទ្យគេហ្នឹងគេថា គេមិនឲ្យជួបទេ ប្រពន្ធកូនអង្គការមើលហើយ មើលថែមិនបាច់ពួកឯងមើលទេ។ ខ្ញុំរន្ធត់ណាស់លោក ខ្ញុំទន់ដៃទន់ជើងអុកគូទទៅនឹងក្ដារហ្នឹង។ អង្គុយយំនឹកស្រណោះឪពុកម្ដាយ តែខ្ញុំមិនអាចនៅបានយូរទេ ខ្ញុំគ្រាន់តែបានយំ បានភ័យ បានរន្ធត់ សោកស្ដាយតែប៉ុណ្ណឹង គឺខ្ញុំបកម្ដាយ សូមម្ដាយខ្ញុំ ខ្ញុំមិនប៊ានទៅជិតផង។ ខ្ញុំរត់កាត់ទៅសមរភូមិវិញ។

បានតែប្រហែលជាពីរបីអាទិត្យក្រោយមកទៀត ឮដំណឹងទៀតហើយថា បងស្រីខ្ញុំឈឺស្លាប់។ បន្ទាប់មកប្អូនស្រីខ្ញុំពីរនាក់ឈឺស្លាប់។ តែទីកទីបញ្ចប់ ប្អូនប្រុសពៅខ្ញុំមួយហ្នឹង ខ្ញុំមានប្រុសពៅមួយអាយុ

៨ឆ្នាំ។ ពេលហ្នឹងគេប្តូរសមរភូមិខ្ញុំត្រូវដើរកាត់ភូមិ ខ្ញុំក៏សុំគេចូលទៅអើតប្អូនបន្តិច។ ពេលទៅដល់ហ្នឹង ខ្ញុំឃើញប្អូនខ្ញុំ គេឈើដេកនៅនឹងកន្ទេលហ្នឹង។ វាគ្រាន់តែឃើញខ្ញុំ ខ្ញុំស្រែកថា “បងអើយៗ បងឯងមកហើយអី បងឯងមកវិញ បងឯងមានបាយទេ? ឲ្យខ្ញុំសុំបាយញ៉ាំតែមួយម៉ាត់ទេបង ខ្ញុំងាប់ទៅបិទភ្នែកជិតហើយ”។ អស់លោក ខ្ញុំគ្មានទេ ខ្ញុំគ្មានស្អីទេ។ ឲ្យខ្ញុំធ្វើម៉េច បើខ្ញុំគ្មាន សូម្បីតែខ្លួនខ្ញុំគ្មានផង តើខ្ញុំមានស្អីដែលខ្ញុំយកទៅឲ្យប្អូនខ្ញុំ។ រួចហើយប្អូនខ្ញុំក៏ស្លាប់ទៅ។

[១១:៤១:៣៣]

ខ្ញុំទៅដល់គេដូរសមរភូមិខ្ញុំ ឲ្យខ្ញុំទៅសហករណ៍តាលោ គេដកខ្ញុំទៅកាប់ប្រឡាយនៅតាលោ។ ពេលដែលខ្ញុំទៅដល់កាប់ប្រឡាយនៅតាលោហ្នឹង ខ្ញុំ គេត្រូវឲ្យខ្ញុំវាស់ម៉ែត្រគូបគ្រប់បែបយ៉ាងទាំងអស់ គឺថាប្រឡាយហ្នឹងគឺត្រូវធ្វើយ៉ាងម៉េចឲ្យសម្រេចផែនការក្នុងមួយៗថ្ងៃ១០នាក់ហ្នឹង គឺឲ្យសម្រេចផែនការគេ។ បើគេដាក់១០ម៉ែត្រ ឬ២០ម៉ែត្រ គឺត្រូវតែធ្វើឲ្យសម្រេចឲ្យគេក្នុង១ថ្ងៃ។ ដល់ហើយហ្នឹងនៅហ្នឹងបានយូរបន្តិចទៅ គេក៏មានចេញផែនការឲ្យពួកខ្ញុំកងចល័តហ្នឹងចុចឈ្មោះហ្នឹងឲ្យទៅចាប់អារម្មណ៍នៅសហករណ៍វិញ ដោយមានកង់រទេះមកយើងទៅចាប់អារម្មណ៍នៅសហករណ៍។ ពេលដែលយើង-- ពេលហ្នឹងខ្ញុំមានអារម្មណ៍ថា ខ្ញុំប្តេជ្ញាចិត្តថាមិនទៅដាច់ខាត ទោះមួយជំហានស្លាប់ក៏ខ្ញុំមិនទៅដែរ។ តែខ្ញុំត្រូវធ្វើម៉េច? ខ្ញុំមានមធ្យោបាយសួរពូកងរទេះថា ពូជួយខ្ញុំទៅ ឲ្យខ្ញុំរត់រួចផុតពីការចាប់អារម្មណ៍អីហ្នឹង។ គាត់ថាមិនដឹងជួយម៉េចទេ? គាត់តែជួយអ៊ីចេះ “អ្អែងជិះរទេះក្រោយទៅ? ហើយកាលពេលចេញទៅ អ្អែងលោតទៅនឹងព្រៃទៅ អ្អែងធ្វើម៉េចរួចខ្លួនបានអ្អែងធ្វើទៅ ពូអត់ដឹងទេ”។ គាត់និយាយអ៊ីចឹង។ ពេលហ្នឹង ខ្ញុំឡើងលើរទេះហ្នឹង ខ្ញុំ -- ពេលគេចេញដំណើរយប់ម៉ោងបីយប់ហ្នឹង ខ្ញុំក៏លោតចុះពីលើរទេះដីហុយហ្នឹងលោក ខ្ញុំលោកចុះពីហ្នឹង ខ្ញុំដើរចូលទៅក្នុងព្រៃ ដើរតម្រង់។ ខ្ញុំចេះតែដើរទៅ ខ្ញុំមិនស្គាល់ផ្លូវព្រៃអីផង។ ដើរៗទៅ ដើរចាក់ឡើងមកលើចាក់មកសមរភូមិដំណាក់ឈើក្រំនៅលើភ្នំក្រវាញនេះវិញ។

[១១:៤៣:១៩]

ចាស ពេលទៅដល់ដំណាក់ឈើក្រំហ្នឹង ខ្ញុំក៏សួរគេទៀត សួរថាគេហៅអីអាហ្នឹង គេថាហៅដំណាក់ឈើក្រំ។ ខ្ញុំក៏ស្គាល់សហករណ៍មួយ មេសហករណ៍មួយ ខ្ញុំក៏សុំលើកដៃសុំ គាត់ក៏សួរថា “មិត្តឯងមកពីណា?” ខ្ញុំភរគេថា ខ្ញុំ គេឲ្យមកកាប់ឈើ តែខ្ញុំវង្វេងផ្លូវ។ ឥឡូវខ្ញុំអត់ដឹងទៅ ផ្លូវទៅសមរភូមិខ្ញុំទៅត្រង់ណាវិញទេបង។ សូមបងឯងជួយខ្ញុំទៅ។ “ថាអើ! បើអ៊ីចឹងនៅត្រង់ណាក៏ធ្វើការឲ្យអង្គការ

ដែរ" មិត្តហ្នឹងគេថាអ៊ីចឹង។ ខ្ញុំអរណាស់ពេលគេនិយាយអ៊ីចឹង។ គេឲ្យខ្ញុំចូលទៅជីកប្រឡាយនៅដំណាក់ឈើក្រំហ្នឹង។

ពេលទៅធ្វើប្រឡាយនៅដំណាក់ឈើក្រំហ្នឹង អស់លោក វេទនាណាស់ ព្រោះជើងភ្នំមានថ្ម។ ដើម្បីធ្វើម៉េចឲ្យបែកថ្មហ្នឹង គេឲ្យយុវជនហ្នឹងកាប់ឈើខ្លុងហ្នឹងងាប់ៗហ្នឹង យកមកដាក់គរហើយដុត។ ដុតដល់ក្ដៅទៅប្រេះ គេឲ្យមិត្តនារីរែកទឹកពីស្ទឹងយកមកចាក់ ដើម្បីឲ្យវាប្រេះទៅ យកដែកស្នែងហ្នឹងបុកគាស់ដុំថ្មហ្នឹងចេញពីមាត់ប្រឡាយ។ ពេលនោះលោកដឹងទេ ឈើស្នែងដែកលោក ដែកស្នែងបុកហ្នឹងដែក ចាស។ យើងក្ដាប់ថ្ងៃដំបូងអត់អីទេលោក ក្ដាប់យូរទៅៗលោក គ្រាន់តែក្ដាប់អ៊ីចឹងគឺឈាមហូរបែកពងពេញដៃទាំងអស់។ ខ្ញុំត្រូវហើមដៃហ្នឹង បែកសុទ្ធតែឈាម ដំបៅពេញដៃទាំងអស់។ តែខ្ញុំអត់ប៊ានឈប់ទេ ខ្ញុំអត់ប៊ានស្រែកយំ ខ្ញុំអត់ប៊ានស្អីទាំងអស់ ខ្ញុំត្រូវតែធ្វើ។ ខ្ញុំត្រូវតែធ្វើខ្ញុំត្រូវតែស៊ូរស់ ព្រោះឪពុកខ្ញុំមុននឹងស្លាប់ គាត់បានផ្ដាំថាកូនត្រូវតែតស៊ូរស់។ ដូច្នេះ ខ្ញុំត្រូវតែតស៊ូរស់ ព្រោះខ្ញុំនៅម្នាក់ឯងខ្ញុំអស់ ខ្ញុំទៅ ខ្ញុំនៅម្ដាយខ្ញុំ នៅម្ដាយមួយ។

[១១:៤៥:០៩]

ពេលខ្ញុំបែកដៃបែកជើងខ្ញុំមិនប៊ានមាត់ទេ។ គេឲ្យយើងជីកប្រឡាយហ្នឹង ដើម្បីគាស់ថ្មចេញទូលផង រែកផងលោក ធ្វើសព្វបែបយ៉ាងវេទនាណាស់។ ដល់ពេលហ្នឹងទៅនៅក្នុង-- ពេលនោះនៅក្នុងសមរភូមិហ្នឹងខ្ញុំឃើញសភាពការណ៍បួនប្រាំយ៉ាងដែលគួរឲ្យខ្ញុំភ័យរន្ធត់ ចងចាំមួយជីវិត ដល់ថ្ងៃខ្ញុំស្លាប់ទៅទៀតក៏ខ្ញុំអត់ភ្លេចដែលលោក។ មានកងចល័តខ្ញុំធ្វើការជាមួយគ្នាហ្នឹងតែនាងហ្នឹងក្មេង អាយុប្រហែលបីបួនប្រាំដណ្ដប់ឆ្នាំ។ ខ្ញុំមិនដឹងថានាងហ្នឹងលាក់ខ្សែកផ្កាកទីនហ្នឹងសសៃតូចមួយ ហ្នឹងនៅក្នុងចង្កេះពីអង្កាល់ខ្ញុំអត់ដឹងទេ។ តែពេលដែលនាងហ្នឹងកាប់ដីទៅធ្វើឲ្យមេកងគេឃើញ គេអត់មាត់ទេថ្ងៃហ្នឹង។ ស្អែកឡើងស្រាប់តែមានឈ្លបបីនាក់មកហៅនាងហ្នឹងទៅ។ ទៅៗដើរមិនមែនដើរចូលទៅក្នុងការដ្ឋានទេ ដើរចេញទៅព្រៃតែម្ដង។ ហើយបាត់នាងនោះរហូត។ ពេលល្ងាចឡើងពេលចប់ការងារនោះពួកខ្ញុំក៏នាំគ្នាទៅលបមើល ឃើញគេកប់នាងហ្នឹងអត់ជិតទេ នៅជើងលើដីហ្នឹង កប់ជាប់ខ្លួន នៅជើងលើដី។ បានខ្ញុំដឹងអូ!គ្រាន់តែរឿងខ្សែកប៉ុណ្ណឹង។ ហើយវាបាននិយាយទៀត ឈ្លបហ្នឹងវាដើរ មកនិយាយថា "ពួកមិត្តឯងកុំឲ្យមានគំនិតអាប្រតិកិរិយានាយទុននៅចង់បានរបស់ទ្រព្យទុកក្នុងខ្លួន បើអង្គការឲ្យយកចេញ យកចេញឲ្យអស់ពីខ្លួនទៅ កុំកម្មសិទ្ធិក្រាស់អីទៀតណាប្រយ័ត្ន មេរៀនមានហើយ"។

[១១:៤៧:០៥]

មិនទាន់បានប៉ុន្មានផងលោក។ មានរឿងមួយទៀតនៅក្នុងការដ្ឋានហ្នឹងមានរឿងរហូត។ មានបងហ្នឹងគាត់ចាស់ជាងខ្ញុំអាយុ២០ជាង គាត់ដឹងបានដំឡូងហ្នឹងពីណាមកយកមកដុតហូប។ ពេលដែលគាត់ដុតហ្នឹងគាត់ដុតហើយហ្នឹងគាត់ហូបបានពីរម៉ាត់។ ដល់ពេលគាត់ហូបបានពីរម៉ាត់ហ្នឹងស្រាប់តែកងឈ្លបគេមកទាន់។ គេសួរថា មិត្តឯងបានដំឡូងហ្នឹងពីណាមក? គាត់ឆ្លើយបិបឹៗគេក៏ចាប់គាត់ចងស្លាបសេកយកទៅចំកន្លែងពួកខ្ញុំធ្វើការហ្នឹងទាំងអស់គ្នាហ្នឹង។ ហើយគេយកកៅស៊ូ ដូចកៅស៊ូភ្លៀងអ៊ីចឹង គេយកមករុំគាត់អ៊ីចឹងទៅគេចងខ្លួនហើយ។ ឈ្លបហ្នឹងបីនាក់។ ព្រនង់ឈើគេប៉ុនៗកដៃយើងគេវៃពីក្រៅកៅស៊ូហ្នឹង វៃមួយផាំងអ៊ីចឹងទៅគាត់ដួល។ ហើយគេវៃៗទាល់តែប្រកាច់ៗ ទាល់តែឈប់ឈប់ប្រកាច់ទៀត។ ពេលហ្នឹងគេស្រាយ គេស្រាយកៅស៊ូហ្នឹងចេញ។ ទិដ្ឋភាពដែលពេលដែលគេស្រាយកៅស៊ូហ្នឹងចេញ អស់លោកដឹងទេ ឈាមបែកវល់ សក់ រូបមនុស្សយើងមើលលែងដឹងថាជាមនុស្ស។ គាត់ស្លាប់បាត់ហើយគាត់បែកខ្ទេចអស់។ ហើយគេអូសសពហ្នឹងដូចឆ្កែអ៊ីចឹង អូសយកទៅព្រៃទៅ ហើយគេគំរាមយើងថា “នេះជាមេរៀន ជាគំរូទុកឲ្យមិត្តឯងរាល់គ្នាហ្នឹងមើលកុំឲ្យត្រាប់តាមហ្នឹង។ ព្រោះវាមិនល្អទេ មីមិត្តហ្នឹងវាក្បត់អង្គការ វាហ៊ានមានដំឡូងហូប!”។

[១១:៤៨:៣៣]

ចាស មួយទៀតមិត្តនារី សាន ហ្នឹងខុសសីលធម៌។ គាត់ពេទ្យ។ គាត់ធ្វើការនៅក្នុងការដ្ឋានជាមួយខ្ញុំហ្នឹង។ គាត់ទៅខុសសីលធម៌ទម្ងន់ដល់ទៅ៧ខែ។ ខ្ញុំអត់ដឹងទេ។ ចាស ស្រាប់តែថ្ងៃមួយហ្នឹងគាត់មកលាខ្ញុំព្រោះខ្ញុំស្គាល់គាត់។ គាត់ថា “មិត្តអើយ មិត្តនី ខ្ញុំទៅសហករណ៍វិញហើយ”។ ខ្ញុំសួរបើបងទៅសហករណ៍អ៊ីចឹងអ្នកណានៅមើលពេទ្យនេះ? គាត់ថា “មានគេអ្នកផ្សេងមកជំនួស”។ ខ្ញុំមិនដឹងថាគេនិយាយស្អីទេ ស្រាប់តែពេលគាត់ទៅ គាត់ហ្នឹងមិនមែនទៅទេចាស។ ស្រាប់តែព្រឹកព្រលឹមឡើងឃើញឈ្លបបីនាក់ហ្នឹងលីចប មានកាំបិតខ្វែវ មួយដើរទៅក្នុងព្រៃ ខ្ញុំហ្នឹងក៏លបៗ ខ្ញុំលបលួចទៅលួចមើលតែម្តង។ ខ្ញុំដាច់ចិត្តលបលួចមើលតែឆ្ងាយ មិនមែនមើលជិតទេ។ ទៅដល់ឃើញឲ្យគាត់កាប់ដីកាប់ដីត្រឹមជង្គង់ហ្នឹង។ កាប់ដីហើយសម្រាតខោអាវអស់ យកចបកាប់ហ្នឹងវៃពីក្រោយកញ្ចឹងកហ្នឹងគាត់ធ្លាក់ទៅក្នុងរណ្តៅហ្នឹងទៅ ហើយវៃទៀត វៃៗទាល់តែស្លាប់។ ពេលស្លាប់ហ្នឹងទៅកូននៅក្នុងពោះហ្នឹងវាកម្រើកៗ។ អ្នកដែលកាន់ផ្គាក់ស្ទុះយកកាំបិតហ្នឹងមកវះពោះហ្នឹងយកកូនហ្នឹងចេញមក ហើយយកចិញ្ច្រាំ ហើយចោលពាក្យថា “មីនេះប៉ុនធ្វើកូនណាស់វី! ដល់ឥឡូវឲ្យទៅនៅជាមួយគ្នាវាទៅ”។ តើវាសាហាវប៉ុនណា វាយង់ឃ្នងវាព្រៃផ្សៃប៉ុនណាអស់លោក។ មនុស្សណាលោកមិនមែនសាច់ជ្រូកទេ

ដាក់ចិញ្ច្រាំដូចសាច់ជ្រូកអ៊ីចឹង មើលទៅខ្ញុំស្លុតរន្ធត់ណាស់លោក។

[១១:៥០:២៦]

ពេលដែលខ្ញុំមកដល់ការដ្ឋានវិញ មានរឿងមួយទៀត ដែលគាត់ហ្នឹងជាមេកង គាត់រាង -- គេហៅគាត់ថា មេកងបារាំង១ តែគាត់ស្រី។ គេឱ្យគាត់ចាប់អារម្មណ៍ជាមួយនឹងមេសហករណ៍គ្នាគេហ្នឹង តែគាត់អត់ព្រម ដល់គាត់អត់ព្រមអ៊ីចឹងគេវាស់ដីឱ្យគាត់។ វាស់ដីឱ្យគាត់ហ្នឹងជីកប្រឡាយហ្នឹងឱ្យហើយក្នុង១ថ្ងៃហ្នឹង បើមិនហើយទេគាត់ -- គេសម្លាប់គាត់។ ចៃដន្យអីគាត់ហ្នឹងរែកដី រែកហ្នឹងរែកមិនរួចទេ ដល់ពេលនុ៎ងគាត់ភ្លាត់ជើងធ្លាក់ពីលើភ្លឺទៅហ្នឹងថ្លោះជើងទៅអត់បានសម្រេចផែនការលោក។ ពួយយើងនៅជីកប្រឡាយខែនេះ តែគាត់នៅខាងស្ដាំដៃយើងឆ្ងាយប្រហែលជា១០០ម៉ែត្រអីហ្នឹង។ យើងមើលទៅឃើញ យើងចេះតែលួចមើលហ្នឹង។ ពេលហ្នឹងល្ងាចហើយ ពួកយើងធ្វើហើយពួកយើងរៀបនឹងដើរចេញអស់ហើយ ស្រាប់តែក្រលេកទៅឮសូរកាំភ្លើងផាំង១។ បានន័យថា គេសម្លាប់គាត់នៅក្នុងរណ្ដៅដែលគាត់ជីកហ្នឹង ព្រោះគាត់អត់បានសម្រេចផែនការឱ្យគេ។

ហើយពេលដែលខ្ញុំជីកប្រឡាយនៅ ប្រឡាយដំណាក់ឈើក្រំហ្នឹង ជិតចុងបញ្ចប់ហើយលោកខ្ញុំឃើញគេដឹកអ្នកបូព៌ាហ្នឹងពីរឡាន។ ក្នុងមួយឡានហ្នឹងមានអ្នកបូព៌ាហ្នឹងប្រហែលជា៣០នាក់ លោកគេមិនចងមិនអីទេ គេឱ្យចុះពីលើឡានគេដើរសំដៅទៅឡើងទៅលើអ៊ីចេះវិញ ព្រោះយើងជីកប្រឡាយដេញមកក្រោម។ គេឱ្យដើរឡើងទៅលើចាស។ ហើយខ្ញុំសួរគេនៅជិតនុ៎ង ខ្ញុំសួរគេថា "គេយកមនុស្សទៅណា?" គេថា"យកឡើងទៅលើនោះ ទៅធ្វើការនៅលើនោះ"។ តែទៅបាត់ឈឹងលោក ទៅបាត់ឈឹង។ រួចពីបាត់ឈឹងហ្នឹងស្អែកឡើងឃើញគេប្រមូលស្បែកជើង ឃើញគេប្រមូលខោអាវហើយនិងក្រមាឡើងមួយកំភ្លុស។ បានយើងសន្និដ្ឋានថាគេយកអ្នកបូព៌ាហ្នឹងទៅសម្លាប់នៅដំណាក់ឈើក្រំហ្នឹងចំនួនពីរឡាននេះ។

[១១:៥២:៣៦]

លោកឆាកជីវិតខ្ញុំសែនកំសត់មែនទែន ព្រោះអត់ឪពុកហើយ អត់បងប្អូនទៀត ខ្ញុំនៅម្ដាយមួយនៅផ្ទះបាយ ខ្ញុំនៅសមរភូមិ ខ្ញុំទទួលដំណឹងថា ម្ដាយខ្ញុំឈឺធ្ងន់ទៀតហើយ ខ្ញុំរត់ពីសមរភូមិ ខ្ញុំលួចរត់ -- សុទ្ធតែលួចរត់លោក លួចរត់ពេលយប់។ ខ្ញុំលែងខ្លាចស្លាប់ហើយ ខ្ញុំរត់មកមើលម្ដាយខ្ញុំ។ ខ្ញុំឮគេប្រាប់ថា ម្ដាយខ្ញុំហ្នឹងគេឱ្យថ្នាំពេទ្យ ពេទ្យគេហ្នឹងឱ្យថ្នាំត្រកួនទែកលោក។ ហ៊ឺះ! ដាំត្រកួនទែកឱ្យម្ដាយខ្ញុំៗហូប។ ម្ដាយខ្ញុំហូបត្រកួនទែកហ្នឹងហើយ រាកដេកផ្ទាល់នឹងកន្ទេលហ្នឹង ខ្ញុំមិនដឹងថា គេហេតុអីគេឱ្យដាំ

ត្រកូនទែកឲ្យម្ដាយខ្ញុំហូបទេចាស។ គាត់រាកដល់ស្លាប់លោក។ ខ្ញុំអស់ហើយលោក ខ្ញុំអស់ឪពុកម្ដាយ អស់បងប្អូន អស់ទីពឹង អស់ស្អីៗរលីងពីក្នុងខ្លួន។ ខ្ញុំគ្មានស្អីទៀតទេលោក ទុក្ខវេទនារបស់ខ្ញុំ ខ្ញុំមិនអាចរៀបរាប់ប្រាប់អស់លោកថាពេលហ្នឹងខ្ញុំលំបាកប៉ុនណា។ ខ្ញុំវេទនា ខ្ញុំឈឺចាប់ប៉ុនណា ខ្ញុំអត់អាចនិយាយបានលោក។

[១១:៥៤:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សូវណ្ណី ហើយជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះលោកស្រី សូវណ្ណី បាទ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំ ឌេល លីសាក់ ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំមានសំណួរតែពីរបីជូនលោកស្រីទេសម្រាប់ព្រឹកនេះ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរបស់លោកស្រី លោកស្រីថា នៅស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ហើយនៅក្នុងឃុំស្រែស្តុក។ សំណួររបស់ខ្ញុំជូនលោកស្រី គឺថាតើលោកបានដឹងកន្លែងមួយទេ ថាកន្លែងមួយឈ្មោះ ទួលពោធិ៍ជ្រៃនៅក្នុងតំបន់មួយដែលនៅជិតឃុំនោះដែរ។ បាទ បើសិនជាលោកស្រីស្គាល់ពីទួលពោធិ៍ជ្រៃនោះ ថាតើមានរឿងរ៉ាវអីដែលលោកស្រីបានដឹងពីកន្លែងនោះដែរឬទេ?

**លោកស្រី សូផាន់ សូវណ្ណី៖**

**ឆ៖** ចាស ខ្ញុំសូមជម្រាបលោកមេធាវីថា ខ្ញុំនៅភូមិពោធិ៍ពីរស្រុកកណ្ដៀងហ្នឹង ចំណែកឯទួលពោធិ៍ជ្រៃហ្នឹង គឺនៅឆ្ងាយពីៗភូមិដែលខ្ញុំនៅ។ តែខ្ញុំគ្រាន់តែដឹងថា ភូមិទួលពោធិ៍ជ្រៃហ្នឹង គេបានយកពួកយោធាទៅសម្លាប់នៅទីនោះ តែត្រង់ថាយ៉ាងម៉េច ព្រោះខ្ញុំអត់ដឹង។ ព្រោះពេលហ្នឹងលោកដឹងស្រាប់ហើយ គេមិនមែនឲ្យយើងដឹងរឿងរ៉ាវអីច្រើនទេ ព្រោះយើងជាជនរងគ្រោះដែរ យើងគេឲ្យយើងកងចល័ត យើងគិតតែពីធ្វើការងារ។ គេមិនឲ្យយើងដឹងរឿងស្អីដែលជាស្អីទេ។ គេឲ្យដឹងតែយើងទៅធ្វើការទៅ។ ធ្វើម៉េចឲ្យតែធ្វើការពេញតួនាទីឲ្យអង្គការល្អទៅបានហើយ។ គេមិនឲ្យយើងរឿងស្អីទៀតទេ។

រឿងទួលពោធិ៍ជ្រៃនេះ ខ្ញុំដឹងដែលពេលយើង ពេលរំដោះរួច៧៩នេះទេ បានខ្ញុំដឹងថាមានទួលពោធិ៍ជ្រៃហ្នឹង។

[១១:៥៦:៤៣]

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយ។ សំណួរមួយទៀតអំពីទីកន្លែងមួយផ្សេងទៀត ជនជាប់ចោទនៅក្នុងរឿងក្ដីនេះ បាននិយាយថាមូលហេតុមួយដែលគេត្រូវជម្លៀសប្ដូរទីតាំងប្រជាជនចេញពីភ្នំពេញនោះ គឺដើម្បីឲ្យពួកអ្នកភ្នំពេញនោះ មានអាហារគ្រប់គ្រាន់។ តើលោកស្រី និងសមាជិកក្រុមគ្រួសារមានអាហារគ្រប់គ្រាន់ហូបទេនៅគ្រប់កន្លែងដែលលោកស្រីដែលបានគេជម្លៀសទៅនោះពីកន្លែងមួយទៅកន្លែងមួយនោះ តើមានអាហារហូបគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបលោកថា បើសិនជាការជម្លៀសហ្នឹងទៅ មានម្ហូបអាហារហូបចុកគ្រប់គ្រាន់ឪពុកម្ដាយ បងប្អូនខ្ញុំមិនស្លាប់ទេលោក មិនស្លាប់ទេ។ គ្មានម្ហូបអាហារ ហើយគ្មានអង្ករ ហើយគ្មានថ្នាំសង្កូវ គ្មានអ្វីៗទាំងអស់លោក។

[១១:៥៧:៥៥]

**លោក ខេល លីសាក់៖**

សូមអរគុណលោកស្រីដែលលោកស្រីបានអញ្ជើញមកថ្ងៃនេះ។ ខ្ញុំយល់ថាគឺជាការលំបាកណាស់។ នេះជាសំណួរដែលខ្ញុំអាចសួរ ហើយខ្ញុំសូមអរគុណដែលលោកស្រីបានចំណាយពេលមកពេលនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន យើងខ្ញុំមិនមានសំណួរអ្វីសួរទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន បាទ។

[១១:៥៨:៤២]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ក្នុងនាមលោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

អរគុណលោកស្រី សូវណ្ណី។ ការស្តាប់លើសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាព ទុក្ខសោកវេទនា ស្ថានភាពព្យសនកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សុភមង្គល។ ហើយលោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ។

[១១:៥៩:៣៣]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី សូវណ្ណី វិលត្រឡប់ទៅកាន់ទីកន្លែងដែលជាគោលដៅគាត់មានបំណងចង់ទៅ ឬក៏ទៅទីលំនៅដ្ឋានរបស់គាត់វិញចុះ!

ហើយអង្គជំនុំជម្រះសូមជម្រាបថា នៅរសៀលនេះអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការស្តាប់សក្ខី -- សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប គឺ TCCP-170 និង TCCP-117។

ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងម្ភៃនាទីសូមអញ្ជើញចូលវិញ។ សូមភាគីនៃរឿងក្តី បុគ្គលិកគាំទ្រដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅពីក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុខម៉ោងមួយនិងម្ភៃនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១២:០០នាទី ដល់ម៉ោង ១៣:២២ នាទី)*

[១៣:២២:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី TCCP-170 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៣:២៤:១៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី! តើលោកឈ្មោះអី?

**លោក យិន រំដួល៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ យិន រំដួល។

**ស៖** បាទ អរគុណលោក យិន រំដួល។ តើលោកមានថ្ងៃខែឆ្នាំកំណើត ថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** បាទ សូមគោរពលោកប្រធាន ខ្ញុំសូមជម្រាបអំពីថ្ងៃខែឆ្នាំកំណើតរបស់ខ្ញុំបាទបន្តិច។ ការពិតខ្ញុំកើតនៅឆ្នាំ១៩៦៥ មកទល់ពេលនេះអាយុ៤៨ឆ្នាំហើយ។ តែក្រោយឆ្នាំ១៩៧៩ ពាក់ព័ន្ធទៅនឹងការសិក្សារបស់ខ្ញុំ នាយកសាលាពេលនោះ គាត់បានប្ដូរឲ្យខ្ញុំដាក់នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៦៩។

**ស៖** បាទ អរគុណលោក រំដួល។ តើលោកមានទីកំណើតកន្លែងណា? ទីកន្លែងណា?

**ឆ៖** បាទ លោកប្រធាន! ខ្ញុំមានទីកន្លែងកំណើតនៅសង្កាត់លេខ៥ រាជធានីភ្នំពេញ។

**ស៖** អរគុណ ហើយសព្វថ្ងៃនេះ លោកមានទីលំនៅនៅទីកន្លែងណា? ហើយលោកប្រកបមុខរបរអ្វី?

**ឆ៖** អរគុណលោកប្រធាន។ សព្វថ្ងៃ ខ្ញុំរស់នៅខេត្តសៀមរាប នៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ មានមុខរបរជារាជការ។

[១៣:២៦:០៧]

**ស៖** បាទ អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី? ហើយម្ដាយបង្កើតរបស់

លោកឈ្មោះអី? ហើយប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ សូមអរគុណលោកប្រធាន។ ឪពុករបស់ខ្ញុំបាទ លោក យិន ស៊ីដារ៉េត។ ម្ដាយខ្ញុំបាទ ឈ្មោះលោកស្រី គីម ឈន។ ខ្ញុំមានភរិយា។ មានកូនពីរនាក់ក្នុងបន្ទុក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក យិន វំដួល នៅក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងឱកាសឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោក ជាអាទិ៍ដូចជា ការខូចខាតខាងផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈ ដូចជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានឡើងពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ននេះ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

សូមអញ្ជើញ!

**លោក យិន វំដួល៖**

បាទ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាទីគោរព។ និងសូមគោរពអង្គសវនាការទាំងមូល ព្រមទាំងប្រិយមិត្ត មិត្តបរទេសទាំងអស់ ដែលមានវត្តមាននៅក្នុងទីនេះ។

[១៣:២៨:០៥]

ខ្ញុំបាទ យិន វំដួល ជាអតីតកុមារកំព្រានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមរំឭកថា នៅក្នុងឆ្នាំ១៩៧៥ ក្នុងវ័យអាយុ១០ឆ្នាំ ខ្ញុំបាទជាកុមារម្នាក់ដែលមានការបីបាច់គ្រងពីលោកឪពុកអ្នកម្ដាយដ៏ត្រឹមត្រូវបំផុត ហើយក្នុងឋានៈជាកូនដ៏មានគុណធម៌ម្នាក់ចំពោះឪពុកម្ដាយក្នុងវ័យសិក្សា។ ពេលនោះ ខ្ញុំបានរៀនក្នុងថ្នាក់ទី៩ចាស់ នៅក្នុងសម័យសាធារណរដ្ឋខ្មែរ។ ឆ្នាំ១៩៧៥ ថ្ងៃទី១៧ មេសា ខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ នៅវេលាម៉ោងប្រាំបួនព្រឹកនៅរោងកុនចេនឡា ហើយផ្ទះខ្ញុំបាទនៅទួលស្វាយព្រៃកៀកនឹងរោងកុនចេនឡាន។ ព្រឹត្តិការណ៍ទាំងអស់នោះ ខ្ញុំបានជិតជាប់នៅក្នុងខួរក្បាលដល់សព្វថ្ងៃ។ ពេលដែលឃើញកងទ័ពខ្មែរក្រហមស្លៀកពាក់ខ្មៅបានមកដល់ទីក្រុងភ្នំពេញ ខ្ញុំបានក៏បានចូល

រួមអបអរសាទរជាមួយនឹងកងទ័ពខ្មែរក្រហមដែរ ក្នុងឋានៈកុមារ ពេលនោះ ខ្ញុំមិនបានដឹងអ្វីទាំងអស់។ ខ្ញុំដឹងតែពីឃើញកងទ័ពច្រើន ខ្ញុំសប្បាយចិត្ត ហើយក៏ខ្ញុំបានឃើញនូវមាមីងបងប្អូនទាំងអស់ ជនរួមជាតិទាំងអស់បានលើកទង់ស ហើយបានជជែក និងពិភាក្សាគ្នាថា “យើងមានសន្តិភាពហើយ” ខ្ញុំនៅចងចាំនូវព្រឹត្តិការណ៍នេះ។

[១៣:២៩:២៨]

ពេលនោះ ខ្ញុំក៏បានចូលរួមមើលរថក្រោះ និងគ្រប់កាំភ្លើងតូចធំទាំងអស់ដែលខ្មែរក្រហមបានវាយចូលទីក្រុងភ្នំពេញនៅពេលនោះ។ នៅពេលដែលខ្ញុំបានឃើញនូវព្រឹត្តិការណ៍នោះ ខ្ញុំក៏បានវិលមកផ្ទះរបស់ខ្ញុំបាទវិញ។ នៅប្រហែលជាម៉ោងដប់ទៅដប់មួយ សាមសិបនាទីថ្ងៃត្រង់ ខ្ញុំបានឮស្នូរកាំភ្លើងបាញ់នៅតាមដងផ្លូវ នៅក្បែរសាលារៀនទួលស្វាយព្រៃដែលខ្ញុំសិក្សា។ ពេលដែលព្រឹត្តិការណ៍នៃការបាញ់នោះ ខ្ញុំនៅក្មេង ខ្ញុំមានការរន្ធត់ខ្លាំងណាស់ ហេតុអ្វីគេបាញ់រឿងអ្វី ខ្ញុំអត់យល់។ ខ្ញុំឃើញកងទ័ពខ្មៅ អាវខ្មៅ មានមួរជើងខោ មានខ្លះ មានចងកន្សែងក្រហម ហើយស្ពាយអាកាបាញ់ឡើងលើៗ។ នៅពេលដែលបាញ់ឡើងលើហ្នឹង ប្រជាជនដែលនៅក្នុងផ្ទះហ្នឹងមានការរន្ធត់បំផុត។ ខ្ញុំជាកុមារភាព ខ្ញុំសួរទៅម្តាយខ្ញុំថា មានរឿងអីម៉ាក់? នៅពេលនោះ ខ្ញុំហៅអ្នកម្តាយរបស់ខ្ញុំ គឺម៉ាក់ មិនហៅ ម៉ែ ដូចសម័យ ប៉ុល ពត ទេ។ ខ្ញុំ ម្តាយខ្ញុំ គាត់ថាកូនម៉ាក់ក៏មិនដឹងអីដែរ។ ព្រឹត្តការណ៍កើតឡើង គឺបាញ់ចូលផ្ទះមួយនៅទល់មុខផ្ទះរបស់ខ្ញុំ នៅក្បែរសាលារៀនទួលស្វាយព្រៃហ្នឹង។ ពេលនោះ មានទាហានម្នាក់ដែលខ្ញុំចាំ ប៉ុន្តែខ្ញុំមិនបានចាំឈ្មោះគាត់។ គាត់បាញ់បោះតបវិញ។ ព្រឹត្តិការណ៍ប្រហែល៥នាទីក្រោយមក ឃើញខ្មែរក្រហមមានគ្នាកម្លាំងប្រហែលជាប្រាំនាក់ ទៅ១០នាក់ បានបាញ់ផ្ទប់ចូលមុខផ្ទះខ្ញុំតែម្តង។ ពេលនោះហើយមិនដឹងថាសោកនាដកម្មនៃការកាប់សម្លាប់ ការបាញ់ប្រហាររបស់ខ្មែរក្រហម។ កងទ័ពខ្មែរក្រហមទៅលើផ្ទះនោះយ៉ាងដូចម្តេចទេ។ ខ្ញុំមិនបានដឹង។ នេះជាបញ្ហាមួយដែលខ្ញុំចង់ជម្រាបទៅអង្គសវនាការ។

[១៣:៣១:១៤]

យប់ឡើងគ្រួសារខ្ញុំមានជីដូន និងជីតា។ ជីតារបស់ខ្ញុំគាត់ជាមនុស្សដែលពិការមួយចំហៀងខ្លួនដោយសារគាត់មានជំងឺ។ ពេលហ្នឹងយើងមិនទាន់បានចេញពីទីក្រុងភ្នំពេញទេ។ នៅក្នុងឱកាសនោះខ្មែរក្រហមបានបាញ់សំដៅមកផ្ទះខ្ញុំ ខ្ញុំគ្រាន់តែនៅចងចាំថា គ្រាប់ដែលបាញ់ចូលផ្ទះខ្ញុំ ប្រហែលជាគ្រាប់អាកា ឬអឹមសិ។ ប៉ុន្តែប៉ុន្មាននាទីក្រោយមក ដោយសារយើងមិនបានចេញ យើងនៅសម្ងំក្នុងផ្ទះ។ មុនហ្នឹងបន្តិច ជីដូនរបស់ខ្ញុំ -- ខ្ញុំនៅចាំ -- គាត់អុជចង្កៀងក្រោយពីអត់មានអគ្គិសនី។ ពេលដែលឃើញភ្លើ

ចង្រៀងនោះ ខ្មែរក្រហមស្រែកសួរថាហេតុអ្វីបានជាផ្ទះអ្នកឯងមិនចេញ? ពេលនោះហើយ ខ្មែរក្រហមបានបាញ់កាំភ្លើងធំ។ ខ្ញុំប្រហែលជាការប៉ាន់ស្មានរបស់ខ្ញុំ ប្រហែលជាមិនគ្រាប់សីវេនធីណៃ ឬក៏បេ។ ពេលនោះបាញ់បុកនឹងជញ្ជាំងផ្ទះ។ ខ្ញុំ និងម្ដាយខ្ញុំ និងក្រុមគ្រួសារខ្ញុំ បងប្រុសរបស់ខ្ញុំ ឪពុកមារបស់ខ្ញុំសម្រេចចេញពីទីក្រុងភ្នំពេញនៅពេលនោះ។

[១៣:៣២:១៤]

ក្រោយពីចេញមក នៅតាមដងផ្លូវខ្ញុំបានដើរកាត់នៅក្នុងជាកុមារ ខ្ញុំបានដើរកាត់តាមផ្លូវពេទ្យចិនទៅព្រះមុនីវង្ស ខ្ញុំបាទឃើញនូវសោកនាដកម្មជាច្រើននៅពេលដែលយប់នោះ។ ព្រលឹមឡើង ខ្ញុំបានដឹងអំពីបញ្ហាកើតចេញពីអំពើយង់ឃ្នងរបស់របបខ្មែរក្រហម ក្នុងនាមជាកុមារម្នាក់។ ពេលដែលខ្ញុំទៅដល់ច្បារអំពៅម៉ោងប្រាំពីរព្រឹក ខ្មែរក្រហមបានឆែកសួរបងប្រុសរបស់ខ្ញុំ និងបងជីដូនមួយរបស់ខ្ញុំថា "ឯងជាអ្វី?" បងខ្ញុំបានប្រាប់ថាគាត់ជាសិស្ស។ បើឯងជាសិស្ស ឯងយកកាតមកឲ្យយើង? ពេលនោះបងប្រុសរបស់ខ្ញុំក៏បានយកកាតនិស្សិតឲ្យគាត់។ ពេលដែលយកកាតសិស្សឲ្យគាត់ បានគាត់ឲ្យរួចខ្លួន។

ក្រោយបានចេញពីក្បាលថ្នល់មក យើងក៏ទៅផ្ទះរបស់ម្ដាយខ្ញុំ ផ្ទះរបស់ជីតាខ្ញុំដែលមាននៅព្រែកឯង។ ក្រោយពីសំណាក់នៅព្រែកឯងមិនបានប៉ុន្មានថ្ងៃផង យើងឃើញថាសភាពការណ៍នៃការរស់នៅក្នុងស្រុកព្រែកឯង ពុំមានអ្វីគួរឲ្យទទួលយកបានទេ។ ពីព្រោះយើងគ្មានស្បៀងអាហារ។ មនុស្សស្លាប់នៅតាមដងទន្លេ តាមផ្លូវ។ អ៊ីចឹងម្ដាយខ្ញុំ និងឪពុកខ្ញុំ (សូមទោស) ម្ដាយខ្ញុំ និងបងប្រុសខ្ញុំត្រូវដាក់បង្ខំចិត្តទៅរកស្រុកកំណើតខាងម្ដាយនៅក្នុងឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

[១៣:៣៣:៣១]

ក្រោយពីបានផ្លាស់ខ្លួនពីព្រែកឯង ពីស្រុកកំណើតរបស់ជីតារបស់ខ្ញុំទៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ខ្មែរក្រហម មេភូមិ មេបក្សនៅក្នុងតំបន់ភូមិកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មិនបានឲ្យយើងនៅស្ងៀមទេ ពីព្រោះគេដឹងអំពីសាវតារនៃក្រុមគ្រួសារខ្ញុំ។ ពីព្រោះឪពុកខ្ញុំជាសាស្ត្រាចារ្យផង និងជានាយទាហានជាន់ខ្ពស់នៅក្នុងសម័យសាធារណរដ្ឋខ្មែរផង។ អ៊ីចឹងហើយគេក៏ជម្លៀសខ្ញុំចេញពីឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ទៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល នៅក្នុងភូមិមេបាំង។ ព្រឹត្តការណ៍ទាំងអស់នេះ ខ្ញុំចងចាំបានទាំងអស់។ ខ្ញុំដើរជាមួយនឹងឪពុក ដើរជាមួយនឹងម្ដាយខ្ញុំ បងខ្ញុំ ជីដូនខ្ញុំ ជាមួយនឹងជីតារបស់ខ្ញុំដែលពិការមួយចំហៀងខ្លួន យកអូសរទេះទៅ។

ក្រោយពីរស់នៅក្នុងភូមិមេបាំង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ អស់រយៈប៉ុន្មានខែកន្លងមក កងទ័ពខ្មែរក្រហម ឬក៏មេភូមិ មេឈ្លបខ្មែរក្រហម ក៏ជម្លៀសយើងចេញពីភូមិមេបាំង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលនេះទៀត។

ព្រឹត្តការណ៍នៃការជម្លៀសនេះយើងឃើញថា មានភាពស្មុគស្មាញ ហើយមនុស្សរាប់ពាន់នាក់ រាប់ម៉ឺននាក់ត្រូវបានជម្លៀសចេញពីភូមិមេបាំង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មកឈប់នៅឃុំព្រែកប្រសព្វ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល នៅតាមដងទន្លេ។ នៅពេលនោះខ្ញុំឃើញទូកកាណូតជាច្រើនបានចតតម្រៀបជួរគ្នានៅតាមមាត់ទន្លេច្រាំង។ នៅពេលនោះខ្មែរក្រហមក៏ចាប់បង្ខំឲ្យយើងខ្ញុំ ក្រុមគ្រួសារយើងខ្ញុំឡើងកាណូតជិះមកភ្នំពេញ។ ពេលនោះខ្ញុំមិនដឹងថា ភ្នំពេញយ៉ាងម៉េចទេ ព្រោះខ្ញុំនៅក្មេងខ្ញុំមិនទាន់មានការចងចាំច្បាស់លាស់។ ក៏ប៉ុន្តែពេលដែលយើងបានឆ្លងដំណើរពីភ្នំពេញកាត់តាមព្រែកព្នៅ។ ពេលដែលខ្ញុំមកដល់ ភ្នំពេញខ្ញុំបានឃើញព្រឹត្តិការណ៍នៅភ្នំពេញវេលាខ្ទង់ជាម៉ោងបីរសៀល។ ម៉ោងបីរសៀលនៅភ្នំពេញ នេះខ្ញុំឃើញទិដ្ឋភាពនៅភ្នំពេញនេះគឺស្ងប់ស្ងាត់មែនទែន។ ពេលនោះខ្ញុំមានវ័យខ្ទង់ជាជាង១០ឆ្នាំហើយ។ ហើយប៉ិះនឹងក្រឡាប់ទូកទៀតដោយសារអី ដោយសារប្រជាជនទាំងអស់ដែលមិនបានឃើញទីក្រុងភ្នំពេញ ហើយបានជ្រួលច្របល់នាំគ្នាមើលទីក្រុងភ្នំពេញ។

[១៣:៣៦:០៩]

អង្គសវនាការជាទីគោរព! ក្រោយពីបន្តដំណើរ ទៅដល់ព្រែកព្នៅខ្ទង់ជាម៉ោងប្រាំពីរយប់ ខ្មែរក្រហមក៏ចាប់បង្ខំឲ្យក្រុមគ្រួសារយើងខ្ញុំនឹងប្រជាជនជម្លៀស ចេញពីតាមដងទន្លេឡើងរថយន្តទៅខេត្តពោធិ៍សាត់ទៀត។ សូមជម្រាបថានៅពេលដែលយើងឡើង រថយន្តនោះខ្មែរក្រហមបានភ្ជង់យើង ជីតារបស់ខ្ញុំដែលជាជនពិការត្រូវចាប់បង្ខំឲ្យឡើងរថយន្តពេលនោះ ម្តាយខ្ញុំគាត់បាននិយាយថា បើយើងយកតាទៅយើងនឹងមានពិបាក។ តែជីតារបស់ខ្ញុំគាត់ថា "មិនចាំបាច់លើកឪពុកទៅទេ" -- ខ្ញុំនៅចាំសម្តីនេះ -- ទុកឲ្យគាត់ស្លាប់ទីនេះចុះ។ ប៉ុន្តែទឹកចិត្តម្តាយនិងកូន និងឪពុក ត្រូវតែ លើកជីតារបស់ខ្ញុំដាក់លើរថយន្តជាបន្ទាន់។ ដើម្បីមានឱកាសទៅទាំងអស់គ្នា។ បន្តដំណើរទៅដល់ខេត្តពោធិ៍សាត់ទាំងយប់ទាំងថ្ងៃ។ ទៅដល់ខេត្តកំពង់ឆ្នាំង ខ្ញុំបានជួបព្រឹត្តិការណ៍មួយពេលនោះរថយន្តរបស់ខ្មែរ ក្រហមឆេះខាងមុខ។ ពេលនោះខ្មែរក្រហមប្រហែលជាគ្នាជាង១០នាក់បានចុះទៅស្រ អមដោយអាវុធជាច្រើនដើម។ ខ្ញុំនៅស្ងៀម នៅក្នុងទ្រូងម្តាយខ្ញុំមិនឲ្យចុះទេ។ ពេលនោះខ្ញុំមានភាពរន្ធត់ខ្លាំងណាស់ ដោយសារអី? ដោយសារយើងជាកុមារយើងមិនបានដឹងអ្វីៗទាំងអស់។

[១៣:៣៧:៤២]

បន្តមកទៀត ក្រោយពីការរៀបចំរបស់កងឈ្លបដែលអមដំណើរដោយកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនចេញពីឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល បន្តទៀតនោះ យើងក៏បន្តដំណើរទៅដល់ស្រុកបាកានខេត្តពោធិ៍សាត់។ ពេលនោះខ្ទង់ជាម៉ោងប្រាំពីរព្រឹក គេទម្លាក់យើងនៅគេហៅថាវ៉ានៅត្រាំខ្នារ នៅបឹងខ្នារ គេហៅថា ថាវ៉ាបឹងខ្នារ។ បន្ទាប់ពីចុះនៅវ៉ាបឹងខ្នារហើយ គេក៏ដាក់រទេះយើងទៅក្នុងរទេះឲ្យទៅឃុំព្រះម្លូ និងឃុំមេទឹកស្រុកបាកានក្រោមខេត្តពោធិ៍សាត់។ ក្រោយពីបានទៅនៅឃុំមេទឹក ក្នុងភូមិអូរព្រាល ខ្ញុំបាទពេលនោះមានការបែកបាក់ក្រុមគ្រួសារទាំងអស់។ ខ្ញុំទៅនៅជាមួយនឹងកងកុមារ។ ម្ដាយខ្ញុំទៅនៅដោយឡែក។ ជីដូនខ្ញុំនៅផ្ទះ។ ជីតាខ្ញុំនៅនឹងជាមួយជីដូនខ្ញុំ។ បងប្រុសបងស្រីខ្ញុំ ឪពុកមាខ្ញុំត្រូវបែកបាក់ទាំងអស់ចេញពីក្រុមគ្រួសារ។ ភាពឈឺចាប់របស់ខ្ញុំគឺបង្កឲ្យខ្ញុំមានការសោកសៅជាខ្លាំង។ នៅពេលនោះហើយខ្ញុំមិនដែលបែកពីម្ដាយ មិនដែលបែកពីបង មិនដែលបែកពីឪពុក ប៉ុន្តែខ្ញុំត្រូវរងទណ្ឌកម្មក្នុងការបែកបាក់នេះ។

[១៣:៣៩:១៣]

លោកប្រធានជាទីគោរព! អង្គសវនាការជាទីគោរព! នៅពេលដែលខ្ញុំបាទបានទៅនៅក្នុងជំរំកុមារត្រូវគេធ្វើទារុណកម្មខ្ញុំបាទដូចសត្វធាតុ ធ្វើឲ្យខ្ញុំឈឺចាប់។ គេវ៉ៃខ្ញុំដោយសារខ្ញុំលួចដំឡូង ខ្ញុំលួចអំពៅគេ ពីព្រោះខ្ញុំស្រេកឃ្លាននូវអ្វីដែលខ្ញុំមិនទាន់បានទទួលទាន។ ភាពរបស់ខ្ញុំគឺឈឺចាប់នៅពេលដែលខ្ញុំទទួលនូវអ្វីៗដែលខ្ញុំពីដើមមិនដែលទទួលសោះ។ សោកនាដកម្មនេះខ្ញុំចងចាំជានិច្ច។ គេធ្វើបាបខ្ញុំគេចងខ្ញុំ គេវ៉ៃបំបែកចិញ្ចើមខ្ញុំរហូតមកទល់សព្វថ្ងៃ។ ខ្ញុំរត់មករកម្ដាយ។ ម្ដាយខ្ញុំពុំមានលទ្ធភាពឱបក្រសោបកូនទេ។ ឈ្លបរបស់កងកុមារបានចាប់ខ្ញុំយកទៅវិញរហូតទៅដល់ខ្ញុំបែកចេញពីម្ដាយ។ ភាពឈឺចាប់របស់ខ្ញុំនៅពេលដែលខ្ញុំព្រាត់ពីម្ដាយ ខ្ញុំចុកចាប់ប៉ុនណា? លោកប្រធានមានកូន អង្គសវនាការទាំងមូលមានកូនមានចៅលោកជ្រាបហើយ។ នេះជាអ្វីដែលខ្ញុំចង់លើកឡើង។

បន្ទាប់មកទៀត នៅពេលដែលខ្ញុំបែកចេញពីម្ដាយ ខ្ញុំស្រេកឃ្លានខ្ញុំបានទៅលួចសំណាបគេ។ នៅពេលយប់មួយខ្ញុំបានទៅលួចសំណាបគេ ដែលកំពុងតែសាបពីល្ងាច យប់ឡើងខ្ញុំទៅលើយសំណាបយកមកទទួលទានទាំងស្រូវ ទាំងដីនៅក្នុងមាត់។ នៅពេលនោះ ជាសោកនាដកម្មមួយដែលខ្ញុំឈឺចាប់នៅក្នុងជីវិតរបស់ខ្ញុំត្រូវមេភូមិម្នាក់បានមកចាប់វ៉ៃខ្ញុំ ទាត់ធាក់ខ្ញុំ រហូតប្រគល់ឲ្យខ្ញុំទៅកងឈ្លប។ ពេលនោះម្ដាយខ្ញុំនៅក្នុងមន្ទីរពេទ្យ។ កងឈ្លបគេយកខ្ញុំទៅ ពេលនោះម្ដាយខ្ញុំមិនទាន់បានដឹងរឿងអ្វីទេ ហើយ

គាត់សួរខ្ញុំថា "កូនមានរឿងអី?" ខ្ញុំបានប្រាប់ម្ដាយខ្ញុំថា ខ្ញុំបានលួចសំណាបគេត្រូវមេភូមិ មេឈ្លបចាប់បានហើយម៉ាក់។ សូមទោសម៉ែ។

[១៣:៤១:៣៣]

ក្រោយពីបានចាប់ខ្ញុំចងជាប់ហើយ ម្ដាយខ្ញុំក្នុងឋានៈជាម្ដាយនិងកូន គាត់ថាបើចាប់កូនគាត់ក៏ដូចចាប់ខ្ញុំដែរៗ។ នៅពេលនោះ ខ្ញុំត្រូវបានកងឈ្លបបណ្ដើរជាមួយនឹងម្ដាយទៅគុកនៅក្នុងឃុំមេទឹក ស្រុកបាកានក្រោម ខេត្តពោធិ៍សាត់។ ការរស់នៅក្នុងឃុំឃាំង មន្ទីរឃុំឃាំងនៅក្នុងមេទឹកនេះ ខ្ញុំមានភាពលំបាកខ្លាំងណាស់ ពីព្រោះខ្ញុំស្គម ហើម។ លោកប្រធានជ្រាបហើយ ពោរពេញទៅដោយការអត់អាហារ ខ្ញុំអត់មានអ្វីទទួលទាន។ ខ្ញុំទៅដល់ គេវ៉ៃខ្ញុំសន្លប់ម្ដងនៅក្នុងគុកហ្នឹង។ ព្រឹកឡើងគេឲ្យខ្ញុំងើបឡើងដើម្បីសួរចម្លើយ ខ្ញុំត្រូវទទួលទារុណកម្មទៀត។ ហើយគេចាប់បង្ខំឲ្យខ្ញុំជាកុមារទៅធ្វើការយ៉ាងទម្ងន់ កាប់ដី ជីកប្រឡាយ ដកស្ទូង។ ខ្ញុំគ្មានអ្វីទាំងអស់។ ពេលនោះ ក្រោយពីការធ្វើទារុណកម្មយ៉ាងឃោរឃៅរបស់កងទ័ពខ្មែរក្រហម និងកងឈ្លបខ្មែរក្រហម និងរបបដឹកនាំរបស់ខ្មែរក្រហម ថ្ងៃមួយមេបក្ស មេភូមិកងទ័ពខ្មែរក្រហម គេបានកោះប្រជុំគ្នាថា "បើសិនជាគ្រួសារណាមួយរត់ចេញពីគុកគេនឹងកម្ទេចគ្រួសារនេះចោល"។

[១៣:៤៣:០៥]

នៅពេលនោះ ខ្ញុំក៏បានឆ្លៀតឱកាសពិភាក្សាជាមួយម្ដាយថា "ម៉ាក់ បើម៉ាក់នៅក៏ស្លាប់ កូននៅក៏ស្លាប់ អ៊ីចឹងតើម៉ាក់គិតយ៉ាងម៉េច?" ម្ដាយខ្ញុំគាត់បានគិតថា "កូនត្រូវតែរត់នៅក្នុងពន្ធនាគារនោះ"។ នៅពេលដែលខ្ញុំចាប់ផ្ដើមយកខួរក្បាលគិត ខ្ញុំនឹងរត់ ខ្ញុំក៏បានសម្រេចចិត្តសួរម្ដាយម្ដងទៀតថា "ម៉ាក់អនុញ្ញាតឲ្យកូនទៅទេ? គាត់ឆ្លើយថា "ត្រូវតែទៅកូន បើសិនជាកូនទៅកូនអាចមានសំណាងនឹងរស់ ប៉ុន្តែម្ដាយខ្ញុំត្រូវស្លាប់ក្នុងរបប ប៉ុល ពត។ នៅពេលដែលខ្ញុំបានរត់ចេញពីគុកនៅម៉ោងប្រាំបីយប់ ពេលដែលមានភ្លៀង និងផ្លូវជិតខាង -- និងពេលដែលឈ្លបខ្មែរក្រហមបានប្ដូរវេនគ្នាយាម។ ហើយកាលណោះយើងនៅក្មេង យើងនៅតូចស្គម វាមិនអាចសូវចាប់អារម្មណ៍ដូចមនុស្សចាស់ទេ។ ខ្ញុំសម្រេចចិត្តរត់ទាំងយប់ក្រោមការឃុំឃាំងរបស់ខ្មែរក្រហម។ ខ្ញុំមិនបានដឹងថា ម្ដាយខ្ញុំស្លាប់នៅពេលដែលខ្ញុំរត់ចេញពីគុក។ ខ្ញុំបានរត់ចេញពីគុកនៅម៉ោងប្រាំពីរប្រាំបីយប់នៅពេលដែលភ្លៀងខ្លាំង ខ្ញុំសម្រេចចិត្តថាខ្ញុំត្រូវតែរត់ គឺខ្ញុំតាមបណ្ដាំរបស់ម្ដាយខ្ញុំ។

[១៣:៤៤:៣៨]

ពេលដែលខ្ញុំចាប់ផ្តើមរត់ ខ្ញុំមិនបានងាកក្រោយទេ ខ្ញុំសម្រុកយ៉ាងម៉េចឲ្យទៅដល់ភូមិអូរព្រាល ដែលជីដូនរបស់ខ្ញុំរស់នៅ កាត់កន្លែងខ្មោចកប់ច្រើនណាស់លោកប្រធាន។ ខ្ញុំកុមារ ខ្ញុំខ្លាចក៏ប៉ុន្តែខ្ញុំតាំងស្មារតីក្នុងនាមកូនពៅម្នាក់ក្នុងចំណោមបងប្អូនបីនាក់។ ពេលខ្ញុំទៅដល់ភូមិ ជួបនឹងជីដូននិងម្តាយមីងបង្កើត។ ខ្ញុំបានរាយរ៉ាប់រឿងអតីតកាលដែលពាក់ព័ន្ធទៅនឹងការសោកនាដកម្មនៅក្នុងគុក គេធ្វើបាបមកលើរូបខ្ញុំ និងម្តាយខ្ញុំ។ ពេលនោះ ខ្ញុំជម្រាបម្តាយមីងខ្ញុំថា "អ្នកមីង ម៉ាក់ឲ្យទៅយកអីវ៉ាន់បន្តិចបន្តួចដែលនៅជាប់នឹងចង្កេះរបស់គាត់"។ ប៉ុន្តែជាការអកុសលរបស់ខ្ញុំ នៅពេលដែលម្តាយមីងរបស់ខ្ញុំបានចេញដំណើរទៅសួរមន្ទីរឃុំឃាំងនៃដែលដាក់ពន្ធនាគារម្តាយខ្ញុំ គេបានប្រាប់ថាម្តាយខ្ញុំត្រូវស្លាប់តាំងពីម៉ោងបីទៅហើយ។ ខ្ញុំចុកចាប់ណាស់លោកប្រធាន ខ្ញុំចុកចាប់ជាទីបំផុត។ ក្នុងឋានៈជាកូនម្នាក់ ខ្ញុំយំ ខ្ញុំថាហើយជីវិតខ្ញុំ ខ្ញុំស្រែកទ្រហោយំ ជីដូនម្តាយមីងលួងចិត្ត គេនឹង -- ប៉ិះនឹងសម្លាប់ម្តាយមីងខ្ញុំទៀត។ គេថា "មិត្តនារីឯងមកធ្វើអី? ចង់ស្លាប់ដូចបងមិត្តនារីឯងដែរឬទេ?" ពេលនោះហើយ ដែលខ្ញុំទទួលនូវសោកនាដកម្មយ៉ាងកំសត់ក្នុងឋានៈជាកូនខ្មែរម្នាក់ ហើយជាកុមាររងគ្រោះ ដែលដឹកនាំដោយលោកខៀវ សំផន និង អៀង សារី នេះ និង ប៉ុល ពត, នួន ជា នេះ។ ខ្ញុំចុកចាប់ណាស់ ខ្ញុំសូមជម្រាបលោកប្រធាន។

[១៣:៤៦:៣១]

កាលពីឪពុកម្តាយខ្ញុំ ម្តាយខ្ញុំបានសម្លាប់នៅក្នុងគុក ម្តាយមីងក៏បានប្រាប់។ ខ្ញុំគិតថា ពេលនោះគេនឹងតាមសម្លាប់ខ្ញុំទៀត ពីព្រោះគេថាគេនឹងកម្ទេចទាំងអស់។ បន្តមកទៀត ខ្ញុំក៏បានចេញពីភូមិទៅជួបនឹងបងប្អូនជីដូនមួយរបស់ខ្ញុំដែលជាកងដឹកជញ្ជូន ខ្ញុំក៏ទៅសុំបងថា "បង ខ្ញុំអស់ទីពំនឹងហើយ"។ ពេលនោះ បងរបស់ខ្ញុំបានទៅទាក់ទងមេកងដឹកជញ្ជូនម្នាក់ឈ្មោះ ពូតឿ ដែលជាមានគុណក្នុងការសង្គ្រោះជីវិតខ្ញុំ។ ពេលនោះដោយសារខ្វះអ្នកឃ្វាលគោក្របី គាត់ក៏សម្រេចចិត្តឲ្យខ្ញុំនៅជាមួយនឹងកងដឹកជញ្ជូនពេលនោះ។ នៅពេលដែលខ្ញុំរស់នៅក្នុងកងដឹកជញ្ជូនក្នុងនាមជាកុមារ គេនឹងប៉ុនប៉ងយកសម្លាប់ច្រើនលើកច្រើនសាចំពោះខ្ញុំ ប៉ុន្តែត្រូវបាន ពូតឿ ជាអ្នកការពារចំពោះរូបខ្ញុំ ដោយគាត់បានឆ្លើយទៅប្រាប់មេឈ្លបថា "កុំធ្វើបាបវា វានៅក្មេងទេ មិនទាន់ដឹងអីទាំងអស់"។ ប៉ុន្តែសព្វថ្ងៃ ខ្ញុំសូមជម្រាបអង្គសវនាការទាំងមូលថា ពូតឿ បានស្លាប់ហើយ។ ខ្ញុំបានទៅធ្វើបុណ្យគាត់នៅពោធិ៍សាត់ក្នុងឋានៈជាកូនចិញ្ចឹម។

[១៣:៤៨:០៥]

ក្រោយពីបានរស់នៅជាមួយនឹង ពូតឿ ខ្ញុំបានឃើញព្រឹត្តិការណ៍ជាច្រើននៅក្នុងរបបខ្មែរក្រហមនេះគឺ ការធ្វើទារុណកម្ម ការកាប់សម្លាប់ ជាពិសេសបងប្អូនខាងខេត្តស្វាយរៀងនៅក្នុងឆ្នាំ១៩៧៨ ក្នុងខ្ញុំមានវ័យខ្ទង់ជា១១ឆ្នាំហើយ ក្បែរនឹង១២ឆ្នាំហើយ។ ខ្ញុំឃើញគេពាក់ក្រមា ខ្ញុំដឹងថាមកពីស្វាយរៀង ពីព្រោះខ្ញុំឃើញក្រមាខៀវនិងលាយស ហើយគេដឹកជញ្ជូនមកឃុំមេទឹកហ្នឹងតែម្តង។ ពីព្រោះខ្ញុំនៅពេលនោះ ខ្ញុំនៅឃ្វាលក្របីឲ្យ ពូតឿ។

ក្រោយពីបានឃើញប្រជាជនខាងខេត្តស្វាយរៀងមក នៅទីនោះ មិនបានប៉ុន្មានយប់ផង ខ្ញុំឃើញប្រជាជននៅខេត្តស្វាយរៀងនេះ ត្រូវបានគេយកទៅសម្លាប់នៅហុងទឹក នៅក្នុងឃុំមេទឹកនេះតែម្តង។ តាមរយៈការមើលឃើញនៅពេលដែលខ្ញុំបានទៅឃ្វាលក្របីប៉ះ ហើយខ្ញុំមានភាពរន្ធត់ ហើយខ្ញុំបានទៅជម្រាប ពូតឿ ថា "គេសម្លាប់មនុស្សច្រើនម្លេះពូ?" ពូតឿ គាត់នៅតែឆ្លើយប្រាប់ថា នៅឲ្យស្ងៀមៗ ឯងកុំមាត់។ ខ្ញុំរង់ចាំនូវពាក្យពេចន៍របស់ពូ តឿ។ ខ្ញុំមិនហ៊ាន ខ្ញុំសុខចិត្តបរក្របីជៀសចេញពីកន្លែងដែលគេសម្លាប់។ ព្រឹត្តិការណ៍ហ្នឹងខ្ញុំក៏បន្តមកទៀត នៅក្នុងរស់នៅជាមួយ ពូតឿ។

[១៣:៤៩:៣០]

ក្រោយមកទៀត ក៏គេបញ្ជូន ពូតឿ ឲ្យទៅធ្វើការមួយនៅខាងទន្លេសាប គឺឡដុតធ្យូង។ នៅពេលដែលឡដុតធ្យូងនោះ ខ្ញុំបានទៅនៅជាមួយនឹង ពូតឿ នៅនឹងទន្លេសាបនោះ នៅនឹងចុងភូមិអូរព្រាលហ្នឹង នៅជាប់នឹងមាត់បឹងទន្លេសាបហ្នឹង។ ពេលនោះខ្ញុំក៏បានឃើញព្រឹត្តិការណ៍មួយទៀត គេបានយកគ្រួសារមួយទៅសម្លាប់ ប្រហែលជាប្រាំប្រាំមួយនាក់។ ពេលនោះខ្ញុំក៏នៅឃ្វាលគោឃ្វាលក្របី ពីព្រោះខ្ញុំជាកងដឹកជញ្ជូនជាមួយនឹង ពូតឿ នៅពេលដែលយើងដឹកធ្យូងមកជូនសហករណ៍។ នៅក្រោមដើមរាំងនៅព្រៃត្រែងនោះ ខ្ញុំបានឃើញក្រុមគ្រួសារដែលគេយកពីព្រឹករបស់មេភូមិនោះ ថាយកទៅចាំចម្ការនោះត្រូវបានកាប់សម្លាប់នៅពេលប៉ុន្មានថ្ងៃក្រោយមក។ ដោយសារការធុំក្លិនស្អុយខ្លាំងពេក ខ្ញុំពិបាកទ្រាំ ខ្ញុំក៏ទៅលួចមើលការកាប់សម្លាប់របស់ខ្មែរក្រហមនៅពេលនោះ។

ក្រោយពីបានឃើញចំណងចំតិតគូទឡើងលើ ទាំងក្មេងទាំងចាស់ ខ្ញុំក៏បានរត់មកប្រាប់ ពូតឿ ទៀតថា មានគេសម្លាប់មនុស្សនៅនឹងបឹង -- នៅនឹងដើមរាំជិតនឹងព្រៃត្រែង។ ពូតឿ ថា "នៅឲ្យស្ងៀម" ខ្ញុំក៏នៅស្ងៀមតាមគាត់។

[១៣:៥០:៥៦]

ព្រឹត្តិការណ៍ក្រោយមកទៀត មានករណីមួយដែលគួរឲ្យឈឺចាប់បំផុត។ ក្រុមគ្រួសារមួយត្រូវ

បានឈ្លបចាប់រំលោភស្ត្រីម្នាក់ ដែលជាកូនក្រុមគ្រួសារហ្នឹង។ ក្រោយពីចាប់រំលោភហើយត្រូវបានសម្លាប់តាមរយៈការដឹងរបស់ខ្ញុំ គឺសំឡេងស្រែក។ ក្រោយមកក៏ខ្ញុំដឹងថា អ្នកនោះត្រូវបានស្លាប់តាមរយៈការសម្លាប់របស់ខ្មែរក្រហម។ ព្រឹត្តិការណ៍ទាំងអស់នេះជាព្រឹត្តិការណ៍មួយដែលចុកចាប់បំផុតនៅក្នុងជីវិតរបស់ខ្ញុំ ក្នុងឋានៈជាកុមារក្នុងវ័យអាយុប្រហែលជា១២ឆ្នាំ។

[១៣:៥១:៣៦]

អង្គសវនាការទាំងមូលជាទីគោរព! អ្វីៗដែលខ្ញុំបានស្តែងឡើងនៅថ្ងៃនេះ ខ្ញុំសូមជម្រាបទៅអង្គសវនាការ និងជនរួមជាតិ និងប្រជាជននៅលើពិភពលោកឲ្យបានជ្រាបថា សោកនាដកម្មនៅក្នុងរបប ប៉ុល ពត គឺឃោរឃៅ ព្រៃផ្សៃជាងសត្វតិរិច្ឆានទៅទៀត។ ខ្ញុំចុកចាប់ណាស់ ខ្ញុំបាត់បង់ឪពុក បាត់បង់ម្តាយ បាត់បង់ឪពុកមាជាទីស្រឡាញ់របស់ខ្ញុំ។ ខ្ញុំចង់ឲ្យគាត់សងមកវិញនូវអ្វីដែលគាត់ជំពាក់ខ្ញុំ ក្នុងឋានៈជាមេដឹកនាំរដ្ឋមួយ។ គាត់ត្រូវតែប៉ិនទទួលខុសត្រូវចំពោះទង្វើដ៏លាមករបស់គាត់។ គាត់ត្រូវតែបើកកកាយនូវទំព័រប្រវត្តិសាស្ត្រសម្រាប់ប្រជាជាតិកម្ពុជា និងប្រជាជនពិភពលោកឲ្យគេដឹងថាអំពើអាក្រក់របស់គាត់ដែលបង្កើតឡើងដោយរបបខ្មែរក្រហមនេះវាឃោរឃៅប៉ុនណា ក្នុងឋានៈជាមេដឹកនាំរដ្ឋមួយ។

អ្វីៗទាំងអស់មកទាល់ថ្ងៃនេះ ខ្ញុំរង់ចាំ៣៤ឆ្នាំហើយ ពីកុមារភាព ខ្ញុំបាន*សេរ* ទុកក្នុងខួរក្បាលខ្ញុំថាខ្ញុំនឹងបើកកកាយនូវអំពើអាក្រក់របស់គាត់ បើសិនជាខ្ញុំមានឱកាស។ បើសិនជាខ្ញុំមានឱកាស ខ្ញុំនឹងបើកកកាយនូវទង្វើដ៏លាមក និងអាក្រក់របស់គាត់។ ឲ្យប្រជាជាតិនៅលើពិភព និងប្រជាជនខ្មែរដែលរងគ្រោះដោយការកាប់សម្លាប់របស់គាត់។ ឲ្យគាត់បានជ្រាប បានដឹងនូវអ្វីដែលគាត់បានបង្កឡើង។

[១៣:៥៣:៣២]

ការសោកនាដកម្មដ៏ចុកចាប់នេះ គាត់មកធ្វើចំពោះខ្ញុំជាកូនក្មេង បំបែកបំពាក់ខ្ញុំពីឪពុកម្តាយខ្ញុំ មិនឲ្យខ្ញុំរៀនសូត្រ មិនឲ្យខ្ញុំសិក្សា តើសីលធម៌ជាមេដឹកនាំនៅត្រង់ណា? លោក ខៀវ សំផន ពិចារណាទៅ! លោក នួន ជា ពិចារណាទៅ! ក្នុងឋានៈជាបញ្ញាជនជាន់ខ្ពស់ម្នាក់ លោកពិចារណាទៅ! លោកត្រូវតែប៉ិនបកស្រាយការពារពិតចំពោះមុខជាតិ និងប្រជាជាតិទាំងមូល លោកមិនត្រូវសោកស្តាយ ឬមានវិប្បដិសារីក្នុងការបកស្រាយទេ។ ខ្ញុំចុកចាប់ណាស់។ ថ្ងៃនេះខ្ញុំសូមទោសអង្គសវនការទាំងមូល។

ខ្ញុំសូមបញ្ចេញនូវទស្សនៈ នូវភាពចុកចាប់របស់ខ្ញុំ ចិញ្ចើមរបស់ខ្ញុំស្នាមរហូតដល់កូនរបស់ខ្ញុំ និងចៅរបស់ខ្ញុំតាមរយៈការរើនឹងដំបងរបស់លោក ក្រុមរបស់លោក បក្ខពួករបស់លោក ក្នុងឋានៈលោកជាមេដឹកនាំ។ លោកអត់បានស្រឡាញ់ជាតិរបស់ខ្លួនទេ លោកបំផ្លាញជាតិរបស់ខ្លួន លោកធ្វើឲ្យជាតិរបស់

ខ្លួនរងគ្រោះវេទនាអាប់ឱនកិត្តិយសនៅក្នុងពិភពលោកនេះ។ គេគ្រាន់តែនិយាយថា ខ្មែរ គេខ្លាច តាមរយៈបញ្ញាជនដ៏គួរឲ្យមិនគួរកោតសសើរនេះ។ លោកពិចារណាចុះ!

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ហើយពេលវេលានៅបន្តិចទៀតទេ គឺពេលវេលានៅតែ១២មីនុតទៀតទេ។ ហើយលោកស្រីមេធាវី តើមានសំណួរអីត្រូវសួរទេ? ហើយប្រយ័ត្នអស់ពេល ព្រោះទំនងជាលោក យិន វំដួល មានសំណួរមួយចំនួនសួរដល់ជនជាប់ចោទផង។

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ និងសូមគោរពអង្គសវនាការទាំងមូល។

[១៣:៥៥:៤០]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ខ្ញុំ ជេត វណ្ណលី ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរបន្តិចបន្តួចបន្ថែមលើអ្វីដែលលោក វំដួល បានបញ្ជាក់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើឪពុកលោក -- ខ្ញុំចង់ឲ្យលោកបញ្ជាក់ម្ដងទៀតថា តើឪពុកលោកធ្វើអី? ហើយហេតុអ្វីក៏លោកអត់មានបាននិយាយពីឪពុកលោក?

**លោក យិន វំដួល៖**

**ឆ៖** សូមអរគុណ លោកប្រធានក្រុមប្រឹក្សាអង្គជំនុំជម្រះ។ ខ្ញុំសូមអរគុណលោកមេធាវីការពារជនរងគ្រោះ។ ឪពុកខ្ញុំឈ្មោះ យិន ស៊ីដារ៉េត ជាសាស្ត្រាចារ្យ និងជានាយទាហានជាន់ខ្ពស់នៅក្នុងរបបខ្មែរក្រហម។ នៅថ្ងៃទី១៦ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់គាត់បាត់ទៅហើយ គឺគាត់នៅក្នុងជាមេបញ្ជាការនៅក្នុងកងពលលេខ២៤ (វាំងកាត់បេអ៊ី) នៅបន្ទាយដែក១។ ប៉ុន្តែឪពុកខ្ញុំត្រូវបានចាប់នៅថ្ងៃទី១៦ មេសា ការចាប់របស់គាត់បាត់ដល់សព្វថ្ងៃ។ បាទ សូមអរគុណ។

[១៣:៥៦:៤១]

**ស៖** សូមអរគុណលោក។ ឥឡូវចំពោះមុខនេះ តើលោកមានសំណូមពរអ្វីចំពោះតុលាការទេ?

**ឆ៖** បាទ ខ្ញុំមានសំណូមពរ។ ចំពោះលោកប្រធាន និងអង្គសវនាការទាំងមូល! ខ្ញុំចង់ឲ្យលោក ខៀវ សំផន និងលោក នួន ជា បង្ហាញនូវអ្វីដែលជាការពិត សម្រាប់--

**ស៖** សូមទោសៗលោក គឺថាលោកមានសំណូមពរអ្វីចំពោះតុលាការ អត់ទាន់ដល់សំណួរ។ លោកមានសំណូមពរដូចម្ដេចចំពោះតុលាការ លោកមានទាមទារសំណង ឬបញ្ហាអីទេ?

**ឆ៖** អរគុណលោកប្រធាន។ ក្រុមប្រឹក្សាជំនុំជម្រះ និងលោកស្រីមេធាវី។ ខ្ញុំសូមឲ្យតុលាការស្វែងរកយុត្តិធម៌ឲ្យខ្ញុំបាទ និងប្រជាជាតិទាំងមូលដើម្បី ព្រមទាំងដាក់ទណ្ឌកម្មទៅលើជនឧក្រិដ្ឋជននេះឲ្យសក្តិសមទៅនឹងទម្ងន់ទោសរបស់គាត់។ ពីព្រោះគាត់ជាអ្នកទទួលខុសត្រូវ ជៀសវាងកុំឲ្យមេដឹកនាំខ្មែរជំនាន់ក្រោយ និងមេដឹកនាំដទៃទៀត នៅលើពិភពលោកនេះ យកគំរូអាក្រក់តាមជនរូបនេះ។

[១៣:៥៨:០៤]

**ស៖** លោកមានទាមទារសំណងអីទេ ចាស?

**ឆ៖** ខ្ញុំមិនទាមទារសំណងអ្វីទេ។ ប៉ុន្តែខ្ញុំសូមឲ្យអង្គសវនាការទាំងមូល គ្រាន់តែធ្វើស្តូបជូនលោកពុកអ្នកម្ដាយជាទីគោរពរបស់ខ្ញុំ នៅក្នុងឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលតែប៉ុណ្ណឹងបានហើយ។

**ស៖** សូមអរគុណលោក។ តើលោកមានសំណួរអ្វីសួរដល់ជនជាប់ចោទទេ?

**ឆ៖** បាទ សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ សូមគោរពលោកមេធាវីការពារក្តីជនរងគ្រោះ។ ខ្ញុំមានសំណួរប្រាំ ដែលត្រូវចោទសួរទៅមេដឹកនាំខ្មែរក្រហមទាំងពីររូបនេះ។

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកៗ។ លោកប្រធាន សូមលោកប្រធានអនុញ្ញាតឲ្យកូនក្តីរបស់យើងខ្ញុំសួរសំណួរទៅជនជាប់ចោទ។ សូមអនុញ្ញាតលោកប្រធាន។

[១៣:៥៩:០៨]

**ប្រធានអង្គជំនុំ៖**

បាទ លោក វំដួល លោកមានសិទ្ធិក្នុងការតាំងសំណួរចំពោះជនជាប់ចោទ ប៉ុន្តែសំណួរលោកមិនអាចធ្វើផ្ទាល់ជាមួយនឹងជនជាប់ចោទបានទេ។ សំណួរលោកត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះ ធ្វើតាមរយៈរូបយើង។ ដូច្នេះគឺសួរមកយើង ដើម្បីយើងបញ្ជូនសំណួរនោះទៅជនជាប់ចោទដើម្បីឲ្យគាត់ឆ្លើយតបនឹងលោក។ ក្នុងករណីគាត់ប្រើសិទ្ធិក្នុងការឆ្លើយតប។ សូមអញ្ជើញ!

**លោក យិន វំដួល៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។

ខ្ញុំបាទមានសំណួរប្រាំដែលត្រូវចោទសួរលោក ខៀវ សំផន និងលោក នួន ជា។

សំណួរទី១ តើលោកបានដឹងអំពីការចាប់ខ្លួននិងបាត់ខ្លួនរបស់ឪពុករបស់ខ្ញុំបាទ ឈ្មោះ យិន ស៊ីដារ៉េត ជាសាស្ត្រាចារ្យ និងជាវរសេនីយ៍ឯក មេបញ្ជាការកងទ័ពលេខ២៤ បេ.អ៊ី មានទីតាំងនៅបន្ទាយដែកមុនអ្នកលឿងឬទេ?

សំណួរទី២ តើលោកមានដែលគិតដល់ពីផលវិបាកនៃការកាប់សម្លាប់ ការព្រាត់ប្រាសគ្រួសារដែលខ្មែរក្រហមបានបង្កឡើងដល់រូបលោកផ្ទាល់ដែរឬទេ? តើលោកមានការភ្ញាក់រឮក និងមានវិប្បដិសារីចំពោះការចូលរួមរបស់លោកក្នុងរបបនេះដែលបានបង្កការឈឺចាប់ដល់ប្រជាជនខ្មែរទាំងមូលដែរឬទេ?

សំណួរទី៣ ក្នុងឋានៈលោកជាបញ្ញាជនជាន់ខ្ពស់ម្នាក់ តើលោកហ៊ានធ្វើការបកស្រាយនូវការពិតនូវហេតុការណ៍ដែលកើតឡើងក្នុងរបបខ្មែរក្រហមឲ្យប្រជាជាតិ និងប្រជាជនពិភពលោកទាំងមូលបានដឹងដែរឬទេ ក្នុងឋានៈលោកជាមេដឹកនាំកំពូល ហើយក្នុងឋានៈលោកជាបញ្ញាជនជាន់ខ្ពស់ដែលលោកបានប្រើប្រាស់កន្លងមក ហើយបានទទួលនូវភាពល្បីល្បាញពីសម័យសង្គមរាស្ត្រនិយម និងសាធារណរដ្ឋខ្មែរ តាមរយៈការដឹង និងការស្រាវជ្រាវរបស់ខ្ញុំ។

[១៤:០១:៣០]

សំណួរទី៤ តើលោកមានគំនិតក្នុងការសុំទោសដល់ប្រជាជនកម្ពុជាទេ ជាពិសេសក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីនេះ ក្នុងនាមខ្លួនខ្ញុំផ្ទាល់?

សំណួរទី៥ ក្នុងនាមប្រធានគណៈរដ្ឋនៃរបបកម្ពុជាប្រជាប្រជាធិបតេយ្យ តើលោកបានដឹងអ្វីខ្លះអំពីកម្រិតជីវភាពនៃការរស់នៅរបស់ប្រជាជនដែលរងគ្រោះដោយការអត់ឃ្លាន និងការកាប់សម្លាប់ ការឃុំឃាំង ការចាប់ខ្លួន ការធ្វើទារុណកម្មដ៏ឃោរឃៅក្នុងរបបរបស់លោកដែរឬទេ?

សូមអរគុណលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងអង្គសវនាការទាំងមូល។ សំណួរទាំងប្រាំរបស់ខ្ញុំបាទមានត្រឹមតែប៉ុណ្ណោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះអង្គជំនុំជម្រះសូមបញ្ជូននូវសំណួរទាំងប្រាំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះជូនទៅជនជាប់ចោទ ខៀវ សំផន ដើម្បីឆ្លើយតបនឹងសំណួរនេះមុនលោក នួន ជា។ លោក ខៀវ សំផន!

[១៤:០២:៥៦]

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន។ សូមគោរពអស់លោក លោកស្រីចៅក្រមទាំងអស់។ សូមគោរពអង្គសវនាការទាំងមូល។ សូមជម្រាបសួរលោក យិន រំដួល។ ខ្ញុំសូមជម្រាបលោកថា បើខ្ញុំជាលោកវិញ ខ្ញុំក៏មានការឈឺចាប់ ហើយសោកសង្រេងដូចលោកដែរ។

ចំពោះសំណួរទី១ របស់លោក ខ្ញុំសូមជម្រាបលោកថា ខ្ញុំមិនដែលបានស្គាល់ឪពុកលោកនោះទេ។ ខ្ញុំមិនដែលបានស្គាល់លោក ស៊ឹម ស៊ីដារ៉េត នោះទេ។ ហើយខ្ញុំសោកស្ដាយណាស់ដោយឪពុកលោកត្រូវបានគេសម្លាប់ដោយឃោរឃៅ។ ខ្ញុំសូមជម្រាបលោកថា ចាប់ពីខ្ញុំ ពេលដែលខ្ញុំរត់ចេញ-- ត្រូវគេចរត់គៀសខ្លួនចេញពីភ្នំពេញ ពេលណាមកខ្ញុំបានត្រូវការពារដោយមេខ្មែរក្រហមរហូតដល់ឆ្នាំ៧៩។ ដូច្នេះខ្ញុំត្រូវរស់នៅ ហៅថាដោយដាច់ពីជីវភាព ជាក់ស្ដែងរបស់ប្រជាជនរហូតមកដែរ។ រាប់សិបឆ្នាំកាលពីឆ្នាំ៧០ ដល់ឆ្នាំ៧៩ ដោយខ្ញុំត្រូវរស់នៅជាប់ ជាមួយអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងដោយតួនាទីខ្ញុំនៅក្នុងកម្ពុជាប្រជាធិបតេយ្យខ្ញុំបានរួចខ្លួន មិនបានជួបប្រទះនឹងអំពើឃោរឃៅដ៏អ្កួតលីលារបស់ស្ដេចត្រាញ់ផ្សេងៗ ដែលបានបង្កជាសោកនាដកម្មដល់ជាតិនិងប្រជាជនយើងយ៉ាងនេះទេ។ តែមុខមួយទៀតក៏នាំឲ្យខ្ញុំមិនបានដឹងឮអំពីអំពើឃោរឃៅ អ្កួតលីលាដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីជាបន្តបន្ទាប់ ហើយក្រោយនេះលោកបានអញ្ជើញមករៀបរាប់នៅតុលាការនេះដែល។

ពិតមែនហើយខ្ញុំមិនមែនជាអ្នកមនោគមន៍វិជ្ជាទេ ក៏ប៉ុន្តែខ្ញុំជាអ្នកដែលមានឧត្តមគតិមួយគឺឧត្តមគតិរួមចំណែកធ្វើម៉េចកសាងប្រទេសយើងឲ្យបានរីកចម្រើនជឿនលឿន និងការពារប្រទេសយើងឲ្យបានរស់គង់វង្ស។

[១៤:០៨:០២]

ដូច្នេះចំពោះសំណួរទី២របស់លោក ក៏ខ្ញុំមានការសោកស្ដាយ ហើយខ្ញុំយល់ឃើញថា ត្រូវតែចាប់ស្ដេចត្រាញ់ដែលបានប្រព្រឹត្តអំពើឃោរឃៅដ៏អ្កួតលីលាទាំងនោះយកមកកាត់ទោសឲ្យស័ក្តិសមទៅតាមធាតុឃោរឃៅអ្កួតលីលារបស់វា។ ដែលខ្ញុំបានមករួមជាមួយកម្ពុជាប្រជាធិបតេយ្យ មិនមែនដើម្បីសម្លាប់រង្គាលខ្មែរគ្នាឯងទេ គឺដើម្បីរួមចំណែកការពារជាតិឲ្យរស់គង់វង្ស ហើយក្រោយតទៅទៀតកសាងជាតិឲ្យបានរីកចម្រើន។ ប៉ុន្តែខ្ញុំស្ដាយណាស់វាបែរទៅជាអ៊ីចឹងវិញ។

ឥឡូវចំពោះសំណួរទី៣របស់លោក ខ្ញុំបានជម្រាបតុលាការរួចហើយថាខ្ញុំនឹងរួមជាមួយតុលាការឲ្យអស់លទ្ធភាពរបស់ខ្ញុំដើម្បីស្វែងរកការពិត។ ដូច្នេះហើយបានជាខ្ញុំសម្រេចចិត្តឆ្លើយនឹងសំណួររបស់

លោក។ ហើយត្រៀមខ្លួនដើម្បីឆ្លើយនឹងសំណួររបស់ភាគីទាំងអស់នៅក្នុងអង្គសវនាការនេះ។

ចំពោះសំណួរទី៤របស់លោក ខ្ញុំសូមជម្រាបលោកថា ពីម្សិលមិញខ្ញុំបានលើកដៃសំពះសូមទោស លោកស្រី ហូ ចន្ថា ហើយតាមរយៈលោកស្រី ហូ ចន្ថា ក៏ខ្ញុំសូមទោសប្រជាជនខ្មែរយើងទាំងមូល ទាំងអស់ដែលបានរងគ្រោះរួចមកហើយនេះ។ ថ្ងៃខ្ញុំក៏សូមទោសលោកទៀត ខ្ញុំសូមលំឱនកាយគោរព ដល់វិញ្ញាណក្ខន្ធឪពុករបស់លោក ម្ដាយរបស់លោក និងសាច់សាលោកហិតរបស់លោកដែលបានចាក ឋានទៅក្នុងក្ដីឈឺចាប់ខ្លោចផ្សា រកនិយាយមិនបាន។

[១៤:១១:២០]

សំណួរទី៥ មើលពីក្រោមកគេអាចសន្និដ្ឋានថា ខ្ញុំជាមេដឹកនាំធំ។ ពិតមែនហើយខ្ញុំមានស្លាក ធំណាស់ តែខ្ញុំគ្មានអំណាចជាក់ស្ដែងដើម្បីចាប់អ្នកនេះ ចាប់អ្នកនោះទេ ហើយដូចបានខ្ញុំជម្រាបខាងលើ ខ្ញុំមិនបានដឹងនូវសភាពការណ៍ប្រជាជនយើងត្រូវរស់នៅជាក់ស្ដែងយ៉ាងណាៗនោះទេ។ ត្រូវគេធ្វើទុក្ខធ្វើ បាបយ៉ាងណាៗនោះទេ។ ឬមួយក៏ត្រូវគេចាប់ចងដាក់គុកច្រវាក់យ៉ាងណាៗនោះទេ។ ខ្ញុំសូមជម្រាប លោកប៉ុណ្ណឹង។

សូមម្ដងទៀត ខ្ញុំសូមទោសលោក ខ្ញុំសូមទោសពិតមែនតែខ្ញុំមិនបានចូលសម្រេចនៅនយោបាយ អ្វីរបស់កម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ខ្ញុំសូមទោស ពីព្រោះដូចពីព្រឹកមិញអ៊ីចឹង គេហៅថាត្រីមួយ កន្ត្ររកស្អុយមួយវាស្អុយទាំងអស់។ ការពិតទៅខ្ញុំមិនស្អុយទេ ក្នុងន័យថាខ្ញុំមិនបានប្រព្រឹត្តអំពើឃោរឃៅ ដ៏ល្វង់ខ្លៅដូចដែលលោក ហើយនិងភាគីដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតបានរៀបរាប់ជាបន្តបន្ទាប់ មកនោះទេ។ ខ្ញុំសូមអស់ហើយ។ អរគុណលោក។

[១៤:១៣:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះអង្គជំនុំជម្រះសូមបញ្ជូនសំណួរទាំងប្រាំនេះ ទៅលោក នួន ជា!

**លោក នួន ជា៖**

នួន ជា ខ្ញុំសូមគោរពអង្គសវនាការ អង្គជំនុំជម្រះ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ច្បាស់លាស់ហើយថា ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

លោក នួន ជា បង្អង់ -- ផ្អាកសិនលោក នួន ជា ដូចជាមានបញ្ហាបច្ចេកទេសខាងសំឡេងនិងរូបភាពមិនឃើញ ហើយនិងស្តាប់សំឡេងមិនបានទេ។

*(មានបញ្ហាបច្ចេកទេស)*

[១៤:១៥:១៦]

**លោក នួន ជា៖**

ខ្ញុំបានមានមតិជាហូរហែមកហើយ គឺថាខ្ញុំសូមទទួលខុសត្រូវទាំងអស់នូវអ្វីដែលកើត មានកន្លងមកក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ដូច្នោះ ខ្ញុំមិនគេចវេះទៅណាទេ។ ខាងផ្លូវចិត្ត ខ្ញុំសូមទទួលការខុសត្រូវទាំងអស់ ដោយស្មោះអស់ពីចិត្ត។ នេះសូមជម្រាបដោយត្រង់ ពីព្រោះក្នុងឋានៈជាសមាជិកម្នាក់របស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំហ៊ានទទួលខុសត្រូវ ទោះបីជាខ្លួនខ្ញុំបានប្រព្រឹត្តិដោយផ្ទាល់ ឬមិនដោយផ្ទាល់ក៏ដោយ តែខ្ញុំសោកស្តាយណាស់ចំពោះព្រឹត្តិការណ៍ទាំងឡាយដែលកើតឡើងដោយចេតនា ឬអចេតនា។ ហើយទោះបីជាខ្ញុំដឹង ឬមិនដឹងក៏ដោយ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ថាខ្ញុំទទួលខុសត្រូវទាំងអស់។ សូម -- ខាងផ្លូវចិត្ត ខ្ញុំសូមជម្រាបបញ្ជាក់អ៊ីចឹង។

[១៤:១៦:៣៨]

ក្នុងឱកាសនេះ ខ្ញុំសូមចូលរួមមរណទុក្ខ ការសោកស្តាយចំពោះការបាត់បង់គ្រួសាររបស់លោក វំដួល។ តាមខ្ញុំចាំឈ្មោះលោក វំដួល។ ដូច្នោះ នេះ ហើយតទៅនេះ ខ្ញុំសូមបញ្ជាក់ម្តងទៀត នូវតួនាទីនិងភារកិច្ចរបស់ខ្ញុំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ខទី១ ខ្ញុំជាសមាជិកអចិន្ត្រៃយ៍ -- អនុលេខាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាទទួលខាងការអប់រំរៀនសូត្រផ្ទៃក្នុងបក្ស។ ខទី២ ខ្ញុំទទួលភារកិច្ចជាប្រធានគណៈកម្មាធិការសភាតំណាងប្រជាជនកម្ពុជា។ ភារកិច្ចរបស់ខ្ញុំមានពីរប៉ុណ្ណឹងទេ។ ឯខាងនីតិបញ្ញត្តិ នីតិប្រតិបត្តិ ខ្ញុំមិនមានតួនាទីអ្វីទេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។ ហេតុដូច្នោះ សូមឲ្យតុលាការវិនិច្ឆ័យទៅចុះ ខ្ញុំមិនមានអ្វីក្រៅពីការស្មោះត្រង់ ចូលរួមការតស៊ូដើម្បីជាតិ ប្រជាជនរបស់ខ្ញុំប៉ុណ្ណោះទេ។ សូមបញ្ជាក់ សូមគោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល ប្រសិនបើដើម -- ខាងតំណាងសហព្រះរាជអាជ្ញាមានសំណួរ។ សូមអញ្ជើញបាទ!

[១៤:១៨:៣៨]

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ សូមសួស្តីលោក យិន រំដួល ផងដែរបាទ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក យិន រំដួល ខ្ញុំជាមួយសហការីអន្តរជាតិរបស់ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា ហើយខ្ញុំមានសំណួរមួយចំនួនតូចចង់ឲ្យលោកជួយបញ្ជាក់នូវអ្វីដែលលោកបានឆ្លើយមុននេះ។ មុននេះលោកបានជម្រាបជូនអង្គសវនាការថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានការបាញ់ចូលទៅផ្ទះដែលថាផ្ទះទល់មុខអ្នកជិតខាងលោកហ្នឹង គឺទល់មុខផ្ទះលោកហ្នឹង។ តើលោកដឹងទេ តើហេតុអីបានជាមានការបាញ់ទៅក្នុងនុ៎ង?

[១៤:១៩:៣៧]

**លោក យិន រំដួល៖**

**ឆ៖** បាទសូមអរគុណលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ។ សូមអរគុណលោកសហប្រធាន -- ព្រះរាជអាជ្ញា។ ព្រឹត្តិការណ៍ដែលការបាញ់នេះ ខ្ញុំបានដឹងឃើញនឹងភ្នែក គឺមុនដំបូងខ្មែរក្រហមបាញ់ឡើងលើ ឬក៏បាញ់ផ្ទុចដីដើម្បីឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញនេះ។ ប៉ុន្តែផ្ទះនៅខាងមុខខ្ញុំបាទនេះ គឺជាផ្ទះនាយទាហានម្នាក់ ដែលខ្ញុំធ្លាប់ស្គាល់។ ពេលនោះ គាត់ក៏បាញ់តចេញពីក្នុងផ្ទះនោះវិញ ប្រហែលជាបីបួនគ្រាប់។ ពេលដែលបាញ់តនោះ ប៉ុន្មាននាទីក្រោយមក បានឃើញកម្លាំងខ្មែរក្រហមបានបាញ់បុកចូលផ្ទះនោះតែម្តង។ ពេលនោះហើយសភាពការណ៍ត្រូវបានស្ងាត់ៗទាំងអស់ ទាំងផ្ទះខ្ញុំទាំងផ្ទះខាងនោះ គឺលែងបានទាក់ទងគ្នាហើយ ព្រោះព្រឹត្តិការណ៍នោះ គឺយើងរកប្រាសអាយុរៀងខ្លួន។ សូមអរគុណ។

**សៈ** បាទ អរគុណ។ តើលោកអាចបញ្ជាក់ឲ្យបន្តិចទៀតបានទេ ថាផ្ទះនាយទាហាននុ៎ង ជានាយទាហានខាងណាដែរ?

**ផៈ** បាទ លោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ លោកសហព្រះរាជអាជ្ញា! ផ្ទះដែលខ្ញុំបាទឃើញដែលគេមានការបាញ់តនោះ តាមខ្ញុំដឹង ពីព្រោះផ្ទះនោះខ្ញុំធ្លាប់ទៅលេង ធ្លាប់ទៅបះផ្លែត្របែក។ គឺជាផ្ទះនាយទាហាន បើខ្ញុំនៅចាំ ប្រហែលជាខ្ពង់ឋានៈអនុសេនីយ៍ឯករបបសាធារណរដ្ឋខ្មែរ។

[១៤:២១:១៤]

**សៈ** បាទអរគុណ។ ចុះក្នុងអំឡុងពេលនោះដែរ លោកមានដឹងអ្វីខ្លះទៀតដែរទេ ទាក់ទងទៅនឹងដូចជាទាហាននៃរបបសាធារណរដ្ឋខ្មែរ ឬក៏ជាមន្ត្រីរដ្ឋការ។ តើនៅពេលនោះ លោកបានដឹងព័ត៌មានអីឬក៏បានឃើញផ្ទាល់ភ្នែកអ្វីខ្លះ ទាក់ទងនឹងមន្ត្រីទាំងនោះ នៅអំឡុងពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនោះ?

**ផៈ** បាទ សូមអរគុណលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ លោកសហព្រះរាជអាជ្ញា។ ពាក់ព័ន្ធទៅនឹងកងទ័ពដែល -- ពាក់ព័ន្ធទៅនឹងការងារនៅចំពោះមុខផ្ទះខ្ញុំ ខ្ញុំមិនបានដឹងអ្វីទាំងអស់ ក្នុងជួររដ្ឋការរបស់សាធារណរដ្ឋខ្មែរ និងកងទ័ពសាធារណរដ្ឋខ្មែរ។ ប៉ុន្តែគ្រាន់តែខ្ញុំដឹងថា នៅថ្ងៃទី១៧ មេសា ពិតជាមានការជម្លៀស និងបាញ់ភ្លង់ប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញ តែប៉ុណ្ណឹង។ សូមអរគុណ។

**សៈ** បាទ អរគុណ។ ទាក់ទងនឹងការជម្លៀស តើនៅពេលដែលក្រុមគ្រួសាររបស់លោកកំពុងតែធ្វើដំណើរចេញពីទីក្រុងភ្នំពេញនោះ តើនៅពេលនោះ លោកឃើញស្ថានភាពអ្នកដំណើរទាំងអស់ហ្នឹងយ៉ាងម៉េចដែរ? ហើយលោកបានឃើញមានមនុស្សឈឺ មនុស្សស្លាប់អីដែរទេនៅពេលនុ៎ង?

[១៤:២២:៥៦]

**ផៈ** បាទ សូមគោរពលោកប្រធាន សូមគោរពសហព្រះរាជអាជ្ញា! ខ្ញុំបាទឃើញយ៉ាងច្បាស់ពេលនោះវ័យ១០ឆ្នាំហើយ។ ខ្ញុំឃើញសោកនាដកម្មនៃការរុញរទេះ កាលរថយន្ត ជាពិសេសបងប្រុសខ្ញុំមិនមានរថយន្ត -- មិនមានសាំងចាក់រថយន្តផង។ ខ្ញុំត្រូវបានរកស៊ីក្លូបងខ្ញុំ ឪពុកមាខ្ញុំរកស៊ីក្លូ ហើយមនុស្សនៅតាមដងផ្លូវ យើងឃើញថាមានសោកនាដកម្មខ្លាំងណាស់ ទាំងអ្នកត្រូវរបួស អ្នកសែង អ្នកខ្លះសែង អ្នកខ្លះព្យួរសេរ៉ូម ក្មេង ហើយសាកសពនៅតាមដងផ្លូវ ខ្ញុំបានឃើញ។ នៅពេលដែលគេប៉ិះនឹងចាប់បងប្រុសរបស់ខ្ញុំនៅក្បាលថ្នល់ ខ្ញុំឃើញសាកសពប្រហែលជាបួនប្រាំនាក់នៅនឹងអែបក្បាលថ្នល់ហ្នឹង។ ខ្ញុំបានឃើញទិដ្ឋភាពនេះ ហើយទិដ្ឋភាពនៃស្រែកឃ្លាន នៃការអត់ឃ្លាននៅពេលនោះ ខ្ញុំជាកុមារ

ក៏ខ្ញុំត្រូវបានឪពុក -- អ៎! ម្ដាយរបស់ខ្ញុំ (សូមទោស) ម្ដាយរបស់ខ្ញុំដាក់លើរទេះរុញដែរ នៅពេលនោះ ខ្ញុំបានឃើញ។ ប៉ុន្តែអ្វីៗទាំងអស់នៅពេលនោះ ខ្ញុំគ្រាន់បានតែឃើញ មិនដឹងជាខ្ញុំមានលទ្ធភាពនឹងជួយគាត់យ៉ាងម៉េច ខ្ញុំពុំមានទេ គ្រាន់បានត្រឹមតែឃើញ ពីព្រោះគ្រួសារខ្ញុំ ក៏ជាគ្រួសាររងគ្រោះដែរ។

**ស៖** ចុះទាក់ទងទៅនឹងការធ្វើដំណើរនេះដែរ តើលោកមានបានឃើញ ឬក៏លោកបានជួបដោយផ្ទាល់ខ្លួនលោកទេ ថាមានក្រុមខាងណាមួយដែលគេផ្ដល់ជាចំណីអាហារ ឬក៏ជាផ្ដល់ការការពារ -- ព្យាបាលសុខភាព។ តើមានទេ?

[១៤:២៤:៣៣]

**ឆ៖** សូមគោរពអង្គសវនាការ សូមគោរពលោកព្រះរាជអាជ្ញា! គ្មានទាំង -- សឹងតែទឹកញ៉ាំមិនបានផង។ គ្មានអ្វីៗទាំងអស់។ ខ្ញុំស្រែកយំ សួររកម្ដាយខ្ញុំដើម្បីរកចំណីអាហារ គ្មានទេ។ មានតែលុយម្ដាយខ្ញុំមានប៉ុន្មានការ៉ុងត្រូវចាក់ចោលនៅល្វាឯម -- នៅព្រែកឯងទាំងអស់។ អត់មានអ្វីទាំងអស់។ ថ្នាំសង្កូវក៏គ្មាន គ្មានទាំងអស់។ សូមជម្រាបលោកសហព្រះរាជអាជ្ញា។

**ស៖** បាទអរគុណ។ ចំណុចមួយទៀតនៅពេលដែលលោកទៅដល់ទីដៅដែលលោកត្រូវទៅនោះ តើនៅពេលដែលលោកទៅដល់ហ្នឹង មាននរណា ឬក៏អង្គការណាគេមកឲ្យលោកហៅលោកឲ្យចូលកងចល័ត ឬក៏ចូលក្នុងក្រុមអីដែរទេ? ឬក៏លោកស្នាក់នៅក្នុងផ្ទះ?

**ឆ៖** បាទសូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល! នៅពេលដែលខ្ញុំបាទទៅខេត្តពោធិ៍សាត់នៅក្នុងភូមិអូរព្រាល ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់ ត្រូវមេកងកុមារ មេភូមិបានជម្លៀសខ្ញុំបាទចេញពីម្ដាយខ្ញុំ ក្រុមគ្រួសារខ្ញុំ បងប្រុស បងស្រីខ្ញុំបែកគ្នាទាំងអស់ គឺខ្ញុំមិនអាចនៅជាមួយម្ដាយ និងបងប្រុស ជីដូននិងជីតារបស់ខ្ញុំទេ គឺបែកចេញតែម្ដង គឺត្រូវចាប់បង្ខំនិងការធ្វើទារុណកម្មដែលមានស្លាកស្នាមដល់សព្វថ្ងៃនៅលើចុងចិញ្ចើមខាងឆ្វេង។

**ស៖** បាទ ខ្ញុំសូមកាត់លោកប៉ុណ្ណឹង។ ហើយតាមការបញ្ជាក់របស់លោក គឺលោកត្រូវបានគេបញ្ជូនទៅពោធិ៍សាត់តាមរយៈជិះរថភ្លើង។ នេះជាអ្វីដែលលោកបានជម្រាបជូនអង្គសវនាការតាមរថយន្តបាទតាមរថយន្ត។ តើលោកអាចជម្រាបបានទេថានៅពេលណា លោកនៅចាំទេថានៅពេលណា ខែណា ឆ្នាំណា លោកត្រូវទៅពោធិ៍សាត់ហ្នឹង?

[១៤:២៥:៥២]

**ឆ៖** បាទសូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ ខ្ញុំអាចចាំបានថានៅក្នុងចុងឆ្នាំ

៧៥ ដើមឆ្នាំ៧៦ ខ្ញុំចាំតែប៉ុណ្ណឹងទេ។ ថ្ងៃខែខ្ញុំមិនចាំទេ។

**ស៖** បាទប៉ុណ្ណឹងគ្រប់គ្រាន់។ ចំណុចមួយទៀត តើការដែលគេបញ្ជូនលោកក៏ដូចជាក្រុមគ្រួសាររបស់លោកទៅកាន់ខេត្តពោធិ៍សាត់នោះ តើគេមានបានប្រាប់លោកថាទៅធ្វើអីទេ?

**ឆ៖** សូមអរគុណ។ ចំពោះបញ្ហានេះខ្ញុំមិនបានដឹងអ្វីទាំងអស់ ពីព្រោះខ្ញុំក្មេង ហើយណាមួយខ្ញុំគិតថាម្ដាយខ្ញុំក៏មិនបានប្រាប់ គេគ្រាន់តែដឹងថាអង្គការជាអ្នកបញ្ជូនឲ្យទៅ។ ខ្ញុំក្នុងនាមជាកូន ខ្ញុំត្រូវតាមម្ដាយ។ ខ្ញុំទៅជាមួយម្ដាយ។ រឿងបញ្ហាបញ្ជូនឲ្យទៅធ្វើអ្វី ធ្វើអ្វីនៅទីនោះខ្ញុំអត់ដឹង។ គ្រាន់តែខ្ញុំដឹងថានៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំនឹងទទួលនូវទណ្ឌកម្មនៃការធ្វើចម្ការ ទណ្ឌកម្មនៃការស្ទូងដកកាប់ប្រឡាយរហូតដល់យប់។ ពីម៉ោងប្រាំពីរព្រឹកទៅដល់ម៉ោងដប់ពីរ, ម៉ោងមួយទៅដល់ម៉ោងប្រាំ, ម៉ោងប្រាំពីរដល់ម៉ោងដប់មួយយប់ក៏មានដែរ។ ទារុណកម្មនៃការធ្វើការយ៉ាងធ្ងន់ធ្ងរចំពោះកុមារ។

[១៤:២៨:១៧]

**ស៖** បាទអរគុណ។ ចុះលោកអាចបញ្ជាក់បានទេថា នៅពេលដែលក្រុមគ្រួសាររបស់លោកត្រូវបានគេបញ្ជូនទៅខេត្តពោធិ៍សាត់ តើនៅពេលនោះ លោកមានដឹងទេចំនួនមនុស្សដែលទៅជាមួយលោកនោះមានចំនួនប៉ុន្មាននាក់ដែរទេ?

**ឆ៖** បាទសូមគោរពលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ លោកសហព្រះរាជអាជ្ញា! ខ្ញុំមិនអាចគណនាអំពីចំនួនប្រជាជនដែលធ្វើដំណើរតាមការបង្ខំរបស់ខ្មែរក្រហមបានទេ ពីព្រោះច្រើនពេក ណាមួយក្នុងវ័យកុមារ ខ្ញុំមិនអាចគ្រប់គ្រង់នូវបញ្ហាទាំងនេះបានទេ។

**ស៖** បាទអរគុណ។ ពាក្យថាច្រើននេះគ្រប់គ្រាន់ហើយ។ មួយទៀតតាមអ្វីដែលបានជម្រាបជូនអង្គសវនាការមុននេះ ឃើញថាលោកបានធ្វើដំណើរចុះឡើងៗច្រើនទីកន្លែងណាស់នៅក្នុងខេត្តពោធិ៍សាត់ហ្នឹង។ ចុះលោកធ្លាប់ដែលឮ ឬក៏ឃើញ ឬក៏ តាទៀ ដែលជាអាណាព្យាបាលលោកហ្នឹង គាត់បាននិយាយពីឈ្មោះទីកន្លែងមួយដែលមានឈ្មោះថា ទួលពោធិ៍ជ្រៃ ដែរទេនៅពេលនោះ?

[១៤:២៩:៤០]

**ឆ៖** សូមគោរពលោកប្រធាន សូមគោរពលោកសហព្រះរាជអាជ្ញា! ចំពោះទួលពោធិ៍ជ្រៃនេះខ្ញុំមិនដែលឮទេ ពីព្រោះវានៅស្រុកដាច់ដោយឡែកពីគ្នា។ ខ្ញុំនៅស្រុកបាកាន ខេត្តពោធិ៍សាត់ មួយនៅស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។ ដូច្នេះ ការទំនាក់ទំនងពីស្រុកមួយទៅស្រុកមួយ ខ្ញុំពុំមានលទ្ធភាពក្នុងការដឹងទេ ឆ្ងាយណាស់ ហើយបើដើរនោះដើរទាល់តែគេរើចោល អាហ្នឹងបានដឹង។

**ស៖** បាទ អរគុណដោយសារពេលវេលាខ្ញុំសូមអស់សំណួរត្រឹមនេះ ហើយក៏សូមអរគុណលោក រំដួល ផងដែរដែលបានចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហមនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ។!

**លោក សុន អរុណ៖**

សូមគោរពក្រុមប្រឹក្សា សូមគោរពលោកប្រធាន។ ជម្រាបសួរលោក រំដួល។ ខ្ញុំក្នុងនាម លោក នួន ជាខ្ញុំមិនមានសំណួរអីសួរលោករំដួលថ្ងៃនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោកខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពអង្គសវនាការ។ ក្នុងនាមលោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេបាទ។ សូមអរគុណ។

[១៤:៣១:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោក យិន រំដួល។ ការស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាស្ថានភាពព្យសនកម្ម ហើយនិងសក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនាស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកនិងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ សូមលោករំដួលមានសុខភាពល្អ ជួបតែសំណាងល្អ ហើយវិលត្រឡប់ទៅវិញប្រកបសុវត្ថិភាព។ ហើយលោកអាចវិលត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុង

ការជូនលោក យិន រំដួល វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅឬទីកន្លែងស្នាក់នៅរបស់គាត់ ឬលំនៅដ្ឋានរបស់គាត់ទៅវិញបានហើយ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីខ្វះដប់នាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣២ នាទី ដល់ម៉ោង ១៤:៥០ នាទី)*

[១៤:៥១:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយជាបន្តនេះគឺស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាមTCCP-117។

មន្ត្រីរដ្ឋបាលតុលាការកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:៥២:៣៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ប៉ូ ឌីណា៖**

**ឆ៖** ចាស នាងខ្ញុំសូមជម្រាបសួរលោកប្រធាន។ ចាស នាងខ្ញុំឈ្មោះ ប៉ូ ឌីណា។

**ស៖** អរគុណលោកស្រី ប៉ូ ឌីណា។ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ចាស នាងខ្ញុំមានអាយុ ៦០ឆ្នាំហើយចាស។

**ស៖** បាទ អរគុណ។ ហើយលោកស្រីអាចប្រាប់នូវទីកន្លែងកំណើតរបស់លោកស្រីបានទេ តើលោកស្រីកើតនៅទីកន្លែងណា?

**ឆ៖** ចាស ឆ្នាំកើត កំណើតរបស់នាងខ្ញុំនៅឃុំ -- ស្រុកមុខកំពូល ឃុំកោះដាច់ ខេត្តកណ្តាល។

**សៈ** បាទ អរគុណ។ ហើយតើសព្វថ្ងៃនេះលោកស្រីមានទីលំនៅៗកន្លែងណា? ហើយលោកស្រីប្រកបមុខរបរអ្វី?

[១៤:៥៣:៣៧]

**ផៈ** ចាស សព្វថ្ងៃ ខ្ញុំរស់នៅខេត្តកំពង់ស្ពឺ នៅភូមិកាប់ទូក សង្កាត់កណ្ដាលដុំ ក្រុងច្បារមន។ មុខរបរបោកអ៊ុតចាស។

**សៈ** អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះ? ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ផៈ** ឪពុកបង្កើតខ្ញុំឈ្មោះ កុយ ប៉ូ, ម្ដាយនាងខ្ញុំឈ្មោះ ប្រែង រ៉េន។

**សៈ** បាទ អរគុណ។ ហើយសព្វថ្ងៃនេះលោកស្រីមានស្វាមីដែរទេ? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ផៈ** ចាស សព្វថ្ងៃនេះ ខ្ញុំគ្មានស្វាមីទេ ស្វាមីខ្ញុំបានស្លាប់បាត់បង់ចោលខ្ញុំហើយ។ ចាស មានកូនមួយនាក់។

**សៈ** អរគុណលោកស្រី។ ហើយក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះនឹងផ្ដល់ឱកាសជូនទៅលោកស្រី ដើម្បីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានឡើងចំពោះលោកស្រីមានជាអាទិ៍ការខូចខាតខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬក៏សម្ភារៈដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីសម្រេចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់លើជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រី ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៩ ហើយសេចក្ដីថ្លែងរៀបរាប់នេះលោកស្រីអាចប្រើពេលវេលានៅក្នុងអំឡុងពេលដែលមេធាវីរបស់លោកស្រីសួរសំណួរ ឬក៏បន្ទាប់ពីមេធាវីរបស់លោកស្រីតាំងសំណួរចំពោះលោកស្រី ដោយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឲ្យក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាំងសំណួរចំពោះលោកស្រីមុនពេលដែលលោកស្រីថ្លែងរៀបរាប់អំពីទុក្ខវេទនា។

ដូច្នេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិដើម្បីមានឱកាស

តាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយនិងស្តាប់នូវសេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់នៅក្នុងអំឡុងពេលដែលបានបែងចែកឲ្យ។ សូមអញ្ជើញលោកស្រីមេធាវី!

[១៤:៥៦:២៦]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន និងជាបឋមសូមគោរពលោក លោកស្រី -- លោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ជម្រាបសួរលោកស្រី ប៉ូ ឌីណា! នាងខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរទៅកាន់លោកស្រី។ ដំបូងខ្ញុំចង់សួរអំពីប្រវត្តិលោកស្រីបន្តិចទាក់ទងទៅនឹងមុនឆ្នាំ១៩៧៥ តើមុនឆ្នាំ១៩៧៥នុ៎ង ក្រុមគ្រួសាររបស់លោកស្រីរស់នៅកន្លែងណាដែរ?

**លោកស្រី ប៉ូ ឌីណា៖**

**ឆ៖** ចាស មុនឆ្នាំ១៩៧៥ហ្នឹង នាងខ្ញុំរស់នៅមុខវាំង នៅស្ថានទូតថៃចាស។

[១៤:៥៧:២១]

**ស៖** មុននឹងបន្តិចលោកស្រីបានជម្រាបជូនអង្គសវនាការថា លោកស្រីបានរៀបការរួចហើយ តើប្តីរបស់លោកស្រីមានឈ្មោះអ្វីដែរ?

**ឆ៖** ចាស ស្វាមីរបស់ខ្ញុំឈ្មោះ សៅ សារិន។

**ស៖** ហើយគាត់ប្រកបមុខរបរអ្វីដែរ ហើយនៅទីណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*។

**ប្រធានអង្គជំនុំ៖**

លោកស្រី ឌីណា កុំអាលទាន់ឆ្លើយតបរង់ចាំ បង្អង់បន្តិចនៅបន្ទាប់ពីស្តាប់សំណួរសួររហូតដល់ក្បាលមីក្រូហ្វូននៅចំពោះមុខលោកស្រីហ្នឹងឲ្យភ្លើងសញ្ញាក្រហម ដែលជាសញ្ញាថាក្បាលមីក្រូហ្វូនហ្នឹងចាប់ផ្តើមប្រត្តិបត្តិការ លោកស្រីនិយាយទៅប្រព័ន្ធសំឡេងរបស់លោកស្រីនឹងចូលទៅប្រព័ន្ធផ្សព្វផ្សាយចែកចាយសំឡេងនៅក្នុងសាលសវនាការនេះទាំងមូលបាទ។

បាទ សួរម្តងទៀត!

[១៤:៥៨:២៥]

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ខ្ញុំសូមសួរថា តើលោកប្ដីរបស់លោកស្រីហ្នឹងមានឈ្មោះអ្វីដែរ ហើយគាត់ប្រកបរបរអ្វីដែរកាលនុំង ហើយនៅកន្លែងណាដែរ?

**លោកស្រី ប៉ូ ឌីណា៖**

**ឆ៖** ចាស ស្វាមីរបស់ខ្ញុំឈ្មោះ សៅ សារិន បានប្រកបមុខរបរធ្វើការនៅស្ថានទូតថៃនៅម្ដុំមុខវាំង ដំណាក់ព្រះអង្គម្ចាស់ពៅ។

**ស៖** ចុះចំពោះរូបលោកស្រីផ្ទាល់ តើលោកស្រីមានប្រកបការងារអ្វីដែរ ឬក៏នៅកន្លែងណា?

**ឆ៖** ចំពោះរូបនាងខ្ញុំផ្ទាល់ នាងខ្ញុំបានធ្វើការនៅផ្នែកខាងចុងភៅ នៅស្ថានទូតថៃដែរចាស។

**ស៖** តើស្ថានភាពជីវភាពរបស់លោកស្រីអំឡុងពេលនោះយ៉ាងម៉េចដែរ? លោកស្រីអាចរៀបរាប់ជូនអង្គសវនាការផងដែរឬទេ?

**ឆ៖** ចាស ក្នុងពេលនោះស្ថានភាព ជីវភាពរបស់នាងខ្ញុំមានការធូរធារ អត់មានលូតលាស់អ្វី -- អ៎! អត់មានខ្វះខាតអ្វីទេ មានការថ្កុំថ្កើងឧត្តុង្គឧត្ដមរុងរឿង ក្រុមគ្រួសារទាំងសងខាងចាស។

[១៥:00:00]

**ស៖** សូមអរគុណ។ ហើយឥឡូវខ្ញុំចង់ឈានចូលឆ្នាំ១៩៧៥វិញ។ ពាក់ព័ន្ធជាមួយហ្នឹងខ្ញុំចង់សួរលោកស្រីថា តើលោកស្រីអាចរៀបរាប់ជូនអង្គសវនាការបានដែរឬទេនូវហេតុការណ៍ ឬក៏ទុក្ខវេទនាដែលលោកស្រីបានជួបប្រទះចាប់តាំងពីការចាប់ផ្ដើមនៃរបបខ្មែរក្រហម រហូតដល់របបខ្មែរក្រហមដួលរំលំជូនអង្គសវនាការបានដែរឬទេ? បើសិនជាលោកស្រីអាចរៀបរាប់ឲ្យលម្អិតបាន សូមលោកស្រីអញ្ជើញរៀបរាប់។

**ឆ៖** ចាស នៅពេលថ្ងៃទី១៧ មេសា ពេលថ្ងៃ១៧ មេសា បានទាហានខ្មែរក្រហមបានចូលទៅក្នុងផ្ទះរូបរបស់នាងខ្ញុំចាស។ ចូលហើយបានសួររកម្ចាស់ផ្ទះ។ រកម្ចាស់ផ្ទះហើយខ្ញុំឆ្លើយថា ម្ចាស់ផ្ទះគេមិននៅទេ អត់ -- ខ្ញុំនេះហើយគឺអ្នកយាមផ្ទះទេ មិនមែនអ្នកម្ចាស់ផ្ទះទេ។ គេបានសួរហើយសួរទៀតបានបង្ខំចិត្ត ហើយខ្ញុំឆ្លើយតបទៅវិញថា ខ្ញុំមិនមែនម្ចាស់ផ្ទះទេ ខ្ញុំអ្នកយាមផ្ទះ។ គេមិនជឿទេ ចូលមកលុកលុយបោកសម្ភារៈធ្វើការនៅក្នុងផ្ទះហ្នឹងខ្ទេចខ្ទីអស់។ ទាត់ធាក់របស់របបទ្រព្យសម្បត្តិនៅគេហដ្ឋាននោះតែម្ដង។

[១៥:០១:១៧]

បន្ទាប់មកទៀត ស្វាមីនាងខ្ញុំបានឮសំឡេងក្នុងក្លាំង គាត់ក៏ស្ទុះចេញមក១ក៏ទាហានខ្មែរក្រហមហ្នឹងបួនប្រាំនាក់ហ្នឹងក៏ចាប់ក្របួចកអាវស្វាមីរបស់នាងខ្ញុំចាស។ ចាប់ហើយ សួរថានេះគឺម្ចាស់ផ្ទះមែន? ស្វាមីរបស់ខ្ញុំឆ្លើយតបទៅវិញថា មិនមែនម្ចាស់ផ្ទះទេ គឺខ្ញុំអ្នកយាមផ្ទះ។ ហើយក៏ពួកទាហានខ្មែរក្រហមហ្នឹងមិនជឿពាក្យសម្ដីស្វាមីរបស់ខ្ញុំទេ គេឃើញគាត់ថាគាត់រូបរាងស្អាត ថាអ្នកធ្វើការ គេមិនមែនថាគាត់ហ្នឹងអ្នកយាមផ្ទះ ចាំផ្ទះនោះទេចាស។ ពេលនោះ ហើយក៏ពួកវាបានដកស្វាយកាំភ្លើងមកវ៉ៃប្ដីខ្ញុំ។ ខ្លះទាត់ខ្លះធាក់ ឲ្យឆ្លើយឲ្យត្រង់មក "មិត្តឯងឆ្លើយឲ្យត្រង់មក នេះអ្នកម្ចាស់ផ្ទះមែនឬ?" ហើយប្ដីខ្ញុំនៅតែឆ្លើយថាមិនមែនទេ។ នាងខ្ញុំក៏សំពះអង្វរសុំទោសថាកុំធ្វើបាបស្វាមីនាងខ្ញុំអី។ ពេលនោះគេមិនស្ដាប់សម្ដីរបស់ខ្ញុំទេ គេទាក់ធាក់ប្ដីខ្ញុំ អ៊ីចឹងឈឺចាប់ណាស់។ វ៉ៃហើយ គេចាប់ចងប្ដីខ្ញុំចងសេក ដាក់សសរកណ្ដាល។ ខ្ញុំទៅលូនសំពះបាតជើងគេ គេអត់ដោះលែងប្ដីខ្ញុំទេ។ នាងខ្ញុំមានការតក់ស្លុតភ័យយ៉ាងខ្លាំងឈឺចាប់ណាស់។ ដោយគេចាប់ចងប្ដីខ្ញុំហើយ វ៉ៃប្ដីខ្ញុំទាត់ធាក់យ៉ាងឃោឃៅជាទីបំផុត។

[១៥:០៣:០៧]

ពេលនោះហើយបានឮដល់ នរោត្ដម ទ្រង់កន្ទុល លោកបានយាងចេញមក ចង់និយាយប្រាប់គេថាកុំធ្វើបាបគេអី គេមិនមែនអ្នកម្ចាស់ផ្ទះទេ គេមិនជឿទៀត។ គេនៅតែវ៉ៃនៅឈាមហូរហាមប្ដីខ្ញុំ។ ពេលនោះ ខ្ញុំនៅក្រោបន្ទប់ វេទនាឃើញប្ដីខ្ញុំគេធ្វើបាប។ ដល់ពេលនោះ ហើយបានវាសុខចិត្តដោះលែងប្ដីខ្ញុំឲ្យស្រាយចំណងដៃប្ដីខ្ញុំ មួយសន្ទុះបានពួកវាបានចេញចាកចេញពីផ្ទះដែលខ្ញុំនៅ។

ដល់ពេលមួយដំណាក់កាលទៀត ពេលយប់ ម៉ោងប្រាំបីយប់ វាបានមួយក្រុមទៀតបានមក បានដេញឲ្យនាងខ្ញុំចាកចេញពីទីលំនៅដ្ឋាន ក្រុមគ្រួសារទាំងប៉ុន្មានប្រមូលចេញឲ្យអស់ ព្រោះគេរៀបចំក្រុង។ នាងខ្ញុំសូមអង្វរថាកុំអាលអី ខ្ញុំចាំភ្លឺចាំខ្ញុំធ្វើដំណើរទៅ ឥឡូវនេះយប់ហើយ សូមអង្វរសូមអាណិតមេត្តាកុំធ្វើបាបខ្ញុំ ខ្ញុំយកអីអត់ទាន់ទេ ស្រវាអីក៏អត់បានដែរ។ វាថា "អត់ទេ ត្រូវតែចេញ! អ្នកឯងចេញភ្លាម! បើមិនចេញទេយើងត្រូវកម្ទេចចោលឲ្យអស់ឥឡូវហើយ"។ ភ័យភិតពេក នាងខ្ញុំតក់ស្លុតស្រវាអីក៏មិនទាន់ដែរ ណាប្ដីមានរបួស ណា --

[១៥:០៤:៤៧]

ដល់ពេលនោះហើយក៏ចាប់ធ្វើដំណើរទៅបានម៉ូតូមួយធ្វើដំណើរតាមផ្លូវរហូតទៅដល់ស្ពានមុនីវង្សបានដើរពេលនោះហើយ ដែលមានការចង្អៀតតាមផ្លូវថ្នល់ជាតិ និងមិនអាចដើរបានវែងឆ្ងាយទេ។ ដើរ

បានតែ៥ម៉ែត្រម្ដង។ មួយសន្ទុះសុំគេសម្រាក គេមិនឲ្យសម្រាកទេ គេដេញទៅមុខទៀត។ ដល់ដេញទៅមុខអ៊ីចឹងហើយ នាងខ្ញុំក៏ចេះទៅតាមគេ ទៅមុខៗ ទៅរហូត ចេះតែទៅ ដើរៗទៅដល់ យប់កន្លែងណាសុំគេស្នាក់នៅ គេមិនឲ្យឈប់ទៀត ចេះតែទ្រាំដើរទៅទៀត ដើរដល់អស់ដៃអស់ជើង ដួលសន្លប់តាមផ្លូវ។ ពេលនោះហើយ កូនខ្ញុំក៏សន្លប់ ខ្ញុំក៏សន្លប់ ស្រាលដៃអស់រលីង។ ណាមួយប្ដីខ្ញុំ ក៏គាត់ទ្រុឌទ្រោមវាយដំច្រើន ធ្វើបាប លំបាកវេទនាណាស់តាមផ្លូវ ក៏ឈប់សម្រាកបានមួយយប់តាមផ្លូវហ្នឹងទៅចាស។ ដល់ភ្លឺហើយដើរទៅទៀត ដើរពីរបីថ្ងៃបានដល់ព្រែកឯង។ ទៅដល់កន្លែងព្រែកឯងហ្នឹង គេប្រកាសស្រែកមីក្រូថា "បងប្អូនណានៅទីក្រុងភ្នំពេញ ឲ្យមកចុះឈ្មោះ"។ ដល់អ៊ីចឹងហើយ បងប្អូនខ្លះក៏ទៅចុះឈ្មោះទៅ បងប្អូនខ្លះក៏គេចវេះ។ ប្ដីខ្ញុំបានឈាងជើង -- ជើងចូលទៅចុះឈ្មោះនឹងគេហើយ។ ដល់អ៊ីចឹងហើយ ខ្ញុំក៏អួសដៃថាកុំទៅអីបង ព្រោះមិនស្រួលទេ។ ហេតុការណ៍នេះមិនស្រួលទេ កុំចុះឈ្មោះត្រឡប់ទៅទីក្រុងភ្នំពេញធ្វើអ្វី។ យើងដើរបន្តទៅមុខទៀត។ ដល់អ៊ីចឹងហើយបាននាងខ្ញុំដើរទៅមុខទៀត។ ដើរទៅមុខទៀតបីថ្ងៃបានទៅដល់វត្តព្រែកឯង បានទៅដល់ព្រែកឯងហើយបានសម្រាកនៅទីនោះមួយយប់។ ដល់សម្រាកទីនោះមួយយប់ហើយ បានព្រលឹមឡើងឆ្លងដរកន្លែងម្តុំជ្រោយតាព្រហ្មហ្នឹងទៅស្រុកកំណើត ស្វែងទៅរកស្រុកកំណើត។ ស្រុកកំណើតនាងខ្ញុំដល់វត្តសារីកែវ ហើយបានដើរទៅដល់អរិយក្សត្រ។ អរិយក្សត្រព័ទ្ធមកព្រែកថោង ព្រែកល្ហុង ព្រែកក្របៅហ្នឹង បានឆ្លងទៅស្រុកកំណើតនៅកោះដាច់ ស្រុកមុខកំពូល ឃុំកោះដាច់ ភូមិកោះដាច់ ខេត្តកណ្ដាល។

[១៥:០៧:១០]

ឆ្លងទូកទៅដល់ស្រុកកំណើតហើយ ពេលនោះគេបានមកចុះឈ្មោះក្រុមគ្រួសារមានប៉ុន្មាននាក់អ៊ីចឹង បានចុះឈ្មោះហើយអ៊ីចឹង ក៏គេថា "អ្នកឯង១៧ -- អ្នកឯងពួក១៧ អ្នកឯងមិនអាចនៅទីនេះបានទៀតទេ ត្រូវបន្តទៅមុខទៀត"។ ដល់អ៊ីចឹងនាងខ្ញុំសុំគេថាខ្ញុំមកដល់ស្រុកកំណើតហើយ ខ្ញុំសូមជ្រកកោននៅទីនេះផង។ គេក៏បដិសេធពាក្យសម្ដីខ្ញុំថាមិនអាចឲ្យនៅបានទេ ព្រោះវាមានការខ្វះខាត មិនអាចធ្វើស្រែបានទេ ស្រុកចម្ការ ទៅធ្វើស្រែនៅខេត្តផ្សេងទៀត។ ដល់អ៊ីចឹងហើយ ក៏គេបានចុះឈ្មោះក្រុមគ្រួសារប្រហែលជាចំនួនថាមួយខែ គេបានចុះឈ្មោះក្រុមគ្រួសារនាងខ្ញុំឲ្យទៅឡើងកាណូត--

**ស៖** លោកស្រីខ្ញុំសូមកាត់បន្តិច។ ដោយសារតែល្បឿនរបស់លោកស្រីដូចជាហាក់បីដូចជារាងលឿនបន្តិច ហើយអ៊ីចឹងខ្ញុំចង់សួរត្រឡប់បន្តិច ដើម្បីជៀសវាងកុំសួរសាចុះសាឡើង។ ខ្ញុំចង់សួរលោកស្រីបញ្ជាក់បន្តិចថា នៅពេលដែលថ្ងៃដែលលោកស្រីចាកចេញពីទីក្រុងភ្នំពេញហ្នឹង លោកស្រីមានជួប

ប្រទះនូវហេតុការណ៍អ្វីដែលគួរឲ្យកត់សម្គាល់ទេ? ដើម្បីមានភាពងាយស្រួលដល់លោកស្រី ខ្ញុំសូមលើកជាឧទាហរណ៍ថា ឧទាហរណ៍ថា ដូចជាលោកស្រីបានឃើញទិដ្ឋភាពអីដែលគួរឲ្យកត់សម្គាល់ ឧទាហរណ៍ដូចជាមានសាកសពស្លាប់ ឬក៏ស្ថានភាពប្រជាជនផ្សេងៗ ហើយនិងការធ្វើដំណើរតាមផ្លូវហ្នឹង លោកស្រីការហូបចុក ការស្នាក់នៅ មានទទួលការរងការលំបាកដែរឬទេ អំឡុងពេលនោះ?

[១៥:០៩:១២]

**ឆ៖** ការធ្វើដំណើរតាមផ្លូវមានការលំបាក អត់ស្បៀងអាហារ ខ្វះខាតហូបចុក គ្មានចាន គ្មានឆ្នាំង ពេលនោះហើយដែលធ្វើឲ្យនាងខ្ញុំមានការឈឺចាប់។ ដល់ដើរៗ ដើរធ្វើដំណើរតាមផ្លូវមក តាមផ្លូវឃើញគេចងទាហាន ចាស ចងទាហានលន់ នល់ ទាំងខ្សែៗ ហេតុការណ៍នោះ ខ្ញុំបានឃើញជាក់ស្ដែងនឹងភ្នែក ប៉ុន្ដែមិនដឹងចងយកទៅខាងណាទេ គឺដើរបញ្ច្រាស់គ្នា ចាស។ ថ្ងៃនោះហើយ នាងខ្ញុំមានឃើញការណ៍ហេតុដូច្នេះ មានការកត់ស្លុតភិតភ័យយ៉ាងខ្លាំង។ មិនដឹងជាយ៉ាងមុខទៅមុខទៀត ជីវិតរបស់ក្រុមគ្រួសារទាំងអស់គ្នា។ ហេតុការណ៍ឃើញស្លាប់តាមផ្លូវហូរហែអ៊ីចឹងចាស។ គេមិនដឹងទៅស្លាប់ពីម៉ោងណា ថ្ងៃណាទេ ប៉ុន្ដែឃើញស្លាប់តាមថ្នល់ចាស។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំចង់សួរលោកស្រីពាក់ព័ន្ធជាមួយនឹងលោកស្រីថាទៅដល់ស្រុកកំណើត។ ពេលដែលលោកស្រីទៅដល់ស្រុកកំណើតហ្នឹងលោកស្រីមានបានជួប ឬក៏ទទួលជួបប្រទះនូវហេតុការណ៍អ្វីចំពោះក្រុមគ្រួសារលោកស្រីដែរឬទេ? ឬក៏មានបញ្ហាអ្វីដែលបង្កជាការលំបាកដល់ក្រុមគ្រួសារលោកស្រីដែរឬទេ ពេលដែលលោកស្រីទៅដល់ស្រុកកំណើតនោះ?

[១៥:១០:៤៣]

**ឆ៖** ចាសពេលនោះបានទៅដល់ទីស្រុកកំណើតហើយ មានការខ្វះខាតទីលំនៅជ្រកកោន ចាស។ សូម្បីតែស្លឹកមួយកណ្ដាបក៏គ្មានដែរកាលណោះ។ សម្រាកនៅនឹងដី ចាស យកមេឃធ្វើមុង ធ្វើដំបូលអត់ទាន់មានអ្វីទីពឹង។ ឯស្បៀងអាហារ ក៏អត់មានអង្ករ ជាត្រី ឬក៏មិនដឹងទៅបើកឯណា អីណា កាលនោះចាស។ មានការខ្វះខាតយ៉ាងខ្លាំង ដោះស្រាយមិនចេញដឹងទៅពឹងពាក់អ្នកណា។ ៣ថ្ងៃបានគេបើកម្ដង បានឲ្យប្អូនកំប៉ុងកាលនោះ របប។ ពេលថ្ងៃ ដើរឲ្យចេញទៅបញ្ចេញពលកម្ម ពេលយប់ឲ្យទៅជាន់រហាត់ទឹក ធ្វើការស្រែប្រាំង។ កាលណោះ គ្មានទំនេរទេ ចោលកូនចោលចៅលំបាករងទុក្ខ។

**ស៖** សូមអរគុណលោកស្រី។ អ៊ីចឹងខ្ញុំសូមបន្តសំណួរខ្ញុំទៀត។ ខ្ញុំចង់សូមសួរលោកស្រីថាតើលោកស្រីរស់នៅស្រុកកំណើតហ្នឹងរហូតដល់ចប់របបខ្មែរក្រហមហ្នឹងតែម្ដង ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** ចាសមិនអាចរបស់នៅស្រុកកំណើតនោះបានរហូតទេ។ អស់មួយរយៈប្រហែលជា១ខែ គេនឹងមកចុះឈ្មោះរូបខ្ញុំ ក្រុមគ្រួសារ និងប្រជាជនអ្នកដទៃទៀតឲ្យធ្វើដំណើរទៅមុខទៀត។ ឡើងកាណូត ឲ្យឡើងកាណូត ឡើងកប៉ាល់ មិនដឹងជាចាកចេញពីទីណាទេពេលនោះ។ ប្រជាជនទាំងអស់ឲ្យតែអ្នក១៧ មេសា គឺចុះឈ្មោះចាកចេញពីស្រុកកំណើតហើយ សុំអង្វរគេ សុំស្នាក់នៅស្រុកកំណើតក៏គេមិនឲ្យនៅដែរ ថាអ្នកឯង១៧ មេសា មិនអាចនៅស្រុកកំណើតជាមួយអ្នក១៨ បានទេ ចាស, មូលដ្ឋានគេហៅមូលដ្ឋាន។ ដល់អ៊ីចឹងខ្ញុំក៏ឈប់សុំទៅ គឺគេចុះឈ្មោះទៅ នៅថ្ងៃមួយវេលាម៉ោងដប់ពីរយប់ ក៏បានហៅឈ្មោះចុះទាំងគ្រួសារៗឡើងកាណូត មិនទៅទីដៅ ទៅទីកន្លែងណាទេ គឺហៅឡើងកាណូតទាំងយប់។ ក្នុងកាណូតមួយ ៣០, ៤០គ្រួសារអ៊ីចឹងទៅ។ មានជាន់លើជាន់ក្រោម។

[១៥:១៣:០៨]

ពេលនោះហើយ នាងខ្ញុំមានចិត្តភ័យភិតរន្ធត់ញាប់ញ័រ ឱ!សម្ភារៈអីវ៉ែអីវ៉ាន់ម៉ូតូ ដូចជារបស់ណាដែលគេត្រូវដកហូត គេដកហូតទុកហើយ គេអត់ឲ្យយកទៅទេ ព្រោះថាមិនបាច់យកអ្វីទៅទេ យកតែបន្តិចបន្តួចទៅបានហើយ។ សម្ភារៈទាំងប៉ុន្មានគឺដកទុកអស់។ ចាស កាលនុ៎ងក៏ ខ្ញុំមិនប៉ានតវ៉ាមាត់កអីទេ ព្រោះថាគេយកអីក៏យកទៅ ឲ្យតែជីវិតរស់នៅជួបជុំគ្រួសារក៏មិនប៉ានតវ៉ានឹងគេទេពេលនោះ។ ក៏ឡើងកាណូតតាំងពីម៉ោងដប់ពីរយប់អ៊ីចឹង ទាំងគេទាំងខ្ញុំ អ្នក១៧ ដូចគ្នាហ្នឹងក៏ឆ្លងកាត់ឡើងទៅកាត់មុខវាំងហ្នឹង ព្រះបរមរាជវាំងហ្នឹង ឆ្ពោះទៅជើងៗ។ ខាងមួយសន្ទុះធំទៅ ប្រហែលជាពីរម៉ោង បីម៉ោងអ៊ីចឹងបានឃើញមានចំណតឡាន ចំណត -- នាងខ្ញុំមិនដឹងថាទីនោះជាកន្លែងណាទេចាស។ បានឲ្យឡើងទៅលើឡាននាំគ្នាឡើងទៅប៉ុន្មានគ្រួសារ ដូចថា២០គ្រួសារ ៣០គ្រួសារក្នុងឡានហ្នឹង។ ឡានហ្នឹងគឺឡានទ្រុងចាស។

[១៥:១៤:១២]

ហើយពេលនោះហើយ ដែលកូនចៅ ក្មេងតូចតាច ទាំងគេ ទាំងខ្ញុំ អត់បាយក្រហាយទឹក យំរញ៉េករញ៉ៃចពេញទឹក ពេញដី ណែនតាន់តាប់ ច្របូកច្របល់ មិនដឹងជាកូន មិនដឹងជាចៅ ម៉ែឪឯណាទេពេលយប់ងងឹតមិនអាចមើលអ្វីឃើញទេចាសពេលនោះ។ ក៏ឡើងឡានបែកគ្នា ខ្លះក៏បែកកូនខ្លះក៏បែកចៅទៅពេលនោះ។

ធ្វើដំណើរទៅដល់ ចេះតែទៅៗមិនដឹងជាទីដៅនៅទីកន្លែងណាទេ មិនអាចដឹង ព្រោះយប់ងងឹតមិនអាចមើលឃើញអ្វីឡើយ។ ទៅដល់ទីដៅ ភ្លឺឡើងស្រាប់តែដល់ខេត្តពោធិ៍សាត់។ ដល់ខេត្តពោធិ៍សាត់

ហើយ ក៏ខ្ញុំសួរគេថានេះខេត្តអីអុំ? សួរ -- ឆ្លើយ អ្នកស្រុកហ្នឹងឆ្លើយថាហ្នឹងខេត្តពោធិ៍សាត់។ បានភ្ញាក់ខ្លួន អ្ហូ!មកដល់ខេត្តពោធិ៍សាត់ហើយ យើងកាន់តែឆ្ងាយពីស្រុកកំណើតហើយ។ ពេលនោះហើយនាងខ្ញុំមានចិត្តរន្ធត់ញាប់ញ័រកាន់តែខ្លាំង ភិតភ័យយ៉ាងខ្លាំងជាទីបំផុត ព្រោះបានចាកចេញពីស្រុកកំណើតហើយមិនដឹងជាមករស់នៅស្រុកគេមិនដឹងជាយ៉ាងម៉េចយ៉ាងម៉ាទេជីវិតពេលនេះ។

[១៥:១៥:១៩]

ដល់ពេលហើយអ៊ីចឹងក៏ប្រធានកងប្រធានក្រុម គេហ្នឹងមកទទួលយកទៅដាក់តាមក្រុម តាមកង តាមសហករណ៍រៀងៗខ្លួនអ៊ីចឹងទៅតាមក្រុម តាមគ្រួសារនីមួយៗ ១០គ្រួសារ ២០គ្រួសារអ៊ីចឹងទៅ តាមធំ តាមតូច តាមតិច តាមច្រើន។

មកនៅបានមួយរយៈហើយ គ្មានដំបូល គ្មានផ្ទះ គ្មានសម្បែងជ្រកកោនទេ ខ្ញុំសម្រាកនៅទីដីផ្ទាល់តែម្តងចាស ពេលនោះមិនទាន់មានការរៀបចំឲ្យមានជម្រកជ្រកកោនទេ។ មានការលំបាកកាន់តែខ្លាំងឡើងៗណាស្បៀងអាហារមិនបានឆ្អែតគ្រប់គ្រាន់ ណាគ្មានទីជម្រក គ្មានទីកន្លែងឲ្យពិតប្រាកដ ថានៅទីកន្លែងណាឲ្យបានសុខស្រួលគឺគ្មាន។ ជ្រកនៅក្រោមម្លប់ឈើដើមឈើ ចាសកាលណោះ។

ដល់ពេលបានធ្វើការមួយបានប្រហែលចំនួនជិត១ខែ បានគេជម្លៀសខ្ញុំទៅឲ្យនៅខាងសហករណ៍ស្វាយសនោះទៅទៀត។ ទៅសហករណ៍ស្វាយស ប្រហែល១០គ្រួសារជាងអ៊ីចឹងទៅក៏នាំគ្នាដាក់រទេះដាក់អីទៅធ្វើដំណើរទៅនោះក៏មិនទាន់មានជម្រកត្រឹមត្រូវទៀត។ ពេលនោះហើយដែលសេចក្តីរងទុក្ខវេទនាបានមកដល់ហើយចាស។ ពេលនោះបានគេឲ្យចាត់តាំងឲ្យប្តីខ្ញុំស្វាមីខ្ញុំទៅព្រៃ។ លើកទី១ ត្រឡប់មកវិញ លើកទី២ មកវិញ លើកទី៣ អត់ឃើញរហូតដល់សព្វថ្ងៃនេះចាស។ ឯចំណែកកូនៗប្រុសរបស់ខ្ញុំ--

[១៥:១៧:០៨]

**ស៖** ខ្ញុំសូមកាត់លោកស្រីបន្តិច។ មុននឹងលោកស្រីឈានដល់រឿងរ៉ាវរបស់កូនលោកស្រី។ ខ្ញុំចង់សួរបញ្ជាក់អំពីរឿងប្តីរបស់លោកស្រី។ នៅពេលដែលលោកស្រីបាត់ស្វាមីរបស់លោកស្រីបែប ហ្នឹង តើលោកស្រីមានស្វះស្វែង ឬក៏តាមរករូបគាត់ដែរឬទេ ពេលនុ៎ង?

**ឆ៖** ពេលដែលបាត់ស្វាមីរបស់ខ្ញុំហើយខ្ញុំក៏មិនដឹងទៅស៊ើបសួរអ្នកណាទេ។ ពេលនេះ ទៅនោះក៏គេថាមិនដឹង ទៅសួរត្រង់ណេះក៏គេថាមិនដឹង គេថាទៅភ្លូរចាស។ នាងខ្ញុំក៏មិនដឹងទៅស៊ើបសួរឯណាទេ។ បាត់ប្រហែលជាចំនួន១ខែជាង ២ខែ បានដឹងដំណឹងពាក្យសម្តីលាក់លួចមកប្រាប់ថាប្តីខ្ញុំគេយកទៅ

រៀនសូត្រ។ ពេលនេះហើយចិត្តខ្ញុំរន្ធត់អស់ហើយ។ ណាត្រូវប្តី ប្តីទៅបាត់។ ធ្វើឲ្យខ្ញុំស្ទើរតែដាច់ខ្យល់។

**ស៖** តើអំឡុងពេលហ្នឹងលោកស្រីមានបានដឹងអំពីមូលហេតុអ្វីបានជាគេយកប្តីលោកស្រីទៅរៀនសូត្រនោះដែរឬទេ?

[១៥:១៨:៤៦]

**ឆ៖** ពាក្យចចាមអារ៉ាមថា ប្តីខ្ញុំពាក់ស័ក្តិ៥។ ចោទថាប្តីខ្ញុំពាក់ស័ក្តិ៥ បានជាយកប្តីខ្ញុំទៅរៀនសូត្រ ហើយខ្ញុំមិនដឹងខ្លួនសោះ។ ប្តីខ្ញុំគ្មានពាក់ស័ក្តិ៥ឯណា? ពេលនោះហើយទឹកចិត្តនាងខ្ញុំសែនសោកស្តាយមិនដឹងជាប្តីខ្ញុំទៅទីកន្លែងណា? ពេលនោះក៏កងឈ្លបគេបានមកស៊ើបសួរខ្ញុំ គេមកតាមដានខ្ញុំថាខ្ញុំនេះប្រពន្ធស័ក្តិ៥។ ខ្ញុំបានឮប្តីខ្ញុំចាកចេញបាត់ទៅបាត់រហូត បាត់ទៅៗ គេថាយកទៅរៀនសូត្រច្បាស់ជាស្លាប់ហើយមិនអាចវិលត្រឡប់មកជួបខ្ញុំវិញទេ។ ខ្ញុំធ្លាក់ខ្លួនឈឺខ្លាំងណាស់ដោយសារអាឡោះអាល័យក្រុមគ្រួសារជាទីស្រឡាញ់របស់ខ្ញុំ។ គេចោទខ្ញុំថាប្រពន្ធស័ក្តិ៥ គេធ្វើបាប កំហែងគំរាមខ្ញុំ បង្ខិតបង្ខំឲ្យខ្ញុំធ្វើការគ្មានស្គាល់យប់ថ្ងៃទេ។ ខ្ញុំបានឈឺខ្លាំងណាស់ ខ្ញុំឲ្យកូនប្រុសរបស់ខ្ញុំអាយុ៦ឆ្នាំទៅបើករបប ពេលនោះវេទនា រងទុក្ខវេទនាណាស់។ នៅឆ្នាំ៧៦នេះ កូនប្រុសរបស់ខ្ញុំបានដើរទៅបើករបប។ របបនោះគ្រាប់ពោតមួយស្លាបព្រា គ្រាប់សណ្តែកមួយស្លាបព្រា ដើរត្រឡប់មកវិញមកដល់ជិតដល់ផ្ទះហើយ ជំពប់ជើងដួលបាត់នឹងស្មៅ បាត់អស់រលីង។ កូនប្រុសសម្លាញ់របស់ខ្ញុំបានអង្គុយរើសគ្រាប់ពោត គ្រាប់សណ្តែក ហើយលើកដៃសំពះសូមទោសខ្ញុំថា “អ្នកម៉ាក់អើយកូនសូមទោស កំពប់របបអស់ហើយ-- ខ្ញុំ --អ្នកម៉ាក់កុំវ៉ៃកូន” ខ្ញុំអាសូរសម្តីកូនខ្ញុំណាស់។ -- បានឆ្លើយប្រាប់ថា កូនអើយកុំយំ ម៉ាក់អត់យកទោសពៃរ៍កូនទេ កូនមាសម្តាយ កូនឯងកូនបានអីហូបទៅ គ្មានរបបទេ មានតែប៉ុណ្ណឹង។ ខ្ញុំអាណិតអាសូរកូនខ្ញុំណាស់ ដេកអត់បាយរហូត គ្មានរបបអីហូបចុកទេ។

[១៥:២២:០២]

**ស៖** លោកស្រី អត់ទោសលោកស្រី តើអត់អីទេ? លោកស្រីត្រូវការសម្រាកមួយនាទីដើម្បីសម្រួលអារម្មណ៍សិនដែរឬយ៉ាងម៉េចដែរ បើសិនជាលោកស្រីចង់សម្រាក ខ្ញុំនឹងធ្វើការស្នើសុំទៅលោកប្រធានអនុញ្ញាតឲ្យលោកស្រីធ្វើការសម្រាកមួយនាទីសិន? លោកស្រីអត់អីទេ?

**ឆ៖** ចាស។

**ស៖** អាចឆ្លើយតទៅទៀតបានដែរឬទេ?

**ឆ៖** ចាស បាន។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរពាក់ព័ន្ធជាមួយនឹងកូនស្រីបន្តទៀត។ អ៊ីចឹងក្រោយពីប្ដីលោកស្រីស្លាប់ហើយ តើមានអ្វីកើតឡើងចំពោះកូនប្រុសលោកស្រីដែរឬទេ ពេលនុ៎ង?

**ឆ៖** ក្រោយពីដឹងថាស្វាមីខ្ញុំស្លាប់ហើយ បានដឹងថាកូនខ្ញុំបានធ្លាក់ខ្លួនឈឺ។ ឈឺដោយសារអត់ឃ្លាន អត់អាហារ។ ឈឺខ្លាំងណាស់មិនដឹងជាមានថ្នាំសង្កូវណាព្យាបាលទេ អត់មានទាល់តែសោះ មានតែថ្នាំអាចម៍ទន្សាយយកមកលេបអត់ជា កូនខ្ញុំបានកើតជំងឺហើម រាកខ្លាំង។ ហៀបដាច់ខ្យល់ហ្នឹង ខ្ញុំអាណិតកូនខ្ញុំណាស់ អាសូរពាក្យសម្ដីកូន កូនសម្លាញ់មាសម្ដាយអើយ។ កូន -- ម៉ាក់ស្ដាយកូនណាស់ អាសូរណាស់ពាក្យសម្ដីរបស់កូន "អ្នកម៉ាក់កូនឃ្លានបាយណាស់ កូនសុំបាយមួយម៉ាត់មក កូនឃ្លានណាស់"។ កូនមាសម្ដាយ កូនឃ្លានបាយ ស្លាប់ទាំងវេទនា។ ទីបញ្ចប់កូនខ្ញុំស្លាប់អត់បាយ ឃ្លានបាយស្រែកដង្ហើយរកបាយ។ ទឹកចិត្តម្ដាយសែនឈឺចាប់បែបណាឮសម្ដីកូន។ កូនសម្លាញ់អើយ!!! ម្ដាយនឹកកូនណាស់ អាណិតអាសូរកូនណាស់ ដែលពេលស្រែកឃ្លានម្ដាយមិនដឹងរកអ្វីឲ្យកូនហូបបាន ម្ដាយតូចចិត្តខ្លួនម្ដាយណាស់។ អើយកូនមាសម្ដាយ។ កូនអើយ កូនស្លាប់ទាំងវេទនា ស្លាប់ទាំងស្រែកឃ្លានណាស់! ខ្ញុំជាម្ដាយមានទឹកចិត្តអាណិតអាសូរកូនបែបណាទៅ លោកប្រធានអើយ! ជួយខ្ញុំផង!

[១៥:២៥:១៣]

**ស៖** លោកស្រី តើលោកស្រីអាចទប់ចិត្តខ្លួនឯងបានដែរឬទេលោកស្រី?

**ឆ៖** បន្ទាប់មក--

**ស៖** លោកស្រីខ្ញុំសូមតាំងសំណួរតែម្ដង ដើម្បីជួយសម្រួលដល់អារម្មណ៍របស់លោកស្រី។ ខ្ញុំចង់សូមសួរលោកស្រីថា បន្ទាប់ពីលោកស្រីហ្នឹងមានការបាត់បង់ប្ដី និងកូន តើដំណើរជីវិតលោកស្រីបន្ទាប់មកទៀត តើមានជួបនៅហេតុការណ៍អ្វីទៀតដែរឬទេពេលនុ៎ង? ហើយស្ថានភាពនៅក្នុងមូលដ្ឋានដែលលោកស្រីរស់នៅនុ៎ងយ៉ាងម៉េចដែរ?

**ឆ៖** ពេលនោះបានដឹងដំណឹងឮដល់ -- តាមអ្នកម្ដាយរបស់ខ្ញុំបានឈឺធ្ងន់ ដល់ពេលដឹងដំណឹងថា អ្នកម្ដាយខ្ញុំឈឺធ្ងន់គាត់បានមើលកុមារៗក្រុមកងកុមារនោះបាន -- នាងខ្ញុំបានសុំគេទៅមើលម្ដាយគេមិនឲ្យទៅសោះ គេថា "មិត្តឯងចេះដឹងអីមានពេទ្យគេព្យាបាលមើលថែរក្សាគាត់ហើយ។ មិត្តឯងគិតតែខំបំពេញពលកម្ម បញ្ចេញពលកម្មទៅ ការងារតស៊ូជូនអង្គការឯណោះមិត្តឯងចេះដឹងអី មានពេទ្យគេមើលថែរក្សាហើយ"។ ចាស អ៊ីចឹងសូមម្ដងជាពីរដង គេមិនឲ្យទៅខ្ញុំក៏លួចរត់ទៅ។ ពេលយប់ ចាស ពេលយប់ខ្ញុំលួចរត់ទៅពេទ្យ ទៅមន្ទីរពេទ្យៗ ហ្នឹងមើលម្ដាយចាស មើលទៅម្ដាយខ្ញុំស្លាប់ គេអត់ឲ្យខ្ញុំ

ទៅជិតទេ។ គេយកម្តាយខ្ញុំដាក់លើរទេះ ខ្ញុំសូមគេយកមកកាប់ ម្តាយខ្ញុំគេមិនឲ្យយកមកឲ្យទេ។ ម្តាយខ្ញុំស្លាប់យ៉ាងវេទនាដែរ។

[១៥:២៧:២២]

សូមចូលទៅជិតម្តាយគេមិនឲ្យចូលទេ គេថា មិនបាច់មកជិតទេ។ មិត្តឯងកុំមករញ៉េរញ៉ៃកន្លែងនេះអីព្រោះមានអ្នកថែរក្សាមន្ទីរពេទ្យនេះគេយកទៅកប់យកទៅចោលហើយ មិត្តឯងកុំមកវីវរ ត្រឡប់ទៅវិញ។ ដេញខ្ញុំត្រឡប់ទៅវិញ ខ្ញុំក៏ដើរមកវិញមកទាំងទុក្ខសោកលំបាកវេទនា អត់បានឃើញមុខម្តាយស្លាប់។ ដាក់លើរទេះ គេយកទៅកប់ចោល ខ្មោចច្រើនបួនដប់នាក់ក្នុងមួយរទេះហ្នឹង។ ដឹងគេយកទៅកប់ទៅកន្លែងណាទេម្តាយខ្ញុំ គរលើគ្នាពេលនោះ។ ហេតុការណ៍ដូច្នេះហើយធ្វើឲ្យទឹកចិត្តរបស់ខ្ញុំស្ទើរតែឆ្កួតវង្វេងបាត់បង់អ្វីៗភាពកក់ក្តៅអស់ភាពជាទីពឹងរបស់ខ្ញុំពេលនោះ។

ជីវិតខ្ញុំដូចនាងបដាចារ ងាកទៅប្តីបាត់ ងាកទៅកូនស្លាប់ ងាកទៅម្តាយក៏ស្លាប់ បងប្អូនក៏ព្រាត់ប្រាស។ តើខ្ញុំសង្ឃឹមអ្វីទៀត សព្វថ្ងៃនេះខ្ញុំអស់ហើយសេចក្តីសង្ឃឹមជីវិតខ្ញុំក្នុងជាតិនេះ របស់ជាទីស្រឡាញ់របស់ខ្ញុំបាត់ពីខ្លួនខ្ញុំអស់។ សូមលោកតុលាការជួយខ្ញុំផង។

[១៥:២៨:៥៥]

**ស៖** ខ្ញុំសូមស្នើលោកស្រីជួយទប់ចិត្តបន្តិច ដើម្បីយើងអាចបញ្ចប់នៅរឿងរ៉ាវដំណើរជីវិតរបស់លោកស្រីបន្តទៅទៀត ដោយសារពេលវេលាយើងខ្លី។ អ៊ីចឹងខ្ញុំសូមសួរលោកស្រីបន្តទៀតថា តើបន្ទាប់ពីរឿងរ៉ាវទាំងនុ៎ងត្រូវ -- ដូចជាម្តាយ ប្តី កូន បាត់បង់ចោលលោកស្រីហើយ។ ខ្ញុំចង់ដឹងទៀតថា តើដំណើរជីវិតរបស់លោកស្រីក្នុងអំឡុងពេល -- ក្រោយពេលមានការបាត់បង់សាច់ញាតិហើយអ៊ីចឹង តើវាសនារបស់លោកស្រីទៅជាយ៉ាងណាដែរពេលនុ៎ង លោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេអំពីដំណើរជីវិតរបស់លោកស្រីនោះ? លោកស្រីមានជួបនៅឧបសគ្គអីទៀត ឬមួយក៏មិនមានបញ្ហាអ្វីចំពោះលោកស្រីទេនោះ? សូមលោកស្រីជួយជម្រាបជូនអង្គសវនាការឲ្យបានលម្អិតអំពីដំណើរជីវិតរបស់លោកស្រីបន្តទៅទៀត។

[១៥:២៩:៤៨]

**ឆ៖** ចាស បន្តបន្ទាប់ទៅមុខទៀត ពេលនោះបាត់បង់ស្វាមីជាទីស្រលាញ់ កូនចៅ ម្តាយឪពុកខ្ញុំអស់ហើយ។ វាបានបង្ខំ វាយដំ បង្ខំចិត្តឲ្យខ្ញុំយករៀបគ្រួសារ រៀបស្វាមីថ្មីទៀត ខ្ញុំមិនព្រម។ ពេលនោះហើយគេបានធ្វើបាបវ៉ៃដំខ្ញុំ យកខ្ញុំទៅដាក់គុក គុកឥតជញ្ជាំង។ វាដាក់គុកហើយ មុននឹងចូលគុក គេវ៉ៃ

ខ្មាំខ្មោចអស់ហើយរូបរាងកាយ។

**ស៖** តើពេលនោះ គេមានធ្វើការសួរចម្លើយលោកស្រីដែរឬទេ អំឡុងពេលនោះ?

**ឆ៖** ពេលនោះ គេបានសួរចម្លើយខ្ញុំថា មិត្តឯងក៏រឹងទទឹងនឹងអង្គការ អង្គការចាត់តាំងឲ្យធ្វើអ្វីម៉េចក៏មិនធ្វើតាម? មិត្តឯងក៏ចង់ឈ្នះ ចង់ចាញ់អីម្ល៉េះ។ មិត្តឯងតិចយកទៅកម្ទេចចោល។ នាងខ្ញុំក៏មិនឆ្លងឆ្លើយជាមួយគេដែរ សុខចិត្តស្ងៀម។ គេមកវ៉ៃ ស្ទុះមកវ៉ៃដំខ្ញុំអូសដូចសត្វតិរច្ឆានអីចឹង យកខ្ញុំទៅដាក់គុក។ វ៉ៃៗខ្ញុំហើយ យកងខ្ញុំទៅដាក់គុក។ ឃើញដល់អីចឹងហើយ ខ្ញុំក៏បានចូលនៅក្នុងគុកទៅ បានឃើញហេតុការណ៍ប្លែកៗច្រើនក្នុងគុកហ្នឹងទៀតចាស។

[១៥:៣១:២៧]

បន្ទាប់មក ខ្ញុំឃើញគេចងមនុស្ស បុរសម្នាក់ចងជាប់ក្រណាត់កៅស៊ូរុំមុខចាស រុំមុខហើយចងមុខចងដៃ ហើយជាន់ដើមទ្រូង សួរថា មិត្តឯងជាទាហាន លន់ នល់ មែនទេ? ហើយបុរសម្នាក់ហ្នឹងគេឆ្លើយថា ខ្ញុំមិនមែនទេៗ។ នៅតែសួរថា មិត្តឯងឆ្លើយមកត្រង់មក មិត្តឯងទាហាន លន់ នល់ មែន? គ្នាឆ្លើយថាមិនមែនទេ នៅតែវ៉ៃហើយវ៉ៃទៀត ចងក្រណាត់កៅស៊ូរុំមុខចាស។ ពេលនោះហើយនាងខ្ញុំឃើញញាក់សាច់ញាប់ញ័រអស់ហើយ រន្ធត់តក់ស្លុតភិតភ័យមិនដឹងធ្វើយ៉ាងម៉េចទេ។ ណាខ្លួនខ្ញុំឈឺហើមពេញខ្លួនអស់ គេវ៉ៃទារុណកម្ម ធ្វើបាប។

ដល់ស្អែកបានជា២ថ្ងៃ រំលង៣ថ្ងៃបានគេយកខ្ញុំទៅ។ ខ្ញុំឈឺខ្លាំង គេយកខ្ញុំទៅឲ្យដេកពេទ្យ នៅមន្ទីរ។ ដល់យកទៅដេកមន្ទីរពេទ្យហើយនាងខ្ញុំបានប្រហែលជាពីរ -- ៣អាទិត្យ ៣សប្តាហ៍ ក៏វារាងស្រួលហើយក៏បានរើសបានក្រដាសមួយសន្លឹកអីចឹងមក យកមកសរសេរទៅសុំចូលកងគេថ្មី។ ខ្ញុំអត់នៅកងចាស់ទៀតទេ ខ្ញុំលួចរត់ចេញពីមន្ទីរពេទ្យ ទៅនៅសុំគេជ្រកកោននៅកងចម្ការ។ ព្រោះខ្ញុំកងចម្ការបានមួយរយៈធំហើយ បានបញ្ជូនខ្ញុំទៅឲ្យទៅជញ្ជូនស្រូវនៅក្រឡោមភ្នុកចាស នៅខាងជ្រៃរុន ស្វាយដូនកែវនេះទៀត។

[១៥:៣២:៥៧]

ក៏បានធ្វើដំណើរទៅដល់ស្វាយដូនកែវហើយ កន្លែងម្តុំជ្រៃរុនហ្នឹងទៀត គេឲ្យខ្ញុំកងជញ្ជូនស្រូវឡើងភ្នំ។ ពេលនោះហើយ ជួបហេតុការណ៍ទៀតហើយខ្ញុំ។ បានឃើញហេតុការណ៍ជាក់ស្តែងច្បាស់ពិតនឹងភ្នែកតែម្តង។ ពេលនោះ ឃើញគេចាប់ចងមនុស្សទាំងខ្សែៗចាក់ជាជំពុះទុង ចាក់តែម្តងចាសចាក់ជ្រុចៗ។ ខ្ញុំហើយញាក់សាច់ ភ័យតក់ស្លុតចាស។ វង្វេងវង្វាន់អស់ហើយមិនដឹងទៅច្រកណាមក

ច្រកណីទេចាស នាំគ្នារត់គេចពីកន្លែងនុំងទៅ ក៏ចុះមកៗកន្លែងនៅកន្លែងទីលំនៅដ្ឋានវិញ។ ដល់មកហើយចំនួនបានប្រហែលជារយៈកន្លះខែ បានគេផ្លាស់ប្ដូរខ្ញុំឲ្យទៅកងកើបអាចម៍គោវិញ ដើររើសអាចម៍គោមកដាក់ស្រែ។ ពេលនោះ ក៏នាងខ្ញុំទៅធ្វើតាមពាក្យដែលគេបញ្ជា។ ដល់ទៅៗបានឃើញខាងពួកប្ញកក្រមាខៀវនេះចាស ឲ្យរើសក្ជួរស្រូវៗហើយ ពេលនោះហើយខាងទាហានខ្មែរក្រហមហ្នឹងក៏លើកកាណុងកាំភ្លើងហ្នឹង រះអ៊ីចឹងតែម្ដងចាស។ រះបាញ់ព្រូសៗអ៊ីចឹងទៅ ខ្ញុំឃើញអ៊ីចឹងក៏ញាក់សាច់ តក់ស្លុតភ័យញាប់ញ័រនៅក្រោមដើមកាលនុំងដើមៗភ្នា ពួននៅក្រោមដើមផ្កាហ្នឹងខ្លាចគេឃើញចាស។ ញាក់សាច់ឃើញអ៊ីចឹងទៅ ភិតភ័យរន្ធត់ញាប់ញ័រតក់ស្លុត មិនដឹងជាគិតយ៉ាងម៉េច។ ដើរទៅខ្លាចគេឃើញ មិនប៊ាន សុខចិត្តសម្ងំស្ងៀមអ៊ីចឹងទៅចាស។

[១៥:៣៤:៤៣]

កាលពេលនោះ នាងខ្ញុំបានស្ងប់ ហើយក៏នាងខ្ញុំបានដើរលបៗចេញពីគេ ឲ្យផុតពីគេមក កុំឲ្យខ្លាចគេឃើញទៅ គេយកខ្ញុំទៅសម្លាប់ចោល។ ក៏ដើរបានមកដល់ទីគេហដ្ឋានហ្នឹងទៅ បានគេឲ្យហូបបាយហូបទឹកអី។ ពេលវេលាដល់អ៊ីចឹងហើយយប់ ពេលវេលាយប់ហ្នឹងទៅក៏គេចាត់តាំងឲ្យឡើងទៅលើភ្នំទៀតហើយ ចាស គេកៀរកំពុងតែច្របូកច្របល់។ កាលនោះមិនដឹងជាឆ្នាំប៉ុន្មានទេ នាងខ្ញុំមិនដឹងទេ។ ពេលនោះហើយក៏លើកគ្នាដើរទៅឡើងភ្នំផ្សំផ្សាន គេកៀរទៅ ខ្ញុំអត់ព្រមទៅ ខ្ញុំនៅម្ខាងជើងថ្នល់ គេមកនៅខាងត្បូងថ្នល់ គេឲ្យកៀរឡើងភ្នំទៅខាងត្បូងថ្នល់។ ពេលនោះ នាងខ្ញុំមិនព្រមឡើងទៅតាមគេបីបួនប្រាំនាក់។ អ៊ីចឹងហើយគេស្ទុះមកវ៉ៃជើងនាងខ្ញុំហ្នឹង ចាស ត្រូវឥឡូវ -- ត្រូវពិការរហូតសព្វថ្ងៃហ្នឹង ចាស។ វ៉ៃជើងខ្ញុំបំបាក់កុំឲ្យខ្ញុំរត់ ព្រោះខ្ញុំរឹងទទឹងមិនទៅតាមគេ។ ដល់ពេលនោះហើយ នាងខ្ញុំសន្លប់បាត់ស្មារតី បាត់មាត់បាត់ក សន្លប់បាត់ឈឹង បានមិត្តភក្តិហ្នឹងគេជួយរឹតរួត អូសទៅ។ គេដាក់អង្រឹងសែងទៅទៀត សែងទៅលើភ្នំហ្នឹងទៀត។

[១៥:៣៦:០០]

ពេលនោះហើយ ធ្វើឲ្យខ្ញុំរងទុក្ខវេទនាមានការឈឺចាប់យ៉ាងខ្លាំងដែលរបបឃោរឃៅ ខ្មៅងងឹតនេះ ខ្ញុំឈឺចាប់ណាស់ ខ្ញុំមានចិត្ត -- ព្រោះខ្ញុំរងទុក្ខវេទនា របួសផ្លូវចិត្តហើយ របួសរូបរាងកាយទៀតគ្រប់បែបគ្រប់យ៉ាង។ ពេលនោះហើយ វាឲ្យឡើងទៅលើភ្នំ ទៅនៅលើភ្នំបានមួយរយៈ នៅលើភ្នំបានមួយរយៈ វាបានប្រើឲ្យទៅគាស់គល់ តែជើងនេះហើមនៅឡើយ ចេះតែដើរទៅ ចាស។ គាស់គល់ៗហើយ គាស់គល់មិនបានដាច់ផែនការគេ គល់ឈើហ្នឹង ក្នុងមួយគល់មួយហ្នឹង គេឲ្យបួននាក់ គាស់មិន

បានផុត ចប់ផែនការ គេបានមកអើតមើល ឃើញយើងមិនដាច់ផែនការ គេរើថែមទៅទៀត គ្នាប្អូននាក់ហ្នឹង លើកបោះទៅចំជង្គង់ទុរន់ទុរាហ្នឹង រហូតដល់សព្វថ្ងៃហ្នឹងទៀតទៅ ចាស។ រងទុក្ខលំបាក ឈឺចាប់គ្រប់បែបយ៉ាងអ៊ីចឹង។

**ស៖** តើអំឡុងពេលហ្នឹងលោកស្រីមានបានប្រព្រឹត្តកំហុសអ្វីដែលធ្វើឲ្យខាងអង្គការគេចាប់បានដែរ ឬក៏អត់ទេ? ពេលនុ៎ងមានធ្លាប់មានប្រព្រឹត្តកំហុសអីតទៅទៀតដែរ ឬក៏អត់ទេពេលហ្នឹង?

**ឆ៖** ចាស ដល់បន្ទាប់បន្តទៅទៀត ទៅមុខទៀត គេបានដកខ្ញុំពីក្រុមគាស់គល់ហ្នឹងទៅ គេបានឲ្យខ្ញុំទៅដើរទៅរកបន្លែមកដាក់អង្គភាព ចាស។ គ្នា១២នាក់ មួយក្រុមក្នុងអង្គភាពមួយ គេឲ្យម្នាក់ទៅចាស វា១២នាក់ ក្នុងមួយក្រុមៗគេយកម្នាក់។ ដើរទៅជ្រុលដល់តំបន់ហួស ចូលដី ទឹកដីខុសតំបន់គេគេចាប់ដាក់គុកមួយសាទៀតទៅកាលនោះ ចាស។ ដល់ចាប់ដាក់គុកហ្នឹង គុកហ្នឹង ដាក់ -- ហៅថាឈើហ្នឹង ដូចឈើរន្ធអ៊ីចឹង យកមកស្វកជើង ដាក់ច្រវាក់ អត់ឲ្យចេញទេចាស។ ពេលដែលចូលក្នុងគុកហ្នឹងពេលរៀបចូលរើ ទោសតិចដាក់តាមតិច ទោសច្រើនដាក់តាមច្រើន ដាក់តាមទោស តាមឋានៈ។ នាងខ្ញុំជាប់គុក ជាប់ច្រវាក់ដាក់ជើងអ៊ីចឹង។ រងទុក្ខលំបាកក្នុងគុកហ្នឹង បីបួនប្រាំថ្ងៃ។ ដល់ពេលហើយ ដល់ពេលព្រលឹមឡើង គេបញ្ចេញឲ្យនាងខ្ញុំទៅទូលស្លឹក។ នាងខ្ញុំមានឱកាសល្អអ៊ីចឹង ក៏រត់ចេញពីកន្លែងគុកហ្នឹង ទៅប្រាប់ប្រធានក្រុម ប្រធានកង ឲ្យមករំដោះ១១នាក់ហ្នឹងទៀតទៅ ចាស។ ពេលនោះទុក្ខសោកលំបាកវេទនារបស់ខ្ញុំ ឈឺចាប់ណាស់ ជួបហេតុការណ៍គ្រប់ចំណុច គ្រប់រឿង។

[១៥:៣៩:២៣]

**ស៖** អ៊ីចឹងខ្ញុំសូមបន្តសំណួររបស់ខ្ញុំទៀត។ លោកស្រីបានរៀបរាប់ពីខាងដើមថាលោកស្រីមានបាត់បង់ប្តី បាត់បង់កូន និងម្តាយ។ ប្តីបាត់ កូនស្លាប់ ម្តាយស្លាប់។ អ៊ីចឹងខ្ញុំចង់សួរថា ក្រៅពីពួកគាត់ទាំងបីនាក់ហ្នឹង តើលោកស្រីមានបាត់បង់សាច់ញាតិអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** ចាស ក្រៅពីហេតុការណ៍មក ខ្ញុំបានបាត់បងប្រុស ប្អូនប្រុស។ បងប្រុសមួយធ្វើការនៅស្ថានទូតថៃដែរចាសបាត់ ក្រុមគ្រួសារនុ៎ង កូនប្រពន្ធ។ បងប្រុសមួយទៀតគាត់ជាម៉ារីនជើងទឹកពាក់ស័ក្តិ៥ នៅខេត្តកំពង់ឆ្នាំង។ ហ្នឹងក៏បាត់រហូតដែរ មិនដឹងដំណឹងចាស។ ប្អូនប្រុសក៏បានស្លាប់ដំណឹងរហូតទាល់សព្វថ្ងៃហ្នឹងទៅចាស។ ពេលនោះហើយនាងខ្ញុំបានស្រាវជ្រាវដើររក ពេលឆ្នាំ៧៩ ហ្នឹងស្រាវជ្រាវដើររកសួរ មិនដឹងជាទៅទីកន្លែងណា។ សួរគេទៅ គេថាស្លាប់ ខ្លះគេថាស្លាប់។ ទៅសួរទៀតគេថាឃើញនៅពាក់កណ្តាលផ្លូវ ស្វះស្វែងដើររកបងប្អូនគ្រប់ញាតិ សួរគ្រប់ញាតិទាំងអស់មិនបាន

ឃើញ មិនដឹងថាគាត់នៅរស់ទេ។ បាត់រហូតទាល់សព្វថ្ងៃទៅ។

[១៥:៤០:៥០]

**ស៖** ពេលដែលលោកស្រីដើរស្វះស្វែងតាមរកសាច់ញាតិបន្តទៀត ដែលជាក្តីសង្ឃឹមចុងក្រោយរបស់លោកស្រី។ អ៊ីចឹងលោកស្រីពេលនុ៎ង នៅពេលដែលមិនបានដំណឹងពួកគាត់ តើលោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរចំពោះរូបលោកស្រីផ្ទាល់ហ្នឹង?

**ឆ៖** ពេលនោះនាងខ្ញុំបាត់បង់អ្វីៗទាំងអស់ បាត់បង់បងប្អូនម៉ែឪ ស្វាមី ព្រមទាំងកូនអស់ហើយ ឥឡូវហ្នឹងវាទឹកចិត្តរបស់ខ្ញុំមានការតក់ស្លុត មានការឈឺចាប់ មានការក្នុងខ្លួនរបស់ខ្ញុំ អារម្មណ៍របស់នាងខ្ញុំនេះ វាដូចចង់ ដូចថាឆ្កួត ដូចវិកលចរិតហើយចាស។ វាភ្លេចមុខ ភ្លេចក្រោយ គ្មានគិតអីអ្វីៗដឹងទាំងអស់ចាស។ ដោយសារអាឡោះអាល័យក្រុមគ្រួសារដែលបានបាត់បង់ជីវិតហ្នឹងទៅចាស។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកស្រីមេធាវី។ បាទជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[១៥:៤២:២០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកស្រី ប៉ូ ឌីណា។ ខ្ញុំមានសំណួរពីរបីសម្រាប់លោកស្រីនៅល្ងាចនេះ។ ទី១៖ លោកស្រីបានបញ្ជាក់ថា នៅពេលដែលរៀបរាប់អំពីការជម្លៀសដោយបង្ខំពីទីក្រុងភ្នំពេញនោះ លោកស្រីបាននិយាយថា លោកបានឃើញទាហាន លន់ នល់ ត្រូវបានគេចងភ្ជាប់ជាមួយគ្នា ហើយបានបណ្តើរចេញទៅ។ ថាតើលោកស្រីបានឃើញនោះ ឃើញនៅពេលណា? ប្រហែលជាប៉ុន្មានថ្ងៃ ឬក៏ក្នុងថ្ងៃណាដែរ?

**លោកស្រី ប៉ូ ឌីណា៖**

**ឆ៖** ចាស នាងខ្ញុំបានឃើញទាហាន លន់ នល់ គេចងហ្នឹង ឃើញពេលដែលកំពុងជ្រួលច្របល់ចេញពីទីក្រុងភ្នំពេញហ្នឹងចាស។ ហើយម៉ោងប្រហែលជាម៉ោងបួនភ្លឺចាស។

**ស៖** តើនៅចាំដែរឬទេនៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែត្រង់ចំណុចកន្លែងណា? ហើយគេបណ្តើរយកទៅកន្លែងណា?

[១៥:៤៣:៣៣]

**ផ៖** ចាស ខ្ញុំចាំបាននៅពេលដែលខ្ញុំឃើញហ្នឹង ហេតុការណ៍ហ្នឹងឃើញនៅមុខម្តុំបឹងស្នោចាស។ ឃើញបណ្តើរទៅ ខ្ញុំដើរទៅបណ្តោយផ្លូវអ៊ីចេះ គេដើរបញ្ច្រាសទៅទីក្រុងភ្នំពេញវិញចាស។

**ស៖** សូមអរគុណ។ នៅកន្លែងទីពីរដែលខ្ញុំចង់សួរលោកស្រីនោះ គឺថាលោកស្រីបាននិយាយថាគេតម្រូវឲ្យចុះឈ្មោះ ហើយនិងឈ្មោះនាមៗត្រកូលនៅត្រង់កន្លែងមួយ។ តើលោកស្រីអាចប្រាប់តុលាការបានទេទាក់ទងទៅនឹងការចុះឈ្មោះនេះ ពេលដែលទៅដល់នៅកន្លែងនីមួយៗ តើត្រូវផ្តល់ព័ត៌មានអ្វីផ្សេងទៀតទេអំពីរូបលោកស្រី ហើយនិងសមាជិកក្រុមគ្រួសារ ថាតើមានបងប្អូន អ្នកណាខ្លះជាបងប្អូន ធ្វើការងារអ្វីមុនឆ្នាំ មុនខែមេសា ឆ្នាំ១៩៧៥នោះដែរឬទេ?

[១៥:៤៥:១៨]

**ផ៖** ចាស នាងខ្ញុំសូមម្តងទៀត ដូចមិនយល់ចំណុចនេះចាស។

**ស៖** លោកស្រីបាននិយាយបន្តិចដែលថាគេឲ្យចុះឈ្មោះ។ ខ្ញុំចង់សួរលោកស្រីថាតើខ្មែរក្រហមតម្រូវឲ្យលោកស្រីផ្តល់ព័ត៌មានអ្វីទៀតទេថាមានបងប្អូនប៉ុន្មាននាក់ ហើយបងប្អូនទាំងអស់នោះធ្វើការងារអ្វី ជាមុខងារ មុខរបររកស៊ី។ តើត្រូវផ្តល់ព័ត៌មានទាំងអស់នោះទេនៅពេលចុះឈ្មោះម្តងៗនោះ?

**ផ៖** ដែលពេលនោះគេប្រកាសមីក្រូស្រែកថា "បងប្អូនណានៅទីក្រុងភ្នំពេញសូមអញ្ជើញចុះឈ្មោះទៅធ្វើការនៅក្រុងភ្នំពេញវិញ"។ ចំណុចនោះគេបានប្រកាសពាក្យសម្តីអ៊ីចឹងចាស។ ខ្ញុំមិនដឹងថាគេចុះហេតុការណ៍អ្វីទេ គ្រាន់តែឮថាប្រកាសអ៊ីចឹង។ ដល់អ៊ីចឹងខ្ញុំឮអ៊ីចឹង ខ្ញុំមិនឲ្យប្តីខ្ញុំទៅចុះទេ ខ្ញុំទាញដៃប្តីខ្ញុំថយវិញ។ នឹកឃើញហេតុការណ៍ទៅមុខទៅមិនដឹងជាយ៉ាងម៉េចទេ យើងកុំចុះអី។ ចាស ខ្ញុំយល់ថាអ៊ីចេះចាស។

**ស៖** តើនៅពេលណាទេដែលលោកស្រីបញ្ជាក់ថា គេចោទប្រកាន់ប្តីលោកស្រីថាជាវរសេនីយ៍ឯកថាជាស័ក្តិ៥ របស់ លន់ នល់ ដែលថាមានសាច់ញាតិម្នាក់ជាកងនាវានៅខេត្តកំពង់ឆ្នាំងនោះ?

[១៥:៤៧:១៦]

**ផ៖** កាលណោះនាងខ្ញុំបានទៅដល់ខេត្តពោធិ៍សាត់ ហើយគេតាមដាន។ មុនដំបូងនៅស្រុកកំណើតរបស់ខ្ញុំគេចោទប្រកាន់ថាប្តីខ្ញុំស័ក្តិ៥ ចាស មានឈ្មោះតាំងពីត្រឹមនៅស្រុកកំណើតហ្នឹងទៅ។

ដល់ទៅដល់ខេត្តពោធិសាត់ហើយ គេមើលសមត្ថភាពរបស់ប្ដីខ្ញុំវាខុសប្លែកពីមនុស្សធម្មតាបានគេ អាចចោទអ៊ីចឹងចាស ចោទជាស័ក្តិ៥ តាមការពិតគាត់មិនមែនស័ក្តិ៥ ទេ។ គាត់ជាជំនួយការស្ថានទូតថៃតែប៉ុណ្ណោះទេចាស។ ហើយបងប្រុសខ្ញុំបង្កើតនោះគាត់បានពាក់ស័ក្តិ៥ មែនគាត់ធ្វើអាម៉ារីនជើងទឹកខាងខេត្តកំពង់ឆ្នាំងពិតប្រាកដមែនចាស។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកស្រី ឌីណា។ លោកស្រីបាននិយាយថាពេលទៅដល់ខេត្តពោធិសាត់គេបានធ្វើការស្រាវជ្រាវពីរឿងប្រវត្តិគ្រួសារ។ តើលោកស្រីអាចប្រាប់តុលាការបានទេថាគេស្រាវជ្រាវដូចម្ដេច? គេឲ្យយើងផ្ដល់ជីវប្រវត្តិ តើគេមកជួបដើម្បីសួរសំណួរ ឬក៏ធ្វើដូចម្ដេច? អ៊ីចឹងសូមលោកស្រីជម្រាបខ្ញុំឲ្យបានពិស្ដារបន្តិចពីរឿងគេស្រាវជ្រាវប្រវត្តិរូបនេះ។

**ឆ៖** ចាស ពេលដែលទៅដល់ខេត្តពោធិ៍សាត់នោះហើយ គេក៏ស្រាវជ្រាវរកប្រវត្តិរូបធ្វើទាហានចាស។ ពេលនោះក្រុមគ្រួសាររបស់ខ្ញុំបានឆ្លើយថាគាត់អ្នករត់រ៉ឺម៉ក ម៉ូតូឌុបអ៊ីចឹងទៅ រត់រ៉ឺម៉កម៉ូតូអត់មានថាធ្វើការអ្វីទាំងអស់ ភូតកុហកគេអ៊ីចឹងចាស។ អត់មានប្រាប់ថាធ្វើការនេះនោះទេ គឺបិទ មិននិយាយអីទាំងអស់ និយាយឆ្លើយថារត់រ៉ឺម៉កម៉ូតូទេ ចាស។

**លោក ខេល លីសាក់៖**

ខ្ញុំសូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានអញ្ជើញមកថ្ងៃនេះ ហើយនិងឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធានខ្ញុំមិនមានសំណួរអ្វីទៀតទេ។ បាទ សូមអរគុណ។

[១៥:៤៩:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំមានសំណួរតែពីរសំណួរទេ។ នៅពេលលោកស្រីបានជម្រាបខាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីម្ដងរួចទៅហើយ ប៉ុន្តែខ្ញុំស្ដាប់ដូចមិនសូវច្បាស់ ខ្ញុំសូមសួរឡើងវិញ ដើម្បីជាប្រតិចារឹក។ នៅពេលដែលខ្មែរក្រហមចូលដល់ភ្នំពេញ គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលនោះអ្នកស្រីធ្វើការនៅ -- អ្នកស្រីជាមួយនឹងប្ដីអ្នក

ស្រីធ្វើការនៅកន្លែងណា? ហើយធ្វើជាអ្វី?

**លោកស្រី ប៉ូ ឌីណា៖**

**ឆ៖** កាលពីថ្ងៃ១៧ មេសា ឆ្នាំ៧៥ នាងខ្ញុំបានធ្វើការនៅកន្លែងស្ថានទូតថៃជាមួយគ្រួសារជាមួយក្រុមគ្រួសារខ្ញុំតែម្តងចាស។ នៅចំមុខវាំង ព្រះបរមរាជវាំង ខាងជើងឆៀងខាងកើតមុខវាំងផ្ទាល់ចាស។

[១៥:៥១:២៦]

**ស៖** ពេលដែលខ្មែរក្រហមចូលដល់ផ្ទះអ្នកស្រីធ្វើការ ពេលហ្នឹងគេ -- ខ្មែរក្រហមបានសួរអ្នកស្រីថាម្ចាស់ផ្ទះ។ អាហ្នឹងបើសិនជាខ្ញុំខុស សូមលោកស្រី -- អ្នកស្រីកែខ្ញុំផង។ អ្នកស្រីឆ្លើយថា "មិនមែនទេ" ហើយដល់ក្រោយមកទៀតបានឃើញប្តីអ្នកស្រីក៏សួរប្តីអ្នកស្រីទៀតថា "ម្ចាស់ផ្ទះ?" ប្តីអ្នកស្រីក៏ឆ្លើយថា "មិនមែនដែរ"។ អ៊ីចឹងទេ?

**ឆ៖** ចាស បានឆ្លើយតបទៅវិញថា "មិនមែនម្ចាស់ផ្ទះទេ ខ្ញុំជាអ្នកបម្រើ ចាំផ្ទះឲ្យគេទេ" ចាស។ ស្វាមីរបស់ខ្ញុំក៏ឆ្លើយថា "ខ្ញុំអ្នកយាមផ្ទះឲ្យគេទេ ម្ចាស់ផ្ទះគេមិននៅទេ" ចាស ខ្ញុំឆ្លើយបែបនេះចាសឆ្លើយតបទៅវិញ។

**ស៖** អរគុណ។ ពេលនុំងទាហានខ្មែរក្រហម អ្នកស្រីបានឃើញទិដ្ឋភាពនិងការរៀបចំខ្លួន មានន័យថាសម្លៀកបំពាក់របស់ខ្មែរក្រហមចូលមកដល់ផ្ទះអ្នកស្រីហ្នឹងមានសម្លៀកបំពាក់របៀបណា? ហើយចរិត អាកប្បកិរិយា សម្តីសំដៅមកលើអ្នកស្រី និងគ្រួសារអ្នកស្រីហ្នឹងយ៉ាងម៉េច?

**ឆ៖** ចាស ពេលនោះអាកប្បកិរិយាចូលមកដល់ផ្ទះនាងខ្ញុំហើយ អាកប្បកិរិយាឃោរឃៅសាហាវយង់ឃ្នងតែម្តងចាស។ "ឯណាម្ចាស់ផ្ទះ ម្ចាស់ផ្ទះទៅឯណាហើយ?" ចាស ឃោរឃៅចេញមកសាហាវអ៊ីចឹងតែម្តង។ ហើយខ្ញុំបានចេញមកថា "ចាស ខ្ញុំមិនមែនម្ចាស់ផ្ទះទេ ម្ចាស់ផ្ទះគេអត់នៅទេ" ឆ្លើយតបទៅវិញយ៉ាងស្រួលអ៊ីចឹងចាស។ "ខ្ញុំសួររកម្ចាស់ផ្ទះ ម្ចាស់ផ្ទះនៅឯណា?" រួចអ៊ីចឹងបានចូលមករើដំរបស់ទ្រព្យសម្ភារៈនៅក្នុងផ្ទះហ្នឹងចាស។ ខ្ទេចខ្ទីអស់ ប្រដាប់ប្រដាធ្វើការខាងស្ថានទូតហ្នឹងចាស។

[១៥:៥៣:៣៧]

ឃោរឃៅ ស្លៀកពាក់ខ្មៅ អាវខ្មៅ ស្បែកជើងកង់ឡាន ក្រវាត់ក្រមា-ក ស្ពាយកាំភ្លើងម្នាក់មួយដើម បួនប្រាំនាក់ គ្រប់ដៃ មកសម្លុតគំរាមកំហែង សួររកម្ចាស់ផ្ទះមិនឃើញហើយមករើទ្រោមខ្លួនស្វាមីរបស់ខ្ញុំទៀតចាស។ ពេលនោះហើយនាងខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង។

**ស៖** អរគុណ។ ពេលដែលគេបានវាយដំប្ដីអ្នកស្រីនុ៎ង បន្ទាប់ពីវាយដំហ្នឹង អ្នកស្រីបានជម្រាបតុលាការពីថ្មីៗនេះថា មានមនុស្សម្នាក់ចុះមកដើម្បីសួរថាតើមានហេតុអីនៅពេលនុ៎ង។ តើអ្នកណាដែលមកសួរពេលនុ៎ង?

**ផ៖** ចាស ពេលនោះ នរោត្ដម ទ្រង់កន្ដុល បានលោកយាងចេញពីក្នុងបន្ទប់មក។ សួរថា តើនរណា មានការ មានហេតុការណ៍អ្វីចាស? ហើយដល់ហើយអ៊ីចឹង ឃើញច្របូកច្របល់ចាប់ចងស្វាមីរបស់នាងខ្ញុំ បានគាត់មកជួយអង្វរ សុំទោសថា "កុំធ្វើបាបគេ គេមិនមែនម្ចាស់ផ្ទះទេ គឺគេអ្នកយាមផ្ទះទេ សូមដោះលែងគេទៅ" ចាស នរោត្ដម ទ្រង់កន្ដុល ចាស។

**ស៖** លោកបានជម្រាប -- អ្នកស្រីបានជម្រាបតុលាការថា អ្នកស្រីធ្វើការនៅទូតថៃជាមួយប្ដី ហេតុអីបានជា នរោត្ដម កន្ដុល ចុះមកអន្ដរាគមន៍ពេលដែលខ្មែរក្រហមវ៉ៃអ៊ីចឹងទៅវិញ?

[១៥:៥៥:៣០]

**ផ៖** ចាស អង្កាល់ណោះរបបខ្មែរក្រហមបានចូលមកដល់ នៅ១៧មេសា នេះមានការច្របូកច្របល់ ជ្រួលច្របល់ខ្លាំងពេក គាត់ក៏រត់ពីដំណាក់គាត់មកស្នាក់នៅដំណាក់ព្រះអង្គម្ចាស់ពៅ នេះជាមួយខ្ញុំនេះតែម្ដងចាស។ ដល់ពេលជ្រកហើយហ្នឹង ពេលយប់ក៏បាន -- កងទ័ពខ្មែរក្រហមហ្នឹងបានបណ្ដេញទាំងអស់គ្នាឲ្យចាកចេញទៅ ក៏ខ្ញុំបែកពីគាត់ គាត់ក៏បែកពីខ្ញុំទៅរៀងៗខ្លួនទៅពេលនោះចាស។ គាត់រត់មកជ្រកទីនេះ ដំណាក់គាត់មាននៅ -- ភ្លេចទៅហើយមិនដឹងត្រង់ណាទេ ភ្លេច។

**ស៖** បើអ៊ីចឹងអ្នកស្រីធ្វើការនៅទូតថៃទាំងពីរនាក់ប្ដីប្រពន្ធ ប៉ុន្ដែជាផ្ទះនេះ ជាផ្ទះរបស់អង្គម្ចាស់ពៅ អ៊ីចឹងអីយ៉ាងម៉េច សូមជម្រាបតុលាការឲ្យបានច្បាស់លាស់ពីរឿងប្រវត្តិហ្នឹងបន្ដិចមើល?

**ផ៖** ចាស ខ្ញុំធ្វើការនៅស្ថានទូតថៃ តែថៃហ្នឹងជួលដំណាក់ព្រះអង្គម្ចាស់ពៅ ហ្នឹងធ្វើការនៅទីនោះចាស។

**ស៖** អរគុណ។ អ្នកស្រីមានបានដឹងវាសនារបស់អង្គម្ចាស់នរោត្ដម កន្ដុល យ៉ាងម៉េចទេតាំងពីខ្មែរក្រហមចូលមកហើយ ពេលហ្នឹងខ្មែរក្រហមធ្វើយ៉ាងម៉េចខ្លះចំពោះគ្រួសារអ្នកស្រី។ មានន័យថា ប្ដីអ្នកស្រីជាមួយអ្នកស្រីធ្វើយ៉ាងម៉េចតទៅទៀត? ហើយចំពោះនរោត្ដម កន្ដុល ហ្នឹង តើត្រូវខ្មែរក្រហមធ្វើយ៉ាងម៉េច?

[១៥:៥៧:១១]

**ផ៖** ចាស ពេលនោះវេលាយប់ហើយ បានមួយក្រុមទៀតបានមកដេញ មកដេញឲ្យក្រុមគ្រួសារ

ហ្នឹងចាកចេញឲ្យអស់ពីផ្ទះហ្នឹងទៅ គាត់ក៏បានចាកចេញពីទីលំនៅដ្ឋានរបស់ខ្ញុំហ្នឹង ខ្ញុំក៏ចាកចេញទៅរៀងៗខ្លួនទៅចាស។ បែកបាក់ បែកគ្នាទៅ មិនដឹងជាគាត់ធ្វើដំណើរទៅដល់ណាមកអីណីក៏បាន -- ខ្ញុំមិនបានដឹងដែរ បែកគ្នារហូតទល់សព្វថ្ងៃនេះទៅចាស។

**ស៖** ខ្ញុំសួរថយត្រឡប់មកក្រោយបន្តិចវិញ ពេលដែលសម្ដេចនរោត្តម កន្ថុល ចុះមកអន្តរាគមន៍ថាអ្នកស្រីជាមួយប្ដីអ្នកស្រីហ្នឹងជាអ្នកយាមផ្ទះ ចាំផ្ទះអីអ៊ីចឹងទេ។ ពេលហ្នឹងខ្មែរក្រហមជាមួយនរោត្តម កន្ថុល ហ្នឹងមានតតាំងគ្នា -- ឧប្បត្តិហេតុហ្នឹងវាកើតឡើងរវាងនរោត្តម កន្ថុល ជាមួយនឹងខ្មែរក្រហមទេ?

[១៥:៥៨:០៧]

**ឆ៖** ចាស ពេលនោះកងទ័ពហ្នឹងដូចអត់មានប្រឆាំងអីហ្នឹងគាត់ទេ ក៏គាត់សូមអង្វរសំពះអង្វរទៅថា កុំធ្វើបាបគ្នាអី ដោះលែងគ្នាទៅនិយាយតាមសម្រួល។ អ៊ីចឹងទៅក៏ម្នាក់នោះងក់ក្បាលអ៊ីចឹងទៅអ៊ីចឹងស្រាយចំណងប្ដីខ្ញុំហ្នឹងទៅចាស ពេលនោះអត់មានប្រទូសរ៉ាយគ្នាអ្វីទេចាស។

**ស៖** រួចពីហ្នឹងបានជាកងទ័ពមួយកងទៀត ពីក្រោយគេចូលមកដេញម្ដងទៀតអ៊ីចឹង?

**ឆ៖** ចាស បន្តបន្ទាប់មកម៉ោងប្រាំបីយប់ វេលាម៉ោងប្រាំបីយប់ បានមួយក្រុមទៀតចំនួនប្រាំប្រាំមួយនាក់ហ្នឹងបានមកដេញកម្ចាត់កម្ចាយឲ្យចាកចេញទាំងយប់ងងឹតអ៊ីចឹងទៅចាស។ ចេញដំណើរទាំងអស់គ្នា បែកគ្នារហូតទាល់សព្វថ្ងៃហ្នឹងចាស។

**ស៖** ពេលនោះ អ្នកស្រីដឹងស្គាល់ នរោត្តម កន្ថុល តាមរយៈយ៉ាងម៉េច? ហេតុអីបានជាអ្នកស្រីស្គាល់?

**ឆ៖** ខ្ញុំមិនអាចថានេះទេ ព្រោះលោកបានយាងចូលមកដើរតាមមានខ្សែរយៈបងត្រូវជាសាច់សាលោហិត នរោត្តម សម្ដេច សីហនុ ហ្នឹងចាស។ ខ្ញុំមិនអាចដឹងជ្រៅជ្រះច្បាស់លាស់រឿងអស់នេះទេចាស គ្រាន់តែដឹងថា សែស្រឡាយរបស់ព្រះអង្គទេ ហើយខ្ញុំចេះតែគោរពតាមហ្នឹងទៅ ខ្ញុំមិនអាចដឹងច្បាស់ទៅមុខទៀត ថាបានចាស។

[១៥:៥៩:៥០]

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំអរគុណអ្នកស្រីដែរ ខ្ញុំអស់មានសំណួរ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។ ក្នុងនាមលោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ។ សូមអរគុណ។

[១៦:០០:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកស្រី ប៉ូ ឌីណា។ ការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកស្រី នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ ហើយមានសេចក្តីសុខសុភមង្គល។ លោកស្រីអាចវិលត្រឡប់ទៅវិញបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោកស្រី ប៉ូ ឌីណា វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។

[១៦:០១:២១]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី០៤ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃអង្គារ សប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីសេចក្តីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យចំនួនបីរូបដែលមានរហស្សនាម TCCP-4, TCCP-145, ហើយនិង TCCP-141។

ហើយអង្គជំនុំជម្រះ ក៏សូមជម្រាបផងដែរថា នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះមិនធ្វើការសវនាការទេ ដោយហេតុមានកិច្ចការចាំបាច់បន្ទាន់ជាច្រើនដែលអង្គជំនុំជម្រះត្រូវធ្វើ និងប្រជុំពិភាក្សាសម្រេច។ ហើយនៅថ្ងៃចន្ទ ទី០៣ ខែមិថុនា ឆ្នាំ២០១៣ ជាថ្ងៃឈប់សម្រាកជំនួសថ្ងៃសម្រាកទិវាបុណ្យអន្តរជាតិ - - ទិវាកុមារអន្តរជាតិ និងទិវាកុមារជាតិកម្ពុជា។ សូមភាគីនៃរឿងក្តី បុគ្គលគាំទ្រដល់កិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនគាត់ចូល ត្រឡប់មករួមនូវកិច្ចដំណើរការសវនាការវិញនៅថ្ងៃអង្គារ ទី០៤ ខែមិថុនា ឆ្នាំ២០១៣ ឲ្យបានមុខម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួន ស្ថិតនៅក្រោមសាលសវនាការនេះដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*